ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Nov-2013, 16:30
CMS/CFO: Krystal THOMPSON

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី២២៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ស៊ីម៉ុន មេសិនប៊ឺជ

*(Mr. Simon MEISENBERG)*

លោកស្រី សែ កុលវុឌ្ឍី

លោក អេនឌ្រូ ម៉ាកស៊ីនយឺ

*(Mr. Andrew MCINTYER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន

*(Mr.Nicolas KOUMJIAN)*

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក លោក ឃីត រេយន័រ

*(Mr. Keith RAYNOR)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក សំ សុគង់

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី បេនី យេ*(Ms.Beini YE)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

លោក ប៉ាស្កាល់ អូប៊ីង *(Mr. Pascal AUBOIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាក់ទូរ វែកគែន | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅជនជាប់ចោទ និងមេធាវីការពារក្តីជនជាប់ចោទដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ពិភាក្សាដេញដោលផ្នែកសំណុំរឿង០០២/០១ ចុងក្រោយបង្អស់។ ហើយមុននឹងផ្តល់វេទិកាជូនទៅជនជាប់ចោទ និងក្រុមមេធាវីការពារក្តីជនជាប់ចោទដែលនឹងចាប់ផ្តើមដោយលោក នួន ជា ជាមុននោះ។ ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធានសម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់លោកមេធាវី ពេជ អង្គ មេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងមកយឺតនៅពេលព្រឹកនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា មកនៅមុខឈើរាងវង់ក្រចកសេះនៅពីមុខអង្គជំនុំជម្រះនេះ ដើម្បីឱ្យគាត់ថ្លែងនូវសេចក្តីសន្និដ្ឋានចុងក្រោយរបស់គាត់។

*(ជនជាប់ចោទទៅកាន់ឈើរាងវង់ក្រចកសេះ)*

[០៩:០៣:៥៨]

**លោក នួន ជា៖**

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈដែលគង់នៅទីនេះ និងនៅគ្រប់វត្ត។ សូមគោរពបងប្អូនជនរួមជាតិជាទីស្នេហា សូមគោរពតុលាការ។

មកដល់ពេលនេះ សវនាការបានចំណាយពេលអស់រយៈជាងពីរឆ្នាំមកហើយ ដើម្បីសម្រេចពី

ជោគវាសនារបស់ខ្ញុំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកដល់ថ្ងៃទី ០៦ មករា ឆ្នាំ១៩៧៩។ ក្នុងអំឡុងពេលនេះគឺជាចន្លោះពេលមួយដែលទាក់ទងនឹងការបំពេញការងារស្ទើរតែមួយជីវិតរបស់ខ្ញុំក្នុងបុព្វហេតុបម្រើប្រទេសជាតិ និងប្រជាជនជាទីស្នេហារបស់ខ្ញុំផងដែរ។

ទាក់ទងទៅនឹងសវនាការនេះ បើទោះបីជាខ្ញុំមិនបានចូលរួមដោយផ្ទាល់ដោយសារសុខភាពរបស់ខ្ញុំមិនសូវល្អក្តី ក៏ខ្ញុំបានតាមដានស្តាប់ដោយយកចិត្តទុកដាក់នូវការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ និងការសួរដេញដោលសាក្សីទាំងឡាយនៅពេលសវនាការពីបន្ទប់ឃុំឃាំងខាងក្រោមសាលជំនុំជម្រះជាបន្តបន្ទាប់។

តាមរយៈសវនាការនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់នោះទេ។ និយាយឲ្យខ្លីទៅ គឺខ្ញុំមិនមានទោសអ្វីទាក់ទងនឹងការចោទប្រកាន់ដូចបានលើកឡើងនោះទេ។

សូមគោរពតុលាការ នៅពេលខ្ញុំនិយាយបែបនេះ ប្រហែលជាអាចមានអ្នកខ្លះដែលមិនទាន់បានយល់ច្បាស់អំពីច្បាប់ ឬមានការគំនិតលម្អៀងអាចសើចចំអកឡកឡឺយឲ្យខ្ញុំ តែនេះមិនជាអ្វីទេ។ នៅពេលខ្ញុំជម្រាបជូននៅពេលបន្តិចទៀតនេះ ទើបអស់លោកដឹងច្បាស់ថា អ្វីដែលខ្ញុំនិយាយគឺសុទ្ធសឹងជាការពិត។

[០៩:០៦:៣៩]

តាមផ្លូវច្បាប់ គោលបំណងនៃការបង្កើតតុលាការនេះ គឺមានទិសដៅ និងតួនាទីដើម្បីស្វែងរកការពិត និងយុត្តិធម៌ឲ្យខ្ញុំ និងជនរងគ្រោះតាមរយៈភស្តុតាងដ៏រឹងមាំ ស្របច្បាប់ និងអាចឲ្យជឿបាន។

ផ្ទុយទៅវិញ មកដល់ពេលនេះ លោក លោកស្រីសហព្រះរាជអាជ្ញាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញធាតុផ្សំបទល្មើសដែលបានចោទប្រកាន់ដាក់បន្ទុកមកលើរូបខ្ញុំ។ ហើយសិទ្ធិស្របច្បាប់របស់ខ្ញុំមួយចំនួនក៏មិនបានធានាត្រឹមត្រូវនៅក្នុងតុលាការនេះផងដែរ ដូចជា សិទ្ធិទទួលបានការកាត់សេចក្តីឲ្យបានឆាប់រហ័ស សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ សិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិផ្សេងៗទៀត ដែលធានាដោយច្បាប់ជាតិ និងអន្តរជាតិ។

ម្យ៉ាងវិញទៀត ចំណុចសង្ស័យជាច្រើនទាក់ទងនឹងភស្តុតាងក៏មិនទាន់បានលាតត្រដាងឲ្យបានច្បាស់លាស់នៅចំពោះមុខតុលាការ ដូចជាឯកសារដើម និងសក្ខីកម្មរបស់សាក្សីសំខាន់ៗដែលជួយដល់ខ្ញុំ។ ដូចលោក លោកស្រីចៅក្រម ព្រះរាជ -- ជ្រាបស្រាប់ហើយចំណុចទាំងអស់នេះលោកមេធាវីរបស់

ខ្ញុំបានបញ្ជាក់ជូនអង្គសវនាការយ៉ាងច្បាស់ និងមានមូលដ្ឋានច្បាប់ត្រឹមត្រូវរួមមកហើយ។ តែទោះជាយ៉ាងនេះក្តី រូបខ្ញុំផ្ទាល់សូមបញ្ជាក់បន្ថែមនូវចំណុចសំខាន់ៗមួយចំនួនទៀតសម្រាប់ជាមូលដ្ឋានផ្តល់ជូនលោក លោកស្រីចៅក្រម ជ្រាបកាន់តែច្បាស់ចំពោះភាពគ្មានទោស និងសុចរិតភាពរបស់ខ្ញុំពាក់ព័ន្ធនឹងបទចោទប្រកាន់ខាងលើ។ ខ្ញុំសំអាងបែបនេះ ដោយផ្អែកលើមូលដ្ឋានបីយ៉ាងជាសំខាន់គឺ៖

[០៩:០៩:០២]

<u>ក) ការគ្មានអំណាចគ្រប់គ្រង និងគ្មានអំណាចទប់ស្កាត់</u>

សូមគោរពតុលាការ និងគោរពបងប្អូនជនរួមជាតិជាទីស្នេហា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅនេះ ខ្ញុំបានជម្រាបជូនអង្គសវនាការម្តងរួចមកហើយថា ខ្ញុំមិនមានអំណាចអ្វី និងមិនជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទល្មើស ដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានតួនាទីតែបីប៉ុណ្ណោះគឺ៖

ក.១) <u>ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា</u>

នៅក្នុងមុខតំណែងនេះ ខ្ញុំមានតួនាទីជាអ្នកឃោសនា អប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស។ ចំពោះខ្លឹមសារនៃការឃោសនាអប់រំ ខ្ញុំមិនដែលឃោសនាអប់រំឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ ដូចជា ប្រើអំណាចអាជ្ញា ឬមានអាកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ។ ខ្ញុំបានអប់រំឲ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជា ចេះគោរពប្រជាជន ស្រឡាញ់ប្រជាជន បម្រើប្រជាជន និងប្រទេសជាតិរបស់ខ្លួន។ ខ្ញុំមិនដែលអប់រំ ឬណែនាំសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ឲ្យធ្វើបាប កាប់សម្លាប់ បង្អត់អាហារប្រជាជន ឬប្រល័យពូជសាសន៍ម្តងណាទេ។

[០៩:១១:២១]

ខ្ញុំតែងតែលើកយកគោលការណ៍សំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាមកបង្រៀន និងអប់រំដល់សមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងទិសដៅធ្វើយ៉ាងណាឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាទាំងអស់អនុវត្តការងារ និងបម្រើប្រជាជនឲ្យបានល្អប្រសើរ។

ជាពិសេស ខ្ញុំបានលើកយកគោលការណ៍ដែលមានចែងនៅក្នុងមាត្រា២ នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីអប់រំឲ្យសមាជិកបក្សទាំងអស់យល់ជ្រួតជ្រាបកាន់តែច្បាស់ អំពីភារកិច្ចរបស់សមាជិកបក្សក្នុងការចូលរួមសកម្មភាពសង្គម។ មាត្រា២ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ចែងថា "បក្ខជនគ្រប់រូប សុទ្ធតែមានភារកិច្ចដូចតទៅ៖

១) ភារកិច្ចក្នុងមហាជនគឺ

ក) ឃោសនា អប់រំមហាជនអំពីនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជិតស្និទ្ធនឹងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍។ ត្រូវទទួលខុសត្រូវខ្ពស់ចំពោះមហាជន បម្រើមហាជន អស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ វាបសានឹងមហាជន ហើយខំរៀនសូត្រពីមហាជន។

[០៩:១៣:១១]

ខ) បំផុសបំផុលចលនាមហាជន ពិសេសមហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ឲ្យក្តៅគគុក និងជាប់ជានិច្ចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសដៅបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម។

២) ភារកិច្ចផ្ទៃក្នុងគឺ

ឃ) ខិតខំថែរក្សា ពង្រឹង ពង្រីកសាមគ្គីភាពផ្ទៃក្នុងបក្សឲ្យបានល្អជាប់ជានិច្ចដាច់ខាត។

ផ្អែកលើគោលការណ៍នេះ វាបញ្ជាក់យ៉ាងច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងឲ្យសមាជិករបស់ខ្លួនមានស្មារតីទទួលខុសត្រូវខ្ពស់ ចុះជាប់ជាមួយប្រជាជន ធ្វើល្អជាមួយប្រជាជន យកចិត្តទុកដាក់ជាមួយប្រជាជន និងរៀនសូត្រពីប្រជាជន។ ជាពិសេស លើកទឹកចិត្តកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និងប្រជាជនឲ្យមានគំនិតស្នេហាជាតិ និងការពារមាតុភូមិ។ ទន្ទឹមនឹងនេះ ខ្ញុំតែងតែអប់រំឲ្យសមាជិកបក្សទាំងអស់កុំប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំពុករលួយ និងកុំលែងល្បែងស៊ីសង ។ល។ ជាពិសេស ឲ្យចេះសាមគ្គីគ្នា ទាំងក្នុងជួរបក្ស និងមហាជន។

អ្វីៗដែលខ្ញុំបានលើកឡើងខាងលើនេះ គឺជាឧទាហរណ៍មួយ បញ្ជាក់ពីកិច្ចការដែលខ្ញុំបានធ្វើក្នុងតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ និយាយឲ្យខ្លីទៅ អ្វីដែលខ្ញុំបានអប់រំ និងបង្រៀនដល់សមាជិកបក្ស និងកងទ័ពនោះ គឺជាការបណ្តុះពុទ្ធិឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ត្រូវមានឆន្ទៈស្នេហាជាតិ (អត់ទោស) ការពារជាតិ និងស្រឡាញ់ប្រជាជន មានសាមគ្គីភាពផ្ទៃក្នុងល្អក្នុងទិសដៅការពារ និងកសាងប្រទេសជាតិមួយ ឲ្យបានរីកចម្រើនរុងរឿង និងឯករាជ្យឲ្យពិតប្រាកដ ហើយមិនអនុញ្ញាតឲ្យប្រទេសណាមួយ ធំក្តី តូចក្តី ជិតក្តី ឆ្ងាយក្តី ឈ្លានពាន និងធ្វើអាណានិគមមកលើប្រទេសកម្ពុជាបានជាដាច់ខាត។

[០៩:១៦:១៦]

ការកម្លាត់ខ្មាំងឈ្លានពាន វាជាតួនាទីរបស់កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងការការពារជាតិមាតុភូមិ។ រួមជាមួយនេះ ការពង្រឹងសន្តិសុខ និងស្ថិរភាពនយោបាយផ្ទៃក្នុងត្រូវអនុវត្តឲ្យបានល្អប្រសើរ ទើបបដិវត្តន៍មានការរីកចម្រើនរុងរឿង។ តាមទស្សនៈទូទៅ ប្រការនេះ វាមិនខុសគ្នាទៅថ្នាក់ដឹកនាំគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ដែលត្រូវតែមានតួនាទីបែបនេះ ដើម្បីការពារសន្តិសុខ និងប្រទេសជាតិរបស់ខ្លួន។ ប្រទេសនានានៅលើពិភពលោកតែងតែមានច្បាប់ ដើម្បីបម្រើនយោបាយ និងគ្រប់គ្រងប្រទេសរបស់គេ។ ប្រសិនបើជនណាម្នាក់រំលោភច្បាប់ ជននោះនឹងត្រូវទទួលទោសតាមច្បាប់នៃប្រទេសនោះ។

<u>ក.២) ជាអនុប្រធានគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម (បច្ចុប្បន្នបក្សកុម្មុយនីស្តវៀតណាម)</u>

ចំពោះកិច្ចការទំនាក់ទំនងជាមួយប្រទេស និងប្រជាជនវៀតណាម គឺមានមកជាយូរយារណាស់មកហើយ។ តែចាប់តាំងពីមានចលនា និងការកកើតបក្សកុម្មុយនីស្តកម្ពុជា ការទំនាក់ទំនងជាមួយវៀតណាមកាន់តែបានពង្រឹងថែមទៀត ដោយមានការចាត់តាំងជាគណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាម តាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់ភូមិភាគ។

[០៩:១៨:១០]

គណៈមុខ -- គណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាមថ្នាក់មជ្ឈិម មាន ប៉ុល ពត ជាប្រធាន ហើយខ្ញុំជាអនុប្រធានគណៈកម្មាធិការនេះ។ តែដោយ ប៉ុល ពត មានកិច្ចការច្រើន ដូច្នោះហើយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានតែងតាំងខ្ញុំជាអនុប្រធានឲ្យទទួលកិច្ចការនេះជំនួស ប៉ុល ពត។ នៅក្នុងឱកាសនោះហើយ ដែលខ្ញុំបានជួបប្រជុំជាមួយបក្សកុម្មុយនីស្តវៀតណាមជាញឹកញាប់។ ចាប់តាំងពីខ្ញុំទទួលកិច្ចការនេះ ខ្ញុំបានដឹងពីកលល្បិច និងកិច្ចការសម្ងាត់ជាច្រើនរបស់ប្រទេសវៀតណាមដែលមានមកលើប្រទេសកម្ពុជាយើង។

ខ្ញុំចាំបានថា នៅពេលខ្ញុំចូលបម្រើចលនាបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៥០ គឺមានវត្តមានកងទ័ពវៀតណាម (វៀតកុង) នៅទូទាំងប្រទេសកម្ពុជារួចជាស្រេចទៅហើយ។ សមាសភាពនេះអាចបានបង្កប់ខ្លួននៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ទាំងនៅក្នុងជួរកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងថ្នាក់ដឹកនាំស៊ីវិល និងក្នុងប្រជាជនកម្ពុជា។

[០៩:១៩:៤១]

ខ្ញុំចាំបានថា នៅពេលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូង គឺមិនទាន់មានការិយាល័យ ឬទីបញ្ជាការរបស់ខ្លួនទេ។ បក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាមទាំងស្រុង។ តែនៅដើមឆ្នាំ១៩៦៤ ប៉ុល ពត បានរំដោះបក្សចេញពីការគ្រប់គ្រងចាត់ចែងពីបក្សកុម្មុយនីស្តវៀតណាម។ ប៉ុល ពត និងសមាជិកគណៈមជ្ឈិមបក្សមួយចំនួនបានទៅកសាងមូលដ្ឋានបង្អែករបស់ខ្លួនដែលមានឈ្មោះថាមន្ទីរ១០០។ ក្រោយមកមន្ទីរនេះបានចល័តទៅនៅខេត្តរតនគិរី។ ពេលនោះការិយាល័យនោះមិនទាន់មានសេរីភាពពេញលេញទេ។ វៀតណាមដែលមានមូលដ្ឋានសឹកនៅភូមិភាគ៥ នៃប្រទេសវៀតណាមបានខំរកគ្រប់វិធីដើម្បីក្តោបក្តាប់បក្សកុម្មុយនីស្តកម្ពុជា គ្រប់ពេលវេលាទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា។

នៅទសវត្សរ៍ឆ្នាំ១៩៦០ វៀតណាមខាងជើងបានប្រើប្រាស់ប្រទេសកម្ពុជាធ្វើជាមូលដ្ឋានសឹកដើម្បីវ៉ៃប្រយុទ្ធជាមួយនឹងវៀតណាមខាងត្បូង (ធីវ គី)។ នៅពេលជាមួយគ្នានេះដែរចលនាបក្សកុម្មុយនីស្តកម្ពុជាបានរីកដុះដាលយ៉ាងរហ័សបន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលធ្វើឡើងដោយចក្រពត្តិអាមេរិក និងបនក្បត់ជាតិ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់។

[០៩:២១:៤៦]

នៅពេលនេះហើយកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើង ហើយរីកចម្រើនធំធាត់យ៉ាងឆាប់រហ័ស។ នៅពេលនោះដែរវៀតណាមបានជ្រើសរើសខ្មែរមួយចំនួនប្រហែល ៣០០០នាក់ឲ្យទៅរៀនសូត្រ និងទទួលការបំពាក់បំប៉នទាំងផ្នែកបច្ចេកទេស នយោបាយ និងសតិអារម្មណ៍នៅប្រទេសវៀតណាមខាងជើង។ នៅពេលពួកគេត្រឡប់មកប្រទេសកម្ពុជាវិញ នៅពាក់កណ្តាលឆ្នាំ១៩៧៣ អ្នកទាំងនោះត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា។

និយាយជារួម វៀតណាមខំប្រើគ្រប់ល្បិចកល ដើម្បីគ្រប់គ្រងចលនាបក្សកុម្មុយនីស្តកម្ពុជាទាំងផ្នែកយោធា នយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល។ តែទោះជាយ៉ាងណានេះក្តីអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានមើលឃើញថា បក្សកុម្មុយនីស្តវៀតណាមធ្វើបែបនេះ គឺមិនស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។

នៅដើមឆ្នាំ១៩៧៣ ដោយការខិតខំតស៊ូបម្រើបម្រះរំដោះខ្លួនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្ស និងដោយសង្គ្រាមនៅវៀតណាមខាងត្បូងកាន់តែប្រយុទ្ធសន្ធោ

សន្ធៅ កងទ័ពវៀតណាមបានបង្ខំចិត្តបន្ធូរដៃគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធ និងរដ្ឋអំណាចកម្ពុជា ហើយដកខ្លួនទៅប្រយុទ្ធជាមួយវៀតណាមខាងត្បូង។ ពេលនោះហើយជាឱកាសមួយធ្វើឲ្យកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជាកាន់តែមានឯករាជ្យភាព និងកម្លាំងរឹងមាំ បន្ថែមទៀត។ ខណៈនោះបក្សកុម្មុយនីស្តកម្ពុជាក្រោមការខិតខំរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្ស បានអនុវត្តនូវគោលការណ៍ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង។

[០៩:២៤:៣១]

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជន បដិវត្តន៍កម្ពុជាបានជ័យជម្នះលើរបប លន់ នល់ ហើយប្រហែលជាពីរអាទិត្យក្រោយមកវៀតណាមខាងត្បូងក៏ត្រូវបានរំដោះផងដែរ។ ទាក់ទងនឹងមហាជ័យជម្នះនេះ គឺប្រជាជនកម្ពុជា និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាបានរំដោះទីក្រុងភ្នំពេញដោយខ្លួនឯង ហើយបក្សនិងកងទ័ពប្រជាជនកម្ពុជាមានឯករាជ្យពេញលេញក្នុងការគ្រប់គ្រងប្រទេសជាតិខ្លួន។ បើទោះជាបក្សកុម្មុយនីស្តវៀតណាមប្រកាសថា កងទ័ពវៀតណាមបានដក ឬក៏ឈប់គ្រប់គ្រងដោយផ្ទាល់លើចលនាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៣ យ៉ាងណាក៏ដោយ តែការពិតកងកម្លាំងវៀតណាម និងភ្នាក់ងារសម្ងាត់របស់វៀតណាមជាច្រើនដែលបានជ្រៀតចូលក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាជាយូរមកហើយ នៅតាមមូលដ្ឋាននានាទូទាំងប្រទេសកម្ពុជា មិនបានត្រឡប់ទៅប្រទេសវៀតណាមវិញទេ។ ពួកគេបាននៅធ្វើការតាមរូបភាពចំហខ្លះ និងសម្ងាត់ខ្លះជាមួយអាណិកជនវៀតណាម និងប្រជាជនកម្ពុជា។

[០៩:២៦:០៥]

ប្រការនេះ ដំបូងឡើយយើងមិនបានយល់ដឹងស៊ីជម្រៅចំពោះកលល្បិចរបស់វៀតណាមនោះទេ។ ក្រោយមកយើងបានដឹងច្បាស់ពីឧបាយកលទាំងនោះតាមរយៈភស្តុតាងបួនយ៉ាងគឺ៖

ក) មានរបាយការណ៍ថាប្រជាជនកម្ពុជាត្រូវបានគេបង្អត់បាយនិងធ្វើការជាទម្ងន់នៅតាមមូលដ្ឋាន។

២) ប្រជាជនកម្ពុជាត្រូវបានគេសម្លាប់។

៣) កម្មាភិបាលថ្នាក់ក្រោមមិនបានរាយការណ៍ពីស្ថានភាពទាំងអស់នោះជូនថ្នាក់លើ និង

៤) កងទ័ពរបស់យើងមួយចំនួនបានបង្កអរិភាព និងចុះចូលជាមួយវៀតណាម ជាពិសេសនៅ

ភូមិភាគបូព៌ា។

ទាំងអស់នោះហើយបង្ហាញយ៉ាងច្បាស់ថា វៀតណាមបានបង្កប់ភ្នាក់ងារសម្ងាត់របស់គេនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងគោលបំណងបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា សម្លាប់ប្រជាជន និងលេបយកទឹកដីនៃប្រទេសកម្ពុជាដែលវៀតណាមមានមហិច្ឆតាជាយូរមកហើយ។

ជាក់ស្តែងណាស់នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៤ វៀតណាមបានឈ្លានពានប្រទេសកម្ពុជានៅពេលដែលវៀតណាមបានកម្ទេចមូលដ្ឋានគ្រឹះរបស់បដិវត្តន៍កម្ពុជានៅតាមមូលដ្ឋានស្ទើរតែទាំងអស់តាមរយៈការបង្អត់អាហារ ការកាប់សម្លាប់ប្រជាជន និងការបង្កើតឲ្យមានភាពមិនទុកចិត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ប្រទេសវៀតណាមបានគ្រប់គ្រងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១ នៅពេលប្រទេសកម្ពុជាមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១។

[០៩:២៨:២៣]

អំពើបង្អត់អាហារ និងកាប់សម្លាប់ប្រជាជនកម្ពុជាទាំងអស់នោះ វាផ្ទុយស្រឡះពីទស្សនៈ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ផ្អែកលើមូលដ្ឋាននេះ ខ្ញុំសន្និដ្ឋានបានថាអំពើទាំងអស់នោះ គឺជាអំពើរបស់បក្សកុម្មុយនីស្តវៀតណាមយ៉ាងពិតប្រាកដ។ ខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាមានការឈឺចាប់ណាស់នៅពេលដែលខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាបានដឹងថា បក្សកុម្មុយនីស្តកម្ពុជាចាញ់ល្បិចកលវៀតណាម ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លួនស្លាប់ ហើយប្រទេសជាតិធ្លាក់ចូលទៅក្នុងភាពអន្តរាយបែបនេះ។ តែវាហាក់ដូចជាហួសពេលក្នុងការស្តារឡើងវិញទៅហើយ។

នៅពេលប្រទេសវៀតណាមឈ្លានពានប្រទេសកម្ពុជា កិច្ចការទូតរវាងប្រទេសទាំងពីរត្រូវបានកាត់ផ្តាច់។ កិច្ចការការពារជាតិ និងការបញ្ជាក់ -- និងការបញ្ជាកម្លាំងប្រយុទ្ធបានធ្លាក់ទាំងស្រុងទៅលើ សុន សេន ដែលជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ។ ពេលនោះហើយដែលតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម(គណបក្សកុម្មុយនីស្ត) នេះត្រូវបានបញ្ចប់ទាំងស្រុង។

<u>ក.៣) ជាប្រធានសភាតំណាងប្រជាជនកម្ពុជា</u>

គោរពតុលាការ! ក្រោយពេលរំដោះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជ្រើសឲ្យធ្វើជាប្រធានសភាតំណាងប្រជាជនកម្ពុជា។ តាមផ្លូវច្បាប់ នៅក្នុងតួនាទីនេះ ខ្ញុំទទួលខុសត្រូវក្នុងការអនុម័តច្បាប់។ នៅពេលនោះ ដោយសារប្រទេសកម្ពុជាទើបតែចប់សង្គ្រាម ហើយក៏មានសង្គ្រាមបន្តជាមួយ

វៀតណាមទៀតនោះ ក្នុងរយៈពេលខ្លីបែបនេះ យើងមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើច្បាប់ច្រើននោះទេ។ ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិស្ថិតក្នុងស្ថានភាពបែបនេះ កិច្ចការច្បាប់គឺមិនមែនជាកិច្ចការជាអាទិភាពនោះដែរ។

[០៩:៣០:៥៧]

តាមទ្រឹស្តីនៃរបបកុម្មុយនីស្ត ការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាប្រទេសកុម្មុយនីស្តផ្សេងៗទៀតដែរ គឺមានបក្សដឹកនាំ និងរដ្ឋគ្រប់គ្រងប្រទេស។ ក្នុងន័យនេះ បក្សផ្តល់ជាគោលការណ៍សម្រាប់ដឹកនាំ ចំណែករដ្ឋវិញគឺសំដៅទៅលើរដ្ឋាភិបាល ឬនីតិប្រតិបត្តិដែលជាអ្នកមានអំណាចគ្រប់គ្រងប្រទេសទាំងមូល។ និយាយឲ្យចំទៅ មានតែរដ្ឋាភិបាលទេដែលមានអំណាចពេញលេញក្នុងការបញ្ជា ឬអនុវត្តរាល់សកម្មភាពការងារទាំងឡាយក្នុងការគ្រប់គ្រងប្រទេស។

នៅក្នុងសម័យកាលនោះ បើទោះបីជាមានការបែងចែកអំណាចជាបី គឺនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ ដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិប-តេយ្យយ៉ាងណាក៏ដោយ ក៏វាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ។ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការមិនបានដំណើរការពេញលេញទេ។ ជាក់ស្តែងមានតែនីតិប្រតិបត្តិទេដែលបានដំណើរការងារពេញលេញ ហើយ ប៉ុល ពត បានទទួលតំណែងជានាយករដ្ឋមន្ត្រី។ ដូច្នោះហើយ ប៉ុល ពត មានអំណាចជារួមក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស ទាំងនៅក្នុងជួរបក្ស និងនៅក្នុងរដ្ឋាភិបាល ដោយសារគាត់ជាលេខាបក្ស និងជានាយករដ្ឋមន្ត្រី។ នៅក្នុងតួនាទីនេះគ្មាននរណាម្នាក់អាចជំនួសគាត់បានឡើយ។ ផ្អែកលើមូលដ្ឋាននេះបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានអំណាចអ្វីបន្តិចក្នុងការគ្រប់គ្រង និងប្រតិបត្តិការងារនៃនីតិប្រតិបត្តិឡើយ។

[០៩:៣៣:១៣]

ក) ការចោទប្រកាន់ចំពោះមុខតំណែងផ្សេងទៀត

ខ្ញុំសូមបញ្ជាក់ថា ក្រៅពីតួនាទីខាងលើ ខ្ញុំមិនដែលបានទទួលនាទីអ្វីទៀតទេ។ ខ្ញុំមានចម្ងល់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទីជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១។

ការចោទប្រកាន់បែបនេះបើទោះជាមានចេតនា ឬអចេតនាក៏ដោយ វាជាការនិយាយខុសពីការពិតទាំងស្រុង ហើយពុំមានភស្តុតាងជាក់លាក់ផងដែរ។ ប៉ុល ពត គាត់មានឧបនាយករដ្ឋមន្ត្រីរបស់គាត់

គឺលោក អៀង សារី, លោក សុន សេន, និងលោក វន វេត។ ដូចនេះវាគ្មានហេតុអ្វីដែល ប៉ុល ពត តែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីក្រៅពីឧបនាយករដ្ឋមន្ត្រីរបស់គាត់នោះទេ។ ជាការពិតណាស់ គាត់មិនអាចតែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៅពេលដែលគាត់អវត្តមានពីប្រទេសនោះទេ។ ពីព្រោះខ្ញុំមិនមានតួនាទីណាមួយនៅក្នុងអំណាចនីតិប្រតិបត្តិទាល់តែសោះ។ ប្រសិនបើគាត់ធ្វើបែបនេះវាជាអំពើខុសច្បាប់របស់បក្ស។

[០៩:៣៥:០០]

ចំពោះការចោទថា ខ្ញុំធ្វើជាសមាជិកគណៈកម្មាធិការឃោជាមជ្ឈិម និងជាប់ទាក់ទងទៅនឹងការគ្រប់គ្រងមន្ទីរស-២១ នោះក៏វាជារឿងមិនពិតដែរ។ ជាការពិតណាស់ ខ្ញុំមិនដែលបានធ្វើកិច្ចការទាំងនេះទេ។ កិច្ចការទាំងអស់នោះ លោក សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់។ ខ្ញុំមិនដែលបានជួប មិនបានគ្រប់គ្រង ឬមិនបញ្ជា ឌុច ឲ្យធ្វើបាប ឬសម្លាប់មនុស្សនោះទេ។ អស់លោកគួរតែជ្រាបហើយ សារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការផ្ទាល់របស់ខ្លួននោះទេ។ ដូច្នេះគ្មានហេតុអ្វីដែល ឌុច ស្តាប់ខ្ញុំនោះទេ។ និយាយដោយត្រង់ទៅ ខ្ញុំទើបតែឮឈ្មោះ ឌុច នៅក្រោយឆ្នាំ១៩៧៩តែប៉ុណ្ណោះ។ សម្តីរបស់ ឌុច ដែលបានចោទខ្ញុំថាបានគ្រប់គ្រងមន្ទីរស-២១ នោះ គឺគាត់គ្រាន់តែចង់គេចពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ និងមានបំណងចង់ឲ្យខ្ញុំទទួលទោសអស់មួយជីវិតដូចគាត់ដែរ។ ដោយសារ សុន សេន ស្លាប់ ហើយ ឌុច ត្រូវបានតុលាការផ្តន្ទាទោសអស់មួយជីវិតទៅហើយ។ មនុស្សដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ មិនដែលនិយាយការពិតនោះទេដោយសារគាត់មានកំហឹងពេញខ្លួន និងអស់សង្ឃឹមក្នុងជីវិត។ នេះគឺជាហេតុផលជាក់លាក់ដែលគាត់ឆ្លើយទម្លាក់កំហុសមកលើខ្ញុំ។

[០៩:៣៦:៥៤]

និយាយជារួមចំណុចទាំងអស់នេះ លោកមេធាវីរបស់ខ្ញុំបានបញ្ជាក់ជូនលោក លោកស្រីចៅក្រមច្បាស់លាស់រួចអស់ហើយថា ខ្ញុំមិនបានបំពេញកិច្ចការនេះទាល់តែសោះ ហើយក៏គ្មានឯកសារណាមួយជាក់លាក់បញ្ជាក់ពីរឿងនេះដែរ។

ផ្អែកលើមូលដ្ឋានទាំងអស់ខាងលើនេះ បញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំគ្មានអំណាច និងមិនមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំង ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ។ ដូច្នេះ តើមានហេតុផលអ្វីដែលខ្ញុំអាចបញ្ជា បញ្ចុះបញ្ចូល ឬទប់ស្កាត់មិនឲ្យជនល្មើសប្រព្រឹត្តបទល្មើសបាននៅក្នុងសម័យនោះ។

សូមលោក លោកស្រីចៅក្រមពិចារណា។

ខ្ញុំសូមអះអាងយ៉ាងឱឡារិកថា អ្វីដែលខ្ញុំបានចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមានបំណងចង់រំដោះប្រទេសជាតិពីអាណានិគមនិយម និងការពារទឹកដីពីការឈ្លានពានពីប្រទេសជិតខាងដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយនោះទេ។ ខ្ញុំស្រឡាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានបំណង និងចេតនាណាមួយធ្វើបាប កាប់សម្លាប់ ឬប្រល័យពូជសាសន៍ឯងនោះទាល់តែសោះ។

[០៩:៣៨:៣០]

<u>ខ) ការគ្មានភស្តុតាងគ្រប់គ្រាន់នៅក្នុងបទចោទ</u>

<u>ខ.១) ការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ</u>

ករណីនេះ ខ្ញុំសូមបញ្ជាក់ដោយស្មោះត្រង់ថា ខ្ញុំមិនដែលបានដឹងថា អតីតទាហាន លន់ នល់ ត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃខេត្តពោធិ៍សាត់នោះទេ។ ក្រោយពេលរំដោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បើតាមខ្ញុំដឹង បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានបង្កើតគោលនយោបាយឲ្យកងកម្លាំងរបស់ខ្លួនកាប់សម្លាប់អតីតទាហាន លន់ នល់ ឬប្រជាជនទេ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះឈ្លើយសឹក គឺសន្តោសប្រណី និងលើកលែងទោស។ ពីព្រោះអ្នកទាំងនោះត្រូវគេចាប់បង្ខំមកឲ្យធ្វើទាហាន សម្រាប់មកប្រយុទ្ធស្លាប់ជំនួសគេ ហើយពួកគេជាកូនចៅរបស់ប្រជាជននៅក្នុងមូលដ្ឋានរំដោះរបស់បក្សកុម្មុយនីស្តកម្ពុជា។

ជាគោលការណ៍ ការធ្វើបដិវត្តន៍ គឺប្រមូលកម្លាំង បើយើងសម្លាប់អ្នកទាំងនោះដូចការចោទប្រកាន់ គឺខុសពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយរុញច្រានឪពុកម្តាយ បងប្អូនរបស់ពួកគេឲ្យទៅនៅជាមួយខ្មាំង បន្ថែមកម្លាំងឲ្យខ្មាំង ឬឲ្យគេងាកមកប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជាវិញទេ។ តែទោះជាមានការកាប់សម្លាប់អតីតទាហាន លន់ នល់ ពិតមែន ក៏នោះគឺជាការសម្រេចចិត្តរបស់មន្ត្រីថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើខុសឆ្គង ធ្វើតាមទំនើងចិត្តរបស់ខ្លួន ឬប្រហែលជាមានបំណងសងសឹកនឹងការគុំកួនគ្នានៅពេលធ្វើសង្គ្រាម។

[០៩:៤០:៤១]

ទាក់ទងនឹងករណីនេះ មានសាក្សីមួយចំនួនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការថា ទាហានខ្មែរក្រហមប្រមូលអតីតទាហាន លន់ នល់ មកជួបប្រជុំនៅសាលាខេត្តពោធិ៍សាត់ ប្រហែលជា

មួយអាទិត្យក្រោយរំដោះ ១៧ មេសា ១៩៧៥។ សាក្សីទាំងនោះផ្តល់សក្ខីកម្មផ្ទុយគ្នា។ សូម្បីតែចម្លើយរបស់គាត់ទៅចៅក្រមស៊ើបសួរ និងនៅសវនាការក៏ខុសគ្នាដែរ។ ដូចជាសាក្សីឈ្មោះ លឹម សាត បានផ្តល់ចម្លើយទៅចៅក្រមស៊ើបសួរថា "ទាហាន លន់ នល់ ដែលចូលរួមប្រជុំនៅសាលាខេត្តពោធិ៍សាត់ និងក្រោយមកត្រូវយកទៅសម្លាប់មានចំនួនប្រហែល៣០០០នាក់។ អ្នកទាំងនោះត្រូវបានដឹកតាមឡានចំនួន២០ ទៅ៣០ឡាន ហើយក្នុងមួយឡានដាក់មនុស្សប្រហែល៣០នាក់"។ នៅពេលសវនាការសាក្សី លឹម សាត ឆ្លើយថា៖ "ទាហាន លន់ នល់ នោះ មានចំនួន២០០០នាក់ ខ្វះបន្តិចបន្តួចប៉ុណ្ណោះ ដឹកតាមឡានពី១០ ទៅ១៥ឡាន"។

សាក្សីឈ្មោះ អ៊ុំង ឆាត់ បានឆ្លើយនៅក្នុងសវនាការដែលថា "ទាហាន លន់ នល់ ប្រជុំនៅសាលាខេត្តពោធិ៍សាត់មានចំនួន២០០នាក់"។ ក្រោយមកថាមានចំនួនពី១០០ ទៅ១៥០នាក់ទៅវិញ។ ហើយខ្សែវីដេអូរបស់ ថេត សម្បត្តិ ដែលមានចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ"។ មានសាក្សីថា ទាហាន លន់ នល់ ដែលត្រូវយកទៅសម្លាប់នោះ មានចំនួនប្រហែល១០.០០០នាក់។

[០៩:៤២:៤៣]

លើសពីនេះ មានសាក្សីខ្លះទៀតឆ្លើយថា "គេបានលួចចូលទៅមើល ហើយឃើញខ្មោចនៅពេញវាល ដោយគ្មានសម្លៀកបំពាក់យោធា ឬសាក់កាដូទេ"។ តែសាក្សីខ្លះអះអាងថា មានសាក់កាដូនៅទីនោះច្រើនណាស់។

សូមសាធារណជន លោក លោកស្រីចៅក្រមពិចារណា និងដាក់ចម្ងល់បន្តិចមើល នៅក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះ តើមានហេតុផលអ្វីដែលប្រជាជនទាំងនោះ ប្រថុយនឹងគ្រោះថ្នាក់ដល់ជីវិតសុខចិត្តលួចចូលទៅមើលសាកសពទាំងនោះ។ ប្រសិនបើមានសម្លាប់មែននោះ ខ្ញុំជឿថាកន្លែងនោះជាតំបន់គ្រោះថ្នាក់ មនុស្សយើងធម្មតាមិនហ៊ានទៅទីនោះទេ។

នៅពេលចៅក្រមស្តាប់ចម្លើយសាក្សីទាំងនោះ តើសាក្សីទាំងអស់នេះគួរជឿ និងយកជាសក្ខីកម្មត្រឹមត្រូវបានឬទេ? ចម្លើយគឺថា មិនអាចឲ្យជឿនិងយកជាការបានទេ។ ដោយសារសក្ខីកម្មរបស់សាក្សីទាំងអស់នោះ ពោរពេញទៅដោយចំណុចមន្ទិលសង្ស័យ និងភូតកុហក។ ខ្ញុំសួរថា នៅពេលនោះក្នុងនាមជាអ្នកដឹកនាំម្នាក់ តើមានពេលវេលាឯណាសម្រាប់គិតគូរពីបញ្ហានេះ។ ពួកយើងមានកិច្ចការរួមសំខាន់ៗ និងបន្ទាន់ជាច្រើននៅទីក្រុងភ្នំពេញ។ ជាពិសេសនៅអំឡុងពេលពីរឬបីខែដំបូង។ បញ្ហាសំខាន់គឺ ដោះស្រាយជីវភាពរបស់ប្រជាជន និងការពារជាតិឲ្យផុតពីការប៉ុនប៉ងគ្រប់គ្រងពីបក្សកុម្មុយនីស្តវៀតណាម

និងពីគូបដិបក្ខ។

[០៩:៤៤:៤៩]

លើសពីនេះទៀត ខ្ញុំសូមឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ហិង្សាបដិវត្តន៍ តាំងពីមុនឆ្នាំ១៩៧៥។ ការអះអាងនេះវាហាក់ដូចជាមើលព្រឹត្តិការណ៍ប្រទេសកម្ពុជាតែជ្រុងម្ខាង ឯជ្រុងម្ខាងទៀតធ្វើជាមិនដឹង មិនឃើញ ឬធ្វើមិនឮ។ បើនិយាយភាសានៅក្នុងតុលាការវិញ គេថាយុត្តិធម៌សម្រាប់តែអ្នកឈ្នះ។ សូមកុំភ្លេចថា មុនពេលសម្រេចចិត្តតស៊ូដោយអាវុធក្នុងបុព្វហេតុរំដោះប្រទេសជាតិ សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនជាច្រើនរូបត្រូវបានគេលួចសម្លាប់ ចាប់ខ្លួន ធ្វើទារុណកម្មដោយគ្មានហេតុផល និងបាត់ខ្លួនជារៀងរាល់ថ្ងៃ។ ព្រឹត្តិការណ៍នោះ ប្រជាពលរដ្ឋគ្រប់រូបគួរតែនៅចងចាំនៅឡើយ។ អំពើហិង្សាទាំងនោះបានកើតមានគ្រប់ជំនាន់នៃសង្គមខ្មែរ ហើយជនរងគ្រោះនៃព្រឹត្តិការណ៍ទាំងនោះ សុទ្ធសឹងជាកសិករក្រីក្រ និងជនស្លូតត្រង់។

[០៩:៤៦:១០]

ខ្ញុំសូមចាប់ផ្តើមពីសម័យអាណានិគមនិយមបារាំង។ បារាំងបានធ្វើអាណានិគមមកលើប្រទេសកម្ពុជាអស់រយៈពេលជិតមួយសតវត្សរ៍។ អ្នកកាន់អំណាចនាសម័យនោះបានប្រើហិង្សាដោយតាមចាប់ខ្លួន និងកាប់សម្លាប់ប្រជាជនកសិករ ដែលគ្មានអាវុធនៅភូមិក្រាំងលាវ ក្នុងខេត្តកំពង់ឆ្នាំង ដែលពួកគាត់ពុំមានលទ្ធភាពបង់ពន្ធដារ ត្រូវបង្ខំចិត្តតវ៉ា និងទាមទារយុត្តិធម៌។ ចុងក្រោយអ្នកចាញ់ គឺកសិករក្រីក្រ ហើយភូមិរបស់ពួកគាត់ត្រូវបានគេប្តូរឈ្មោះទៅជា "ភូមិតិរច្ឆាន"។ តើនេះមិនមែនជាហិង្សាទេឬ?

នៅសម័យសង្គមរាស្ត្រនិយម ពួកអ្នកមានអំណាចបានទៅឈ្លូសឆាយផ្ទះសម្បែង ស្រែចម្ការរបស់កសិករនៅអណ្តើកហែប សំឡូត ។ល។ ពួកគេបានរំលោភបំពានយកដីពីប្រជាកសិករ ដែលធ្លាប់បានរស់នៅទីនោះតកូនតចៅរាប់ជំនាន់មកហើយនោះ។ នៅពេលដែលប្រជាជនតវ៉ាដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគាត់ ទាហានបានបាញ់សម្លាប់ប្រជាជនដែលគ្មានអាវុធយ៉ាងរង្គាល ទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី។ ឈឺចាប់ជាងនេះ ពួកគេតាមកាប់សម្លាប់ប្រជាជនជាច្រើនទៀត ដែលជាហេតុធ្វើឲ្យប្រជាជនមានការភ័យខ្លាច និងរត់ចូលព្រៃ។ តែអ្នកមានអំណាចបានចោទប្រកាន់ប្រជាជនម្ចាស់ទឹក ម្ចាស់ដីទាំងនោះថាជាខ្មែរក្រហម។ តើនេះមិនមែនជាការបង្កើតហិង្សា និងធ្វើឲ្យឈឺចាប់ទេឬ?

[០៩:៤៨:១៣]

នៅក្នុងសម័យ លន់ នល់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក ពួកទាហាន លន់ នល់ បានរំលោភស្ត្រី ប្លន់យកទ្រព្យសម្បត្តិ កាប់សម្លាប់ប្រជាជននៅគ្រប់ទីកន្លែង និងកាត់ក្បាលមនុស្សដោតតាមរបងផ្ទះ ដោយគ្រាន់តែសង្ស័យថាប្រឆាំងនឹងរបបរបស់ខ្លួន និងយកលេសថាប្រជាជនរងគ្រោះទាំងនោះជាខ្មែរក្រហម។ មិនតែប៉ុណ្ណោះពួកលន់នល់ បានប្រព្រឹត្តជាប្រព័ន្ធនូវអំពើរំលោភស្ត្រីភេទ ប្លន់ទ្រព្យសម្បត្តិ ជម្លៀសដោយហិង្សាចេញពីផ្ទះសម្បែង កាប់សម្លាប់យ៉ាងរង្គាលលើអាណិកជនវៀតណាមនៅគ្រប់ទីកន្លែង។

លើសពីនេះអាមេរិកផ្ទាល់បានទម្លាក់គ្រាប់បែកជាច្រើនតោនមកលើភូមិករ ផ្ទះសម្បែង វត្តអារាម ស្រែចម្ការរបស់កសិករកម្ពុជា សម្លាប់ជនស៊ីវិល មានទាំងកុមារ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ និងជនពិការអស់រាប់ម៉ឺននាក់។ តើនេះមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេឬ?

នៅក្នុងឆ្នាំ១៩៧៩ វៀតណាមបានចូលឈ្លានពាន និងកាន់កាប់ប្រទេសកម្ពុជា ហើយនៅឆ្នាំបន្តបន្ទាប់មកពួកគេបានបាញ់ផ្លោងដាក់ជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃធ្វើឲ្យឆេះលំនៅដ្ឋានទ្រព្យសម្បត្តិ បាត់បង់ជីវិតមនុស្សរាប់សិបនាក់ ក្នុងនោះមានទាំងកុមារ ស្ត្រីភេទ មនុស្សចាស់ជរា និងជនពិការផងដែរ។ លើសពីនេះពួកគេបានរៀបចំផែនការ ក-៥ ដោយចាប់បង្ខំប្រជាជនស៊ីវិលឲ្យចូលព្រៃជញ្ជូនគ្រាប់រំសេវ ជីកលេណដ្ឋាន ដើម្បីការពារអំណាចដែលបានមកពីការឈ្លានពាន ដែលបណ្តាលឲ្យប្រជាជនស្លាប់អស់រាប់ម៉ឺននាក់។ តើទាំងនេះមិនមែនជាឧក្រិដ្ឋកម្មទេឬ? មិនមែនជាផែនការសម្លាប់មនុស្សទេឬ?

[០៩:៥០:៣៥]

នៅក្នុងឆ្នាំ១៩៩៩ -- ៩៧ គេបានប្រយុទ្ធគ្នាក្នុងទីក្រុងភ្នំពេញ ដើម្បីដណ្តើមអំណាចគ្នាបណ្តាលឲ្យឆេះផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ប្រជាជន ស្លាប់ជនស៊ីវិល ហើយឈ្លើយសឹកមួយចំនួនរបស់ទាហានហ្វ៊ុនស៊ីនប៉ិចត្រូវបានគេបាញ់សម្លាប់ក្រោយពេលពួកគេចុះចាញ់។ ឧទាហរណ៍លោក ហូ សុខ ត្រូវបានគេសម្លាប់នៅក្នុងបរិវេណក្រសួងមហាផ្ទៃ នៅពេលចាប់បានជាចំណាប់ខ្មាំង។ តើនេះមិនមែនជាហិង្សាឬបទល្មើសឧក្រិដ្ឋទេឬ? តើព្រឹត្តិការណ៍ទាំងអស់ដែលខ្ញុំលើកឡើងមកនេះមិនមែនជាហិង្សា ឬ ឧក្រិដ្ឋកម្ម ជាអំពើអមនុស្សធម៌ទេឬ? ទាំងអស់នេះអាចជាសក្ខីភាពមួយសម្រាប់ធ្វើការប្រៀបធៀប

ទៅនឹងស្ថានភាពនៃបក្សកុម្មុយនីស្តកម្ពុជា។

ប្រសិនបើចោទប្រកាន់ថាមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានប្រើហិង្សា ចុះហេតុអ្វីសហព្រះរាជអាជ្ញាមិនព្រមផ្តល់សច្ចភាពបន្តិចបន្តួច ដោយគ្រាន់តែលើកពីអំពើខ្លះៗស្រាលៗដែលភាគីម្ខាងទៀតបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា។ ខ្ញុំមើលឃើញថា សហព្រះរាជអាជ្ញាបានខិតខំលើកយកការកាប់សម្លាប់គ្នាទៅវិញទៅមកក្នុងដំណាក់ធ្វើសង្គ្រាមមកភ្ជាប់ជាមួយព្រឹត្តិការណ៍កាប់សម្លាប់ក្រោយបញ្ចប់សង្គ្រាមភ្លាម ដើម្បីបង្ហាញអង្គជំនុំជម្រះថា នេះជាផែនការធ្វើឡើងជាប្រព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា។

ការភ្ជាប់ស្ថានភាពបែបនេះ មិនយុត្តិធម៌ទេ ដោយហេតុផលបើចាត់ទុកការកាប់សម្លាប់គ្នាក្នុងពេលធ្វើសង្គ្រាមថាជាផែនការធ្វើឡើងជាប្រព័ន្ធ ហេតុអ្វីមិនចោទប្រកាន់លើគូបដិបក្ខម្ខាងទៀតនៃសង្គ្រាមផងទៅ។ ជាការពិតណាស់បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផែនការធ្វើសង្គ្រាម ដើម្បីរំដោះពេលប្រទេសជាតិពីភាពអន្តរាយ។

[០៩:៥៣:១៦]

យុទ្ធសាស្ត្រប្រយុទ្ធសម្រាប់សត្រូវពិតជាត្រូវបានប្រើប្រាស់ដើម្បីទទួលជ័យជម្នះ។ ការធ្វើបែបនេះ ខ្ញុំគិតថាវាមិនមែនជាការខុសច្បាប់ទេ។ ប្រជាជននៃប្រទេសជាច្រើននៅលើពិភពលោកបានវាយប្រយុទ្ធគ្នាប្រឆាំងនឹងរដ្ឋាភិបាលរបស់ខ្លួន សម្រាប់បុព្វហេតុអ្វីមួយដែលគេគិតថា អ្វីដែលកើតឡើងមកលើពួកគេជាការមិនត្រឹមត្រូវ និងទាមទារឲ្យមានការផ្លាស់ប្តូរ។ ជាពិសេសការទាមទាមសិទ្ធិស្វ័យសម្រេចទៅលើជោគវាសនាប្រទេសជាតិខ្លួន។ ខ្ញុំសូមផ្តល់ឧទាហរណ៍ខ្លះៗដូចជា ប្រទេសស្រីលង្កា ប្រទេសស៊ីរី ប្រទេសលីប៊ី ប្រទេសវៀតណាម និងប្រទេសអ៊ីរ៉ាក់ ។ល។ ប្រទេសទាំងអស់នោះសុទ្ធតែធ្លាប់ប្រយុទ្ធគ្នា។ នៅពេលប្រយុទ្ធបែបនេះក្រុមមនុស្សទាំងនោះសុទ្ធសឹងតែមានផែនការ ដើម្បីកម្ទេចសត្រូវរបស់ខ្លួនទៅវិញទៅមក។ ប្រសិនបើតុលាការចាត់ទុកថាការធ្វើការផែនការប្រយុទ្ធនៅក្នុងពេលធ្វើសង្គ្រាមរបស់ពួក -- របស់ភាគីដើម្បីទទួលជ័យជម្នះជាចេតនាប្រព្រឹត្តបទល្មើស ដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់មែននោះ ម្ល៉េះសមមេដឹកនាំនៃប្រទេសទាំងអស់នោះ មិនថារដ្ឋាភិបាល ឬក្រុមប្រឆាំងទេ ត្រូវតែយកមកកាត់ទោសដូចគ្នា។ ជាពិសេសសហរដ្ឋអាមេរិក វៀតណាម រួមទាំងមេដឹកនាំខ្មែរដទៃទៀតផង។ កុំយកតែខ្លួនក្រពើមកកាត់ទោស តែក្បាល និងកន្ទុយទុកនៅដោយឡែករួចពីសំណាញ់ច្បាប់។ នេះជារឿងអយុត្តិធម៌ណាស់ចំពោះរូបខ្ញុំ។

[០៩:៥៥:១៧]

ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមញែកឲ្យដាច់ពីគ្នារវាងផែនការវីវរំដោះទឹកដី ទៅនឹងផែនការសម្លាប់មនុស្សនៅក្រោយសង្គ្រាម។ ចំណុចទាំងពីរនេះមានភាពខុសគ្នាស្រឡះ។ ផែនការប្រយុទ្ធគ្នានោះ ឬកម្ទេចសត្រូវត្រូវបានបញ្ចប់នៅពេលបញ្ចប់សង្គ្រាម។ ចំណែកចេតនាសម្លាប់មនុស្ស វាជាដំណាក់កាលថ្មីនៃអ្នកកាន់អំណាចនៅពេលដែលពួកគេបានទទួលមុខតំណែងក្នុងការគ្រប់គ្រងប្រទេស។

ម្យ៉ាងវិញទៀត ខ្ញុំចាំបានថាតុលាការនេះបានកំណត់វិសាលភាពនៃការកាត់ទោសចំពោះតែអំពើទាំងឡាយណាដែលកើតឡើងក្នុងចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ ប៉ុណ្ណោះ។ បើទោះជាខ្ញុំមិនចេះច្បាប់ក៏ដោយ ក៏ខ្ញុំយល់ថាការអះអាងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាអំពីសកម្មភាពរបស់ខ្ញុំនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពិតជាអំណះអំណាងខុសច្បាប់ និងគ្មានតម្លៃតាមផ្លូវច្បាប់។

ជារួមការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាពីអំពើហិង្សាបដិវត្តន៍នៅមុនថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ ដើម្បីធ្វើជាមូលដ្ឋានច្បាប់សម្រាប់បង្គ្រប់ធាតុផ្សំនៃបទល្មើសក្នុងគោលបំណងដាក់ទោសចំពោះរូបខ្ញុំនោះ គឺពិតជាមិនត្រឹមត្រូវទេ។ សូមលោក លោកស្រីចៅក្រមបដិសេធចោលចំពោះការអះអាងនេះ។

[០៩:៥៧:១៨]

<u>ខ.២) ការជម្លៀសប្រជាជន</u>

ដូចខ្ញុំបានជម្រាបជូនអង្គសវនាការរួចមកហើយ--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ សម្រាកបន្តិចលោកៗ នួន ជា! លោកៗ នួន ជាៗ សម្រាកបន្តិចសិន!

ម៉េចទៅលោកមេធាវី?

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ ខ្ញុំមេធាវី នួន ជា។ ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យគាត់សម្រាក១០ ឬ១៥នាទី ដូចរបាយការណ៍របស់ពេទ្យ ក្រោយពីគាត់អានមួយម៉ោងរួចមកហើយ គាត់ហាក់ដូចជាហត់ច្រើន ដើម្បីឲ្យបានការបន្តហ្នឹងបានចប់ដោយសម្រួល។ ហើយសូមអនុញ្ញាតឲ្យគាត់បាន១០ ឬ១៥នាទី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះក៏សមល្មមពេលសម្រាកផងដែរ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ សវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងសម្របសម្រួលនាំគាត់ទៅកន្លែងសម្រាកនៅពីក្រោយមេធាវី របស់គាត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ០៩:៥៨នាទី ដល់ម៉ោង ១០:១៨ នាទី)*

[១០:១៨:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅលោក នួន ជា ដើម្បីបន្តធ្វើសេចក្តីថ្លែងសេចក្តីសន្និដ្ឋានបិទបញ្ចប់នូវសេចក្តីសន្និដ្ឋានតបស្លាពររបស់ខ្លួន។

សូមអញ្ជើញ!

**លោក នួន ជា៖**

<u>ខ.២) ការជម្លៀសប្រជាជន</u>

ដូចខ្ញុំបានជម្រាបជូនអង្គសវនាការរួចមកហើយកាលពីប៉ុន្មានឆ្នាំមុននេះ ក្រោយថ្ងៃរំដោះថ្ងៃ១៧ មេសា ១៩៧៥ ប្រជាជនទាំងអស់ដែលបានរស់នៅក្នុងទីក្រុងនានា ត្រូវបានជម្លៀសចេញពីទីក្រុងពិត មែន តែការជម្លៀសនេះមិនមែនជាការជម្លៀសដោយបង្ខំនោះទេ។

[១០:១៩:៥៧]

មានហេតុផលពីរយ៉ាង ដែលថ្នាក់ដឹកនាំបានបង្ខំចិត្តខ្លួនឯងធ្វើសេចក្តីសម្រេចបែបនេះ។ ហេតុ ផលទី១ គឺដោយសារមានការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង ក្រោយ រដ្ឋាភិបាល លន់ នល់ បានទទួលបរាជ័យ។ ចំណុចនេះវាជាមូលហេតុដែលអាចធ្វើឲ្យថ្នាក់ដឹកនាំនិង

ប្រជាពលរដ្ឋខ្មែរជឿបានថា នឹងមានយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាជាថ្មីទៀតនៅតាមក្រុងនានា ជាពិសេសនៅទីក្រុងភ្នំពេញ។ ព្រោះសហរដ្ឋអាមេរិកធ្លាក់ទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជាជាច្រើនគោនកន្លងមកហើយ។ ហេតុផលទី២ គឺថាប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាងប្រាំឆ្នាំមកហើយ។ តាមរយៈសង្គ្រាមនេះប្រទេសកម្ពុជា បានជួបប្រទះបញ្ហាប្រឈមជាច្រើនរួមទាំងស្បៀងអាហារផងដែរ។ ករណីស្បៀងអាហារ វាជាបញ្ហាមួយសំខាន់ដែលត្រូវដោះស្រាយជាបន្ទាន់ ព្រោះវាទាក់ទងនឹងអាយុជីវិតរបស់ប្រជាជន។ នៅពេលនោះប្រទេសកម្ពុជាក៏មិនមានជំនួយពីបរទេសដែរ។ ស្ថិតក្នុងកាលៈទេសៈបន្ទាន់បែបនេះ បានជាថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំផែនការជម្លៀសប្រជាជនឲ្យទៅតាមតំបន់ និងខេត្តណាដែលមានធនធានសេដ្ឋកិច្ចស្រូវអង្ករអាចចិញ្ចឹមប្រជាជនបាន និងទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯងសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ និងកសាងប្រទេសជាតិ។

[១០:២២:៣៥]

ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គណៈអចិន្ត្រៃយ៍បានសម្រេចឲ្យមជ្ឈិមបក្សកោះប្រជុំដើម្បីរៀបចំផែនការជម្លៀស។ គ្រប់លេខាភូមិភាគដែលជាសមាជិកគណៈមជ្ឈិមបក្សបានចូលរួមកិច្ចប្រជុំនេះ។ ពេលនោះខ្ញុំចាំបានថា គ្រាន់តែភូមិភាគពាយ័ព្យបានធានាទទួលយកប្រជាជនចំនួន១,៥លាននាក់ ហើយភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគកណ្តាលបានធានាទទួលប្រជាជនដែលនៅសេសសល់។ ក្នុងផែនការនោះ គឺឲ្យភូមិភាគនីមួយៗមានស្វ័យភាពក្នុងការជួយសម្រួលគ្នាទៅវិញទៅមកទាក់ទងនឹងការជម្លៀសនេះ និងត្រូវណែនាំដល់សហករណ៍ឲ្យខិតខំដោះស្រាយជីវភាពប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយកុំឲ្យមានការរើសអើងចំពោះប្រជាជនទាំងនោះផងដែរ។

[១០:២៤:០១]

ទោះជាមានហេតុផលទាំងពីរនេះក្តី ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ គ្មានប្រើអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ។ ប្រការនេះត្រូវបានអនុវត្តតាមរយៈការពន្យល់ប្រជាជន ឲ្យបានយល់ដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង។ នៅពេលនោះ ប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និងតម្រូវការចាំបាច់របស់ប្រទេស

ជាតិជាពិសេសប្រជាជនបានគាំទ្រ និងស្រឡាញ់បដិវត្តន៍។ ដូច្នេះហើយប្រជាជនបានចាកចេញពីទីក្រុងជាបណ្តើរៗតាមការអំពាវនាវ និងការពន្យល់របស់បក្សកុម្មុយនីស្តកម្ពុជា។

ទាក់ទងនឹងចំណុចនេះ ខ្ញុំសូមបំភ្លឺចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ លោក លោកស្រីសហព្រះរាជអាជ្ញាបានចោទប្រកាន់ចំពោះការហ៊ុមព័ទ្ធទីក្រុងភ្នំពេញ ដែលបណ្តាលឱ្យមានវិបត្តិស្បៀងអាហារ និងការបាញ់ផ្លោងចូលក្នុងទីក្រុង ទីតាំងជាមូលដ្ឋានបង្អែករបស់ លន់ នល់ ក្នុងទីក្រុងភ្នំពេញដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាថា នេះជាអំពើអមនុស្សធម៌។

ចុះសហព្រះរាជអាជ្ញាធ្លាប់បានគិតទេថា ពួកលន់នល់ បានបាញ់ផ្លោងដោយកាំភ្លើងធំដែលសហរដ្ឋអាមេរិកផ្តល់ឱ្យអស់រាប់លានគ្រាប់ និងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកច្រើនជាងកន្លះលានតោន។ បំផ្លាញផ្ទះសម្បែង វត្តអារាម ទ្រព្យសម្បត្តិ សាលា ចម្ការ សត្វពាហនៈរបស់ប្រជាជន។ ជាពិសេសបណ្តាលឱ្យស្លាប់មនុស្សរាប់សិបម៉ឺននាក់ មានទាំងចាស់ៗជរា ទាំងកុមារ ទាំងស្ត្រីភេទ តើនេះមិនមែនជាអំពើអមនុស្សធម៌ ឬជាឧក្រិដ្ឋកម្មទេឬ?

[១០:២៦:៥១]

គ្រាប់បែករបស់សហរដ្ឋអាមេរិក ដែលបានទម្លាក់មកលើប្រទេសកម្ពុជាមានចំនួនច្រើនជាងបីដងនៃគ្រាប់បែក ដែលសហរដ្ឋអាមេរិកបានទម្លាក់លើប្រទេសជប៉ុនក្នុងសង្គ្រាមលោកលើកទី២។

លើសពីនេះបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកប្រជាជន ដែលរស់នៅក្នុងទីក្រុងភ្នំពេញ -- (អត់ទោស) លើសពីនេះបក្សកុម្មុយនីស្តកម្ពុជាមិនបានចាត់ទុកប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញជាខ្មាំងដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ។ ផ្ទុយទៅវិញ ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញទាំងនេះភាគច្រើនជាកម្មករ កសិករ អនុធន បញ្ញាជន និងបុគ្គលស្នេហាជាតិ ដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវប្រមូល និងចាត់ទុកជាកម្លាំងមួយដ៏សំខាន់ ដើម្បីចូលរួមធ្វើបដិវត្តន៍។

ចំពោះករណីដែលលោក លោកស្រីសហព្រះរាជអាជ្ញា លើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យជារដ្ឋទាសករ នេះវាជារឿងមួយមិនអាចទទួលយកបានទេ។ ខ្ញុំសូមបញ្ជាក់ជូនបងប្អូនជនរួមជាតិថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនតស៊ូ រំដោះប្រទេសកម្ពុជាក្នុងគោលបំណងដាក់ប្រជាជនកម្ពុជាជាទាសករដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ។ ផ្ទុយទៅវិញ បក្សកុម្មុយនីស្តកម្ពុជាបានរំដោះប្រជាជនកម្ពុជាពីទាសភាព។ យើងទាំងអស់គ្នាគួរតែបានដឹងរួចមកហើយថា នៅមុនថ្ងៃរំដោះ ១៧ មេសា ឆ្នាំ ១៩៧៥ ប្រជាកសិករកម្ពុជាភាគច្រើនមានភាពក្រីក្រ ខ្វះមុខខ្វះក្រោយ និងជួបប្រទះការលំបាកយ៉ាង

ខ្លាំងនៅក្នុងជីវភាពរស់នៅរបស់ពួកគេ។ រដ្ឋអំណាច លន់ នល់ មិនបានផ្តល់សេវាសាធារណៈ និងគិតគូរពីសុខុមាលភាពសង្គមដល់ប្រជាជនក្រីក្រនោះទេ។ អំពើពុករលួយ និងភាពអយុត្តិធម៌បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា។ ដោយសារហេតុផលនេះប្រជាកសិករកាន់តែក្រទៅៗ ពួកគាត់តែងតែខ្ចីបុលពីនាយទុន ដើម្បីទ្រទ្រង់ជីវភាព ព្យាបាលជំងឺ ឬបង់ពន្ធដារ។ នៅពេលនោះហើយ ពួកនាយទុនបានឆ្លៀតពេលដែលប្រជាជនមានទុក្ខលំបាកបានធ្វើទុក្ខបុកម្នេញ និងទារការប្រាក់គាត់តាមទំនើងចិត្តរហូតដល់យកការប្រាក់ចំនួន៥០ភាគរយក្នុងមួយខែក៏មាន។ ដោយការប្រាក់ហួសហេតុ នាំឲ្យប្រជាជនទាំងនោះគ្មានលទ្ធភាពសងបំណុល ហើយត្រូវបានម្ចាស់បំណុលរឹបអូសយកដីស្រែ ចម្ការ និងផ្ទះសម្បែងអស់។ នៅពេលអស់ដីស្រែចម្ការ និងផ្ទះសម្បែង ប្រជាជនទាំងនោះត្រូវបង្ខំចិត្តស៊ីឈ្នួលគេ ឬត្រូវបានចាប់បង្ខំឲ្យធ្វើជាខ្ញុំកញ្ជះគេ ដើម្បីកាត់បំណុលដែលសងមិនចេះអស់នេះ។ មានករណីជាច្រើនដែលពួកគាត់ត្រូវបង្ខំ ចិត្តលក់កូនឲ្យធ្វើជាខ្ញុំគេ តកូនតចៅ រើខ្លួនមិនរួច។ ហើយក្លាយជាទាសកររបស់គេដោយលក់កម្លាំង ដូរបាយតែមួយចម្អែតក្រពះប៉ុណ្ណោះ។

[១០:៣១:០៩]

ការកេងប្រវ័ញ្ច និងភាពក្រក្រីរកទីបំផុតគ្មានរបស់ប្រជាកសិករនេះ ជាបុព្វហេតុមួយក្នុងបុព្វហេតុជាច្រើនទៀត ដែលបក្សកុម្មុយនីស្តកម្ពុជារំដោះប្រទេសជាតិ និងប្រជាជនចេញពីទាសភាព។ ការកេងប្រវ័ញ្ច ការជិះជាន់ និងការឈ្លានពានរបស់បរទេស ដោយកសាងកម្ពុជាមួយដែលប្រជាជនរស់នៅដោយស្មើភាព និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដ ក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង។ គ្មានគោលនយោបាយ ឬផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាណាមួយដែលកំណត់ឲ្យដាក់ប្រជាជនជាទាសករ តាមរយៈការបង្អត់អាហារ ការបង្ខំឲ្យធ្វើការ ឬការសម្លាប់ឡើយ។

ផ្ទុយទៅវិញ នៅពាក់កណ្តាលឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំ និងអនុម័តគម្រោងផែនការបួនឆ្នាំ សម្រាប់កសាងសង្គមនិយមគ្រប់ផ្នែក។ មាគ៌ា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនកម្ពុជា។ ផែនការនេះបានកំណត់ថារបបអាហាររបស់ប្រជាជនម្នាក់ៗចំនួន១៣ថាំង ឬជប់ -- ៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ។ ដូច្នេះប្រជាជនហូបគ្រប់គ្រាន់សម្រាប់ពីបីពេលទៅបួនពេលក្នុងមួយថ្ងៃ។ ចំពោះម្ហូប គឺពីរមុខ មានសម្លទឹកនិងសម្លគោក។ លើសពីនេះបានសម្រេចបន្ថែមលើរបបអាហារ នូវចំណី និងបង្អែមផ្សេងៗ ដោយផ្តល់

ឲ្យបីថ្ងៃម្តងក្នុងឆ្នាំ១៩៧៧។ ពីរថ្ងៃម្តងក្នុងឆ្នាំ១៩៧៨ ហើយមួយថ្ងៃម្តង ចាប់ពីឆ្នាំ១៩៧៩ តទៅ។

[១០:៣៣:៤៤]

ចំពោះការងារវិញ គឺឲ្យប្រជាជនធ្វើការប្រាំបីម៉ោងក្នុងមួយថ្ងៃ និងឲ្យឈប់សម្រាក៣ថ្ងៃក្នុងមួយខែ។ នារីមានផ្ទៃពោះ និងឆ្លងទន្លេឲ្យឈប់សម្រាកពីរខែ អ្នកជំងឺឲ្យឈប់សម្រាកតាមជាក់ស្តែង។ លើសពីនេះ យើងបានរៀបចំបង្កើនគ្រឿងចក្រឲ្យកាន់តែច្រើន សម្រាប់សម្រាលទម្ងន់ការងារដោយកម្លាំងកាយផ្ទាល់របស់ប្រជាជន។ នេះបង្ហាញថា គោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជាមិនបានបង្ខំឲ្យប្រជាជនធ្វើការយ៉ាងធ្ងន់ធ្ងរនោះឡើយ។ ខ្ញុំនៅចាំបានថា មានថ្ងៃមួយខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តសៀមរាបកាត់តាមខេត្តកំពង់ធំនៅពេលយប់។ ខ្ញុំបានឃើញប្រជាជនដើរទៅកាន់វាលស្រែ។ ពេលខ្ញុំសួរកម្មាភិបាលគ្រប់គ្រងមូលដ្ឋាននោះ គេឆ្លើយប្រាប់ខ្ញុំថា ប្រជាជនមានស្មារតីប្តេជ្ញាចិត្តខ្ពស់ ស្ម័គ្រចិត្តធ្វើការបន្ថែម។ ក្រោយឆ្នាំ១៩៧៩ ទើបខ្ញុំដឹងច្បាស់ថា កម្មាភិបាលមូលដ្ឋាននោះបានកុហកខ្ញុំ។

លើសពីនេះយើងបានគ្រោងការចំណាយសម្រាប់ថ្នាំពេទ្យរយៈពេលបួយឆ្នាំ សរុប៣៥.២៧០.០០០ដុល្លារ។ សម្រាប់សម្លៀកបំពាក់រយៈពេលបួនឆ្នាំ សរុប៦៦.២៧០.០០០ដុល្លារ។ សម្រាប់ផ្ទះសម្បែង អនាម័យ វប្បធម៌ រយៈពេលបួនឆ្នាំ សរុប៨០.២៣០.០០០ដុល្លារ។ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ចេញនូវផែនការនេះយ៉ាងជាក់លាក់ និងច្បាស់លាស់សម្រាប់ឲ្យភូមិភាគ និងតំបន់ស្វយ័តនីមួយៗអនុវត្ត។

[១០:៣៥:៥៧]

ចំពោះការកាប់សម្លាប់ប្រជាជនក៏មិនមែនជាផែនការ ឬគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ។ បក្សកុម្មុយនីស្តកម្ពុជាមានផែនការបង្កើនចំនួនប្រជាជន មិនមែនកាត់បន្ថយចំនួនប្រជាជននោះឡើយ។ ប៉ុន្តែគួរឲ្យសោកស្តាយដែលភូមិភាគ និងតំបន់ស្វយ័តខ្លះមិនបានអនុវត្តតាមការសម្រេចរបស់គណៈអចិន្ត្រៃយ៍។

មកដល់ពេលនេះ ខ្ញុំអាចសរុប និងឆ្លើយតប និងចម្ងល់របស់តុលាការ និងជាពិសេសជនរួមជាតិរបស់ខ្ញុំឲ្យបានជ្រាបថា វិនាសកម្មដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមូលហេតុដូចខាងក្រោម៖

ទី១) អ្នកដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាជ្រើសរើសកម្មាភិបាលមួយចំនួនខុស ដោយអ្នកខ្លះក្បត់ អ្នកខ្លះក្តាប់មិនបានពីមាគ៌ារបស់បក្ស ហើយអ្នកដឹកនាំរវល់តែកិច្ចការនៅទីក្រុងភ្នំពេញមិនសូវបាន

ចុះតាមសហករណ៍ឲ្យបានជាប់លាប់។

ទី២) មានមេដឹកនាំភូមិភាគ តំបន់ស្វយ័ត និងកម្មាភិបាលមួយចំនួនជាភ្នាក់ងារបង្កប់របស់វៀតណាម និងអាមេរិកដែលក្បត់បដិវត្តន៍។ ពួកគេបានធ្វើសកម្មភាពបំផ្លិចបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជា និងប្រទេសកម្ពុជា។ ពួកគេមិនបានធ្វើតាមផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ បែរជានាំគ្នាកាប់សម្លាប់ និងធ្វើបាបប្រជាជនដោយការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំងតាមទំនើងចិត្តរបស់ខ្លួន ហើយលាក់បាំង និងរាយការណ៍ភូតកុហកមកមជ្ឈិមបក្ស។ ពួកគេធ្វើគ្រប់វិធីដើម្បីឲ្យប្រជាជនមានសតិអារម្មណ៍ថ្នាំងថ្នាក់ងាកមកប្រឆាំងបដិវត្តន៍ បណ្ដាលឲ្យបក្សកុម្មុយនីស្តកម្ពុជាចុះខ្សោយ ហើយសត្រូវបរទេសយកលេសថាមករំដោះប្រជាជនកម្ពុជា ដើម្បីឲ្យការឈ្លានពានរបស់គេក្លាយជាអំពើស្របច្បាប់។

ជាក់ស្ដែងមេភូមិភាគបូព៌ាបានបង្អត់បាយប្រជាជន តែបែរជាលួចដឹកស្រូវចេញទៅប្រទេសវៀតណាមទៅវិញ។ ក្រុមនេះអាចចាត់ទុកថាជាពួកដុតឲ្យខ្លោចរោចឲ្យឆៅ។ ពួកដុតឲ្យខ្លោច គឺពួកធ្វើឲ្យលើសហួសហេតុពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ពួករោចឲ្យឆៅ គឺពួកគេមិនធ្វើអ្វី ទាំងអស់ មិនខ្វល់អ្វីទាំងអស់ ហើយកម្មាភិបាលថ្នាក់ក្រោមធ្វើតាមអំពើចិត្ត។

[១០:៣៩:១៣]

ទី៣) មានកម្មាភិបាលភូមិភាគ តំបន់ស្វយ័ត ស្រុក និងសហករណ៍មួយចំនួនធំគ្លាប់មិនបានពីមាគ៌ា ផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្រុមនេះមិនបានរាយការណ៍ពីការលំបាក និងការខ្វះខាតរបស់ប្រជាជន ឬបើបានជារាយការណ៍វិញ គេរាយការណ៍បំភ្លើសពីភាពជោគជ័យក្នុងការដឹកនាំមូលដ្ឋានរបស់ខ្លួនមកមជ្ឈិមបក្សជាថ្នូរនឹងស្នាដៃ ដើម្បីឲ្យបានសម្រេចដូចរបាយការណ៍។ ពួកគេបានបង្ខិតបង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំង កាត់បន្ថយរបបអាហារ និងកាប់សម្លាប់តាមតែចិត្តរបស់ខ្លួន។

សរុបមកបក្សកុម្មុយនីស្តកម្ពុជាមានហេតុផលច្បាស់លាស់ចំពោះការជម្លៀសប្រជាជន ក្នុងគោលដៅដើម្បីធានាសុវត្ថិភាពរបស់ប្រជាជន និងរំដោះប្រជាជនចេញពីទាសភាព និងអំពីអយុត្តិធម៌។ វាមិនមែនជាការដាក់ប្រជាជនជាទាសករនោះទេ។

<u>គ) ភាពយុត្តិធម៌នៅពេលកាត់សេចក្ដីនេះ</u>

គោរពតុលាការ! តាមការសង្កេតរបស់ខ្ញុំនៅក្នុងសវនាការនេះ សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ខ្ញុំ

ត្រូវបានរំលោភបំពាន។ តាមពិតទៅ ខ្ញុំមិនគួរនិយាយថាការកាត់សេចក្តីនេះមានភាពអយុត្តិធម៌នោះទេ ពីព្រោះខ្ញុំកំពុងតែសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំ។ ប្រសិនបើចៅក្រមខឹងខ្ញុំ ដោយសារតែខ្ញុំរិះគន់នោះ ភាពអយុត្តិធម៌ពិតជាកើតមានឡើងចំពោះខ្ញុំជាមិនខាន។ តែបើខ្ញុំមិននិយាយអំពីការរំលោភបំពានទាំងអស់នោះទេ ឱកាសនៃការរកយុត្តិធម៌ឲ្យខ្ញុំនោះ វារឹតតែគ្មានទាល់តែសោះ ពីព្រោះសិទ្ធិទាំងអស់នោះជាមូលដ្ឋានគ្រឹះនៃការរកយុត្តិធម៌ឲ្យខ្ញុំ។

ទាក់ទងនឹងករណីនេះ ខ្ញុំបានតាមដាន និងសង្កេតដោយយកចិត្តទុកដាក់បំផុត ហើយឃើញថាមានសិទ្ធិច្រើនណាស់ត្រូវបានរំលោភបំពាន។

[១០:៤១:៤៣]

ក) ភាពមិនស្មើគ្នានៃប្រមូលភស្តុតាង

នៅពេលដំណើរការរឿងក្តី មេធាវីរបស់ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យចុះស៊ើបអង្កេតដើម្បីប្រមូលភស្តុតាងយកមកការពារខ្ញុំនោះទេ។ ចំណែកសហព្រះរាជអាជ្ញាវិញមានឱកាសគ្រប់គ្រាន់ក្នុងការស៊ើបអង្កេត សួរសាក្សីតាំងពីដំបូង។ ចំពោះមេធាវីការពារខ្ញុំវិញ មិនត្រូវបានអនុញ្ញាតឲ្យស្វែងរកសាក្សីផ្សេងក្រៅអំពីបញ្ជីសាក្សីដែលចៅក្រមស៊ើបអង្កេតផ្តល់ឲ្យនោះទេ។

ការធ្វើបែបនេះវាហាក់ដូចជាចងដៃមេធាវី និងកម្រិតសិទ្ធិមេធាវីរបស់ខ្ញុំក្នុងការប្រមូលភស្តុតាងមកការពារខ្ញុំ ហើយផ្តល់ឱកាសឲ្យភាគីម្ខាងទៀតវ៉ៃខ្ញុំតាមចិត្ត។ នេះធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការការពាររបស់មេធាវី និងផលប្រយោជន៍ស្របច្បាប់ខ្ញុំ។

២) មិនបានកោះហៅសាក្សីសំខាន់មកបំភ្លឺនៅចំពោះមុខតុលាការ

ករណីនេះ មេធាវីរបស់ខ្ញុំបានស្នើសុំជាច្រើនដងឲ្យតុលាការកោះហៅសាក្សីសំខាន់ៗមួយចំនួនឲ្យចូលមកបំភ្លឺនៅចំពោះមុខតុលាការ ដូចជាសាក្សីអត្តចរិត និងសាក្សីទាក់ទងនឹងការសម្លាប់ទាហានលន់ នល់ នៅទួលពោធិ៍ជ្រៃ តែតុលាការបានបដិសេធ។ ការសម្រេចនេះបានធ្វើឲ្យប៉ះពាល់ដល់ការស្វែងរកការពិត និងត្រឹមត្រូវចំពោះរឿងក្តី។

[១០:៤៣:៣៧]

៣) មានភាពលម្អៀងក្នុងការសួរសាក្សីនៅចំពោះមុខតុលាការ

ការសួរសាក្សីជាផ្នែកមួយដ៏សំខាន់សម្រាប់ស្វែងរកការពិត និងភាពមិនច្បាស់លាស់របស់សាក្សី។ ផ្អែកលើលទ្ធផលនៃសក្ខីកម្មនេះ ចៅក្រមអាចសម្រេចសេចក្តីប្រកបដោយយុត្តិធម៌។ ចំពោះសវនាការ

នេះខ្ញុំមើលឃើញថា ចៅក្រមមិនបានពិចារណាឲ្យបានដិតដល់អំពីបញ្ហានេះទេ។ នៅពេលព្រះរាជអាជ្ញាសួរសាក្សី ចៅក្រមតែងតែផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាសួររហូត។ កម្រនឹងមានការរំខានណាស់ បើទោះមានការជំទាស់ពីមេធាវីការពារក៏ដោយ។ ចំណែកមេធាវីការពារវិញមិនមានឱកាសដូចនេះទេ។ មេធាវីការពារត្រូវបានរំខានគ្រប់ពេលវេលាតាមការជំទាស់របស់សហព្រះរាជអាជ្ញា ហើយចៅក្រមតែងតែផ្តល់ឲ្យព្រះរាជអាជ្ញាធ្វើបែបនេះ។ មានពេលខ្លះនៅពេលមេធាវីការពារធ្វើការតវ៉ា ក៏មានការព្រមានពីប្រធានសវនាការជាដើម។

ដោយមើលឃើញភាពអយុត្តិធម៌បែបនេះ ទាំងរូបខ្ញុំក៏ដូចជាលោក ខៀវ សំផន បានសម្រេចចិត្តឈប់ផ្តល់សក្ខីកម្មជូនតុលាការ។ ពីព្រោះយើងយល់ថា បើទោះជាយើងផ្តល់ចម្លើយជូនចៅក្រម ក៏វាមិនមានន័យអ្វីដែរ ដោយហេតុថាចៅក្រមមានភាពលម្អៀង ហើយអ្វីដែលអនុវត្តនៅចំពោះមុខតុលាការនោះ វាគ្រាន់តែជាការបង្គ្រប់នីតិវិធី ឬបំពេញទម្រង់ឲ្យល្អមើលតែប៉ុណ្ណោះ។

[១០:៤៥:៤២]

សរុបសេចក្តីមក ដោយផ្អែកលើមូលដ្ឋានទាំងបីដែលខ្ញុំបានបញ្ជាក់ជូនខាងលើនេះ វាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ខ្ញុំមិនបានធ្វើផែនការប្រព្រឹត្តបទល្មើស។ ខ្ញុំមិនបានជួយឧបត្ថម្ភ ឬលើកទឹកចិត្តឲ្យជនណាម្នាក់ប្រព្រឹត្តបទល្មើស។ បើទោះជាខ្ញុំមានតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា ខ្ញុំមិនបានដឹងអំពីការប្រព្រឹត្តិបទល្មើសនៅតាមមូលដ្ឋាននោះទេ។ ទើបតែនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបខ្ញុំបានដឹងអំពីអំពើក្បត់របស់មេដឹកនាំនៅតាមភូមិភាគ តំបន់ និងនៅតាមមូលដ្ឋានខ្លះ ដែលមានបំណងបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា។ ហើយនៅពេលនោះខ្ញុំពិតជាគ្មានអំណាចក្នុងការទប់ស្កាត់អំពើក្បត់ទាំងនោះបានឡើយ ពីព្រោះខ្ញុំពុំមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំងយោធា ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ។ ប្រសិនបើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំពិតជាមានអំណាចដឹកនាំ ឬបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នៅពេលនេះប្រាកដជាតុលាការដែលបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៩ (*ស៊ឺក*) ពិតជាកាត់ទោសខ្ញុំដូច ប៉ុល ពត និង អៀង សារី ទៅហើយ។ ពីព្រោះពេលនោះ គឺភស្តុតាងនៃឧក្រិដ្ឋកម្មនៅបន្សល់ទុកនៅថ្មីៗនៅឡើយ មិនបាច់រង់ចាំពេល៣៤ឆ្នាំ ដើម្បីកាត់ទោសខ្ញុំទេ។ តែដោយសារដឹងថាខ្ញុំគ្មានអំណាចអ្វី និងមិនបានប្រព្រឹត្ត។

[១០:៤៧:៤៦]

ទោះបីជាយ៉ាងណា ខ្ញុំនៅតែសម្ដែងនូវការសោកស្ដាយជាទីបំផុត និងសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរងគ្រោះទាំងអស់ និងប្រជាជនកម្ពុជាទាំងមូលដែលបានទទួលរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ជាការពិតសម្រាប់ប្រវត្តិសាស្ត្រ ទាំងគោលនយោបាយ ទាំងមាគ៌ា និងទាំងផែនការរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងក្នុងគោលបំណងតែមួយគត់ គឺរំដោះប្រទេសជាតិ និងប្រជាជនឲ្យរួចផុតពីអាណានិគមនិយម ចក្រពត្តិនិយម និងការជិះជាន់កេងប្រវ័ញ្ច ភាពក្រីក្ររកទីបំផុតគ្មាន ការជ្រៀតជ្រែក និងការឈ្លានពានពីប្រទេសជិតខាង ពិសេសពីប្រទេសវៀតណាម។ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយជាក់លាក់ គ្មានការភូតភរគឺកសាងប្រទេសមួយស្មើភាពគ្នា និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដ ក្នុងគោលជំហាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង។

ចលនាបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើងមិនមែនដើម្បីកាប់សម្លាប់ប្រជាជន និងបំផ្លាញប្រទេសជាតិនោះឡើយ។ ខ្ញុំពិតជាមានការសោកស្ដាយចំពោះការលះបង់សឹងតែមួយជីវិតរបស់ខ្ញុំក្នុងបក្សកុម្មុយនីស្តកម្ពុជា។ មនសិការរបស់ខ្ញុំ សេចក្ដីសង្ឃឹមរបស់ខ្ញុំ និងសេចក្ដីប្រាថ្នារបស់ខ្ញុំត្រូវបានបំផ្លាញដោយពួកក្បត់ចលនា ដែលធ្វើឲ្យប្រជាជនរបស់ខ្ញុំត្រូវបានកាប់សម្លាប់ និងរងទុក្ខវេទនា ប្រទេសជាតិរបស់ខ្ញុំត្រូវបែកបាក់។

[១០:៤៩:៤៩]

ទោះបីជាសោកវិនាសកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បង្កឡើងដោយជនក្បត់ចលនាក៏ដោយក៏ក្នុងនាមខ្ញុំជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ដែលមានភារកិច្ចឃោសនាអប់រំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមសូមទោសជាសាធារណៈចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូល។ ហើយខ្ញុំនៅតែប្រកាន់ជំហរទទួលខុសត្រូវលើផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានដិតដល់ និងមិនបានគ្រប់ជ្រុងជ្រោយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនដែលរងគ្រោះដោយគ្រប់យថាហេតុទាំងអស់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

សរុបឲ្យខ្លីតាមពន្លឺនៃសវនាការនេះ ខ្ញុំឃើញច្បាស់ថាយុត្តិធម៌អាចប្រែប្រួលទៅតាមកាលៈទេសៈតែសច្ចធម៌ជាអមតធម៌មិនប្រែប្រួលជាដាច់ខាត។ ពពកខ្មៅមិនអាចបិទបាំងពន្លឺព្រះអាទិត្យបានទេ។ យ៉ាងណាមិញមនុស្សអគតិ អសីលធម៌ មិនអាចភូតភរកុហក និងបិទបាំងភ្នែកប្រជាជន និងមហាជន

មិនឲ្យមើលឃើញនូវសច្ចធម៌នៃការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា និងការឧបត្ថម្ភគាំទ្ររបស់ប្រជាជនស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោកបានឡើយ។

អាស្រ័យហេតុនេះ ដោយផ្អែកលើភស្តុតាង និងហេតុផលទាំងអស់ខាងលើនេះ និងជាពិសេសសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំ ខ្ញុំសំណូមពរតុលាការមេត្តាសម្រេចឲ្យខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងសំណុំរឿងនេះ និងសូមដោះលែងខ្ញុំឲ្យមានសេរីភាពវិញទៅតាមផ្លូវច្បាប់។ សូមអរគុណ។ សូមអស់សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅអង្គុយនៅពីក្រោយមេធាវីរបស់គាត់។

*(ជនជាប់ចោទចាកចេញពីឈើរាំងវង់ក្រចកសេះ)*

[១០:៥២:៥១]

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានតបស្លាពរចុងក្រោយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តី សហព្រះរាជអាជ្ញា ហើយនិងភាគីទាំងអស់ សាធារណជន។

លោកប្រធានពីម្សិលមិញនេះ ខ្ញុំបានចង្អុលបង្ហាញថា ខ្ញុំនឹងនិយាយ៣០នាទី។ ប៉ុន្តែបានស្តាប់ក្រោយមកថា មេធាវីរបស់លោក ខៀវ សំផន និងប្រើពេលតែមួយម៉ោងដែលចែកជូនឲ្យគាត់ទេ។ ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះអាចនឹងអនុញ្ញាតឲ្យខ្ញុំប្រើពេលប្រហែលជា ១៥នាទី ឬក៏លើសពីហ្នឹងបន្ថែមនៅក្នុងការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាដែលបានធ្វើកាលពីម្សិលមិញនោះ។

ឥឡូវនេះ ខ្ញុំសូមអនុញ្ញានឹងនិយាយដោយសង្ខេបដែលអាចធ្វើទៅបាន ហើយនិងព្យាយាមឆ្លើយដោយផ្ទាល់ទៅនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ហើយនិងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហើយជាទូទៅខ្ញុំនឹងលើកឡើងអំពីទឡ្ហីករណ៍ដែលភាគីមេធាវី សហព្រះរាជអាជ្ញាបានធ្វើឡើង។ ហើយខ្ញុំអាចនឹងលើកឡើងត្រឡប់ចុះ គឺថាទាក់ទងទៅនឹងលំដាប់លំដោយដែលត្រូវឆ្លើយតប។

លោក លោកស្រីចៅក្រម ខ្ញុំនឹងចាប់ផ្តើមទាក់ទងទៅនឹងយោបល់ដែលធ្វើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្សិលមិញ។ ការសង្កេតទី១ គឺទាក់ទងទៅនឹងការគ្រាប់តាមរបស់ដើមបណ្តឹងរដ្ឋប្ប

វេណី ឃ្លារបស់សហព្រះរាជអាជ្ញាដែលហៅថា “រដ្ឋទាសករ”។

[១០:៥៤:៥៤]

យើងបានឃើញបានឃើញឃ្លានេះជាច្រើនដងហើយ ស្តាប់ជាច្រើនដងហើយ ដូចជាការឃុទ្ធនាការផ្សាយពាណិជ្ជកម្មដូច្នេះដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាបានបំភ្លឺមកបញ្ចាំងមុខយើងដូចជាភ្លើងណេអុងដូច្នោះដែរ។ ហើយការប៉ុនប៉ងរបស់គាត់ គឺចង់អះអាងថា ការធ្វើបែបនេះឆ្លុះបញ្ចាំងពីគោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចដែលយើងខ្ញុំបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់របស់យើង ការប្រើពាក្យនៅឃ្លានេះជាពាក្យស្លោកថា “រដ្ឋទាសករ” នោះមិនត្រឹមត្រូវទេ ហើយធ្វើឲ្យមានការភ័ន្តច្រឡំនោះដែរ។ គឺមិនត្រឹមតែជាការហៅមិនត្រឹមត្រូវ ដើម្បីរៀបរាប់ការងាររបស់បក្សកុម្មុយនីស្តកម្ពុជាទេ ប៉ុន្តែក៏មិនបានផ្អែកទៅភស្តុតាងដែលស្ថិតនៅក្នុងបញ្ហាត្រូវពិភាក្សានៅចំពោះតុលាការដែរ។

តើមានន័យដូចម្តេចនៅពេលដែលខ្ញុំនិយាយថា មិនមែនជាបញ្ហារបស់តុលាការនេះ។ ហើយខ្ញុំចង់និយាយថា អ្វីដែលយើងនិយាយនោះ គឺមូលដ្ឋាននៅក្នុងចម្លើយរបស់សាក្សី និងភស្តុតាងទាំងអស់នោះ គឺស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តី០០២/០១។

[១០:៥៦:០៧]

នៅក្នុងការជំនុំជម្រះ ហើយយើងទាំងអស់គ្នាបានដឹងច្បាស់ហើយ គឺទាក់ទងអំពីការជម្លៀសប្រជាជនពីរដំណាក់កាល ហើយនិងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ សហករណ៍ ហើយនិងលក្ខខណ្ឌទាក់ទងទៅនឹងសហករណ៍ហ្នឹង គឺមិនមែនជាផ្នែកនៃសវនាការនេះទេ។ ទោះជាដូច្នេះក៏ដោយ សហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមដាក់បញ្ចូលចម្លើយសារភាពសាក្សីតាមទ្វារក្រោយដែលរំឭកពីលក្ខខណ្ឌសហករណ៍ ដើម្បីបង្ហាញពីបុគ្គលមួយចំនួនដែលថាត្រូវបានគេចាត់ទុកដូចជាទាសករ។ ដោយខកខានមិនបានប្រើឃ្លានេះនៅក្នុងសារណារបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដើរតាមសហព្រះរាជអាជ្ញាទាំងងងឹត ហើយក៏បានប្រើពាក្យនេះដូចគ្នា។

លោក លោកស្រីចៅក្រម គឺយើងមិនអាចនិយាយអ្វីឲ្យច្បាស់ជាងនេះបាននោះទេ គឺសាក្សីទាំងអស់ ហើយចម្លើយរបស់គេដែលលើកឡើងថា បុគ្គលនៅសហករណ៍ត្រូវបានគេដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពជាទាសករនោះគឺ ជាការអះអាងក្រៅពីវិសាលភាពនៃរឿងក្តី០០២/០១។ ហើយយើងមិនមានលទ្ធភាព ដើម្បីពិនិត្យពួកគេ ហើយមិនបានធ្វើតេស្តអំពីភាពជឿជាក់ ហើយនិងការទុកចិត្តរបស់គេទេ។

[១០:៥៧:២៤]

ទាំងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្រឹងប្រែងបង្ហាញថា តើចម្លើយទាំងអស់នោះផ្អែកទាំងស្រុងទៅលើការសង្កេតពីលក្ខខណ្ឌរបស់សាក្សីនោះទេ។ ហើយការធ្វើបែបនេះគឺមិនតំណាងពីគំរូរួមរបស់អ្វីដែលកើតឡើងនៅក្នុងប្រទេសនោះទេ ដោយប្រើពាក្យស្លោកថា "រដ្ឋទាសករ"។ ហើយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ថាយើងបានទទួលចំណែកនេះ ហើយយើងត្រូវតែទទួលយកដូច្នេះទៅ។ ហើយពួកគាត់ក៏បានបញ្ជាក់អំពីគំនិតនេះ បញ្ជាក់ថា -- ប៉ុន្តែមិនបានយកភស្តុតាងមកដាក់ឲ្យដេញដោល និងតវ៉ាគ្នានោះទេ។ ដោយសារផ្អែកលើភស្តុតាង វាមិនមែនជាផ្នែកនៃសវនាការនេះទេ ហើយភាពពាក់ព័ន្ធ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

សម្រាកៗតិចសិន លោក នួន ជា មានបញ្ហាអី? សូមអញ្ជើញលោក នួន ជា!

សូមអញ្ជើញលោក នួន ជា ចង់ត្រឡប់ទៅក្រោមវិញ?

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ត្រឡប់ទៅកាន់បន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការចុះ!

អញ្ជើញលោកមេធាវី កូប៉េ បន្តសេចក្តីសន្និដ្ឋានរបស់ខ្លួន!

[១០:៥៨:៥៣]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ដូចដែលខ្ញុំបានបញ្ជាក់ពីខាងដើមការប្រើពាក្យថា "រដ្ឋទាសករ" នេះសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី គឺព្យាយាមថាចង់ប្រើពាក្យនេះ ហើយនិងយល់ន័យដូចគ្នា។ អ្វីដែលគេលើកឡើងនេះគឺថាជាការអះអាងដើម្បីធ្វើម៉េចឲ្យទ្រឹស្តីរបស់ខ្លួន ហើយធ្វើម៉េចថាឲ្យតុលាការជឿថាជាការពិត។ ដោយសារយើងផ្អែកលើភស្តុតាង ចំណុចនេះមិនជាផ្នែកនៃសវនាការទេ ហើយគ្មានភាពពាក់ព័ន្ធ ហើយគ្មានខ្លឹមសារដែលនឹងត្រូវលើកមកទេ។ ហើយតាមពិត មេធាវីការពារក្តីខ្លួនឯងបានស្នើដាក់ភស្តុតាងដាក់បញ្ចូលទៅសវនាការ ប៉ុន្តែសហព្រះរាជអាជ្ញាបានជំទាស់។ មានន័យថា គេមិនចង់លើកឡើងពីការចោទប្រកាន់នេះទេ ដោយមានការភ័យខ្លាចអំពីថា ខ្លួនខ្សោយក្នុងចំណុចនេះ។

ដើមបណ្តឹងរដ្ឋប្បវេណីបានប្រើវិធីសាស្ត្រនេះតាមវិធីផ្សេង គេបានឃើញក្នុងការអះអាងរបស់គេថា មានការស្លាប់មនុស្ស២លាននាក់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ការចោទប្រកាន់ថាមានការស្លាប់២លាននាក់នេះ ជាថ្មីម្តងទៀត គឺផ្អែកទៅលើភស្តុតាងដែលមិនបានដេញដោលគ្នា។ ហេតុអ្វី? ដោយសាររបាយការណ៍ដែលខ្លួនផ្អែកលើនោះ គឺមិនមែនជាផ្នែកសវនាការនេះទេ។ ហើយយើងមិនទាន់បានដេញដោលដោយភាគីនោះដែរ។

[១១:០០:២៣]

អ្នកជំនាញប្រជាសាស្ត្របានកំណត់តួលេខនេះ ក៏យើងមិនបានកោះហៅគាត់មកធ្វើជាសាក្សីដែរ។ ហេតុអី? ជាថ្មីម្តងទៀត ចម្លើយនោះគឺសាមញ្ញទេ ពីព្រោះថាចំនួនមនុស្សស្លាប់សរុប ដែលគេចោទនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ មិនមែនជាផ្នែកនៃការជំនុំជម្រះនេះទេ។ តើវាអាចទៅរួចទេ ដែលដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាទទួលមានជំងឺមួយស្រួចស្រាល់ ហើយពិបាកនឹងធ្វើការចោទប្រកាន់ឲ្យច្បាស់ ឬក៏ក្នុងវិសាលភាពនេះ។ តើពួកគេបានភ្លេច ថាតើគេនិយាយតែពីការជម្លៀសពីរដំណាក់កាល និងទួលពោធិ៍ជ្រៃ។ តើខ្លួនភ្លេចឬហើយ ហើយឬនៅរឿងហ្នឹង? ហេតុអ្វីក៏បាន -- មិនបានចងចាំឲ្យបានច្បាស់លាស់នោះ គឺថាជាសេចក្តីពន្យល់ហាក់ដូចជាស្រួលពេក។ ប៉ុន្តែអង្គជំនុំជម្រះមិនអាចបណ្តោតបណ្តោយឲ្យមាននីតិវិធីបែបនេះនោះទេ។ អនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីផ្អែកលើការអះអាងរបស់ខ្លួនទៅលើភស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពសវនាការនេះ គឺជាការបំពានសិទ្ធិជាមូលដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌។ អង្គជំនុំជម្រះត្រូវតែបដិសេធចោលការអះអាងនោះ ថាគ្មានទម្ងន់ជាភស្តុតាងទេ។

អ្វីដែលខ្ញុំហៅថា ការពិនិត្យដេញដោលចម្លើយរបស់សាក្សីមិនមានកម្រិតត្រឹមតែអ្វីដែលស្ថិតនៅក្រៅវិសាលភាពនោះទេ គឺភស្តុតាងនៅក្នុងវិសាលភាពរឿងក្តី០០២/០១នោះ គឺត្រូវបានចាត់ទុកដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ថាមានតម្លៃដូចគ្នា។ ឧទាហរណ៍នោះ ដូចយើងឃើញនៅក្នុងការប្រើ -- ការចោទប្រកាន់ថា កម្មាភិបាលខ្មែរក្រហមបានសម្លាប់ទារក ហើយនិងអ្នកណាដែលពាក់វ៉ែនតា។ ការចោទបែបនេះ គឺថាមិនអាចផ្អែកទៅលើការសន្និដ្ឋានថាមានអំពើនេះកើតនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ។ ការពិតនោះ គឺការអះអាងនេះ គឺគ្មានភស្តុតាងណាបង្ហាញបញ្ជាក់ គឺថាមិនមានអ្នកណាបញ្ជាក់ សាក្សីណាបញ្ជាក់ទេ។ ការប្រើពាក្យខុសអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងន័យនេះ។ ដូច្នេះអង្គជំនុំជម្រះគួរតែច្រានចោលការអះអាងនេះ។

[១១:០២:៤៦]

លោក លោកស្រីចៅក្រម ខ្ញុំសូមបង្អង់បន្តិច ហើយឲ្យផ្ទុះបញ្ចាំងអំពីការចោទប្រកាន់ដោយដើមបណ្ដឹងរដ្ឋប្បវេណីពីម្សិលមិញព្រឹកនោះ ដែលថាយើងការពារកូនក្ដីរបស់យើងនេះ យើងបានធ្វើចំអកឡកឡឺយទៅដើមបណ្ដឹងរដ្ឋប្បវេណី។ ចំណុចនេះ គឺគ្មានការអះអាងនោះទេ មេធាវីការពារក្ដីគឺមិនដែលបដិសេធការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ។ យើងមិនដែលហៅពួកគាត់ថា ជាអ្នកកុហកទេ។ តាមពិតដែលយើងបានផ្ដល់ការសន្ដានចិត្តដ៏ខ្លាំងទៅដល់ការឈឺចាប់របស់គេ។ ដូចដែលការងាររបស់យើងដែរ យើងធ្វើការងារជាមេធាវីការពារក្ដី ធ្វើការអះអាងយ៉ាងច្បាស់ ជំទាស់លើភស្តុតាងប្រឆាំងនឹងកូនក្ដីរបស់យើង។ ប្រសិនបើមេធាវី -- ដើមបណ្ដឹងរដ្ឋប្បវេណីចាត់ទុកថា ការងារនេះយើងខុសគ្នា គួរគេនិយាយថា យើងខុសនោះ គឺគេយល់ខុសអំពីតួនាទីរបស់មេធាវីការពារក្ដី និងរបស់ពួកគេ។

នៅក្នុងការឆ្លើយតបរបស់ពួកគាត់ម្សិលមិញនោះ ដើមបណ្ដឹងរដ្ឋប្បវេណីប៉ុនប៉ងបង្ហាញពីទិដ្ឋភាពថាមេធាវីការពារក្ដីបានបង្ហាញរឿងហ្នឹងដែលគេស្រមើស្រមៃ ហើយជារូបភាពមិនគាំទ្រដោយភស្តុតាងនោះទេ ការអះអាងបែបនោះ។ ពួកគាត់បានយោងទៅលើសារណារបស់ខ្ញុំក្នុងការប៉ុនប៉ងបង្ហាញថាការអះអាងរបស់យើង គឺនៅក្រៅវិសាលភាពនៃការពិតរបស់កម្ពុជាប្រជាធិបតេយ្យ។ គាត់បានចុចថាយើងប្រើភាសានៅក្នុងនេះថា យើងប្រើភាសា សមានន័យខ្មៅ ថាការជម្លៀសគឺជាការរំដោះប្រជាជនដែលគេយោងទៅរករឿងប្រលោមលោករបស់ អូវែលលៀន *(Orwellian)* ថាជាភាសាថ្មីនោះ។

[១១:០៤:៣២]

ក្នុងករណីនេះ គឺយើងប្រើពាក្យនេះជាបន្តបន្ទាប់ដោយភាគីទាំងអស់នៅក្នុងតុលាការនេះក្នុងការជំនុំជម្រះ។ ពាក្យទាំងអស់នេះ ខ្ញុំពិនិត្យមើលគឺថាយើងដកស្រង់ពីដីកាដំណោះស្រាយដោយខ្លួនឯង ហើយយើងអាចនឹងនិយាយស្មានថា ប្រសិនបើមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអានសារណារបស់យើងឲ្យបានច្បាស់នោះ គឺថាយើងអាចនឹងឃើញច្បាស់ហើយ មិនមែនធ្វើឲ្យមានការភ្ញាក់ផ្អើលបែបនោះទេ។ ផ្ទុយទៅវិញ ពេលដែលគាត់ប្រើពាក្យថា "ការរំដោះ" នោះមានន័យថាជា "វាលពិឃាត" នោះគឺថាគាត់មិនបានវាយតម្លៃឲ្យត្រឹមត្រូវពីការប្រើភាសារបស់យើងខ្ញុំទេ។

នៅទីបញ្ចប់គឺថា ពេលដែលគាត់លើកឡើងពេលនោះថា មេធាវីការពារក្ដីគឺមានកំហុសក្នុងការបង្ហាញភស្តុតាង ដើម្បីសម្របទៅតាមសេចក្ដីរៀបរាប់របស់យើង។ ប៉ុន្តែតាមពិតដើមបណ្ដឹងរដ្ឋប្បវេណីបានវាយប្រហារពីការប្រើសាក្សី ឡាយ បូនី ចម្លើយរបស់គាត់ហ្នឹងនិយាយអំពីលក្ខខណ្ឌនៃការ

ជម្លៀសពីដើមនោះ។ ហើយពួកគាត់បានអះអាងថា ប្រសិនបើមេធាវីការពារក្ដីអានប្អូនបន្ទាត់ទៅខាងក្រោមទៀតអំពីចម្លើយរបស់ ឡាយ បូ នោះគឺថាអាចនឹងឃើញថា ឡាយ បូនី ក៏និយាយដែរថា ជនជម្លៀសបានហើមខ្លួនប្រាណ ហើយគេទទួលបានអាហារតិចតួចជាងជ្រូកទៅទៀត។

[១១:០៦:០៣]

លោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្ដីនោះគឺថា បានអានបន្ទាត់ទាំងអស់នោះហើយនៅក្នុងសក្ខីកម្ម ហើយបានកត់សម្គាល់ថា បន្ទាត់ទាំងនោះមិនបាននិយាយអំពីការជម្លៀសវគ្គទី២នោះទេ។ ប៉ុន្តែផ្ទុយទៅវិញបានយោងទៅរកលក្ខខណ្ឌបន្ទាប់ពីការតាំងទីលំនៅនៅក្នុងសហករណ៍នៅពោធិ៍សាត់។

លក្ខខណ្ឌនៅក្នុងសហករណ៍ថ្មីៗនោះ ឡាយ បូនី បាននិយាយថា សូមដកស្រង់៖ “ទោះជាយ៉ាងណាក្ដីនៅពេលដែលពេលកន្លងទៅយើងមិនមានអាហារបរិភោគគ្រប់គ្រាន់ទេ យើងបានហូបអាហារតិចតួចតែប៉ុណ្ណោះ។ យើងហូបអាហារដែលធ្វើឲ្យយើង ខ្លួនរបស់យើងទៅជាហើម។ ហើយយើងជឿថានៅពេលនោះយើងកត់សម្គាល់ថាជ្រូកក៏បានទទួលអាហារច្រើនជាងយើងជាមនុស្សទៅទៀត”។ សូមចប់សេចក្ដីដកស្រង់។

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំនឹងឆ្លើយតបទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញានិយាយអំពីភាពយុត្តិធម៌នៃការជំនុំជម្រះនេះ។ សហព្រះរាជអាជ្ញាប៉ុនប៉ងនិយាយអំពីការបំពាន ហើយបញ្ជាក់ពីការអះអាងរបស់ខ្លួនថា មេធាវីការពារក្ដីបានលើកឡើងនៅក្នុងទឡ្ហីករណ៍ផ្ទាល់មាត់ គឺអង្គជំនុំជម្រះបានបង្ហាញអំពីការប្ដេជ្ញាដើម្បីផ្ដល់ការជំនុំជម្រះយុត្តិធម៌ដល់កូនក្ដីរបស់ខ្ញុំ។ សហព្រះរាជអាជ្ញាបញ្ជាក់ថា ហើយឲ្យយើងយល់ថា ការបំពានទៅលើការជំនុំជម្រះដោយយុត្តិធម៌នោះ គឺត្រូវបានដោះស្រាយរួចហើយ។ ហើយយើងស្នើឲ្យមានស្ដង់ដារនោះ ប៉ុន្តែយើងថាស្ដង់ដារវាមានកម្រិតទាប។ ចម្លើយទៅនឹងបញ្ហាដែលខ្ញុំសួរនេះ គឺថាពិតជាអ៊ីចឹងមែន។

[១១:០៧:៥០]

ដូចដែលអង្គជំនុំជម្រះជ្រាបហើយ ចំណុចសំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌ បើមានការបំពានហ្នឹងទាក់ទងទៅនឹងសាក្សី ហេង សំរិន គឺជាសាក្សី ជាស្នូលនៃការជំនុំជម្រះដោយយុត្តិធម៌។ ហើយអ្នកផ្សេងទៀតដែលយើងបានកោះហៅនោះ គឺថាដើម្បីធានានូវដំណើរការនីតិវិធីដោយយុត្តិធម៌តាមបរិមាណអប្បបរមា។

លោក ហេង សំរិន ជាសាក្សីដ៏សំខាន់សម្រាប់ការចោទប្រកាន់កូនក្តីរបស់ខ្ញុំនៅក្នុងជំនុំជម្រះការជម្លៀសភ្នំពេញ ហេតុការណ៍ទួលពោធិ៍ជ្រៃ ហើយនិងការអះអាងថា មានគោលនយោបាយក្នុងការសម្លាប់អតីតរដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ។ ហេង សំរិន ជាសាក្សីដែលមានភស្តុតាងដោះ បន្ទុកដោយផ្ទាល់ក្នុងការដោះបន្ទុកកូនក្តីរបស់ខ្ញុំឲ្យផុតពីការចោទប្រកាន់ដែលគាត់មានចេតនាថា សម្លាប់អ្នករដ្ឋការ និងទាហានសាធារណរដ្ឋខ្មែរ។ លោក ហេង សំរិន គឺជាសាក្សីតែម្នាក់គត់ដែលលោក នួន ជា បានស្នើសុំដើម្បីបញ្ជាក់ពីអត្តចរិករបស់គាត់។

លោក លោកស្រីចៅក្រម ភាគីទាំងអស់នៅក្នុងសាលសវនាការនេះគួរតែខ្លួនឯងនូវសំណួរនេះ។ តើពួកគេឮអ្វីពីសហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីដែលឆ្លើយតបទៅនឹងការខកខានរបស់សហព្រះរាជអាជ្ញាក្នុងការកោះអញ្ជើញលោក ហេង សំរិន នេះ?

[១១:០៩:១៨]

គ្មានអ្វីទេគឺស្ងាត់ស្ងៀមស្ងួន្យ ទាំងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនបានឆ្លើយតបទៅនឹងខ្លឹមសារនៃការតវ៉ានេះទាល់តែសោះ។ ហើយមានទឡ្ហីករណ៍ជាច្រើនដែលភាគីគប្បីតែបានធ្វើទាក់ទងទៅនឹងសំណើក្នុងការកោះអញ្ជើញលោក ហេង សំរិន មកបំភ្លឺក្នុងទីនេះ ប៉ុន្តែពួកគេមិនបាននិយាយអ្វីនោះទេ។ គួរតែបានអះអាងថាភស្តុតាងដែលលោក ហេង សំរិន នឹងផ្តល់ហ្នឹងគឺមិនសំខាន់ទេ ឬថាភស្តុតាងហ្នឹងគឺអាចនឹងបង្កើតឡើងដោយសារសាក្សីណាផ្សេងទៀតដើម្បីជំនួស។ គួរតែបញ្ជាក់ថាភស្តុតាងរបស់គាត់ទាក់ទងនឹងអត្តចរិតរបស់លោក នួន ជា មិនពាក់ព័ន្ធ ឬក៏អះអាងថា អ្នកផ្សេងទៀតដែលមានឋានៈខ្ពស់នៅក្នុងយោធាហ្នឹងមិនត្រូវបានស្តាប់នោះ។ ហើយមិនបានឆ្លើយតប ហើយគេបញ្ជាក់ថាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ជាចេតនារបស់ នួន ជា ហើយសក្ខីកម្មរបស់លោក ហេង សំរិន មិនចាំបាច់ទេ។ តើពួកគេបានធ្វើអ្វីឆ្លើយតបទេ? មិនបានធ្វើទេ។

លោក លោកស្រីចៅក្រម លោក ហេង សំរិន គឺជា ដូចជាដំរីនៅក្នុងបន្ទប់មួយអ៊ីចឹង គឺថាយើងឃើញច្បាស់ទាំងអស់ទាំងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុអ្វីបានជាគាត់មិននិយាយអ្វីសោះអំពីគាត់បែបនេះ។ ហេតុអ្វីមិនបាននិយាយថាដូច ក្រេក អេតឆេសាន់ ព្រឹកមិញនេះនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍។

[១១:១០:៥១]

យើងអាចឃើញមានមូលហេតុពីរ គេអាចយល់ស្របថាវត្តមានរបស់គាត់ គឺមានសារៈសំខាន់

ណាស់ដើម្បីការជំនុំជម្រះដោយយុត្តិធម៌ មិនអាចទប់ទល់បាននឹងសក្ខីកម្មរបស់គាត់។ ដូច្នេះហើយគឺយើងមិនចាំបាច់ សូម្បីតែបញ្ជាក់ឈ្មោះគាត់មិនបាច់ផងដែរ។ នេះជាគំនិតរបស់គាត់។ ដូច្នេះយើងមានជំហរដ៏សំខាន់ណាស់ដែលទាក់ទងទៅនឹងដំណើរការនីតិវិធីនេះ។ ប្រសិនបើចម្លើយគឺថាភាគីមិនអាចវិភាគ ឬក៏អំពីលក្ខណៈនៃដំណើរការនីតិវិធីនេះទេ សហព្រះរាជអាជ្ញាគឺស្ថិតនៅក្នុងឆន្ទៈរបស់រដ្ឋាភិបាលដែលធ្វើឱ្យបញ្ហានេះកាន់តែមានការអាក្រក់។ ប្រសិនបើចម្លើយនោះ គឺថាត្រឹមត្រូវមិនអាចរកបានទេ ដូច្នេះហើយយើងគប្បីតែបញ្ជាក់ថា ភាគីទាំងអស់បានយល់ស្របឱ្យមានការបំពានសិទ្ធិរបស់លោក នួន ជា នោះឯង។

សហព្រះរាជអាជ្ញា គួមដែន ក៏បាននិយាយផងដែរថាការជំនុំជម្រះនេះ គឺវាមានលក្ខណៈជានយោបាយជាមូលដ្ឋាន។ យើងបាននិយាយ -- ឮគាត់និយាយម្សិលមិញ ប៉ុន្តែគាត់បដិសេធ។ គាត់និយាយថាការជំនុំជម្រះនេះមិនមែនពីរឿងនយោបាយទេ ពីរឿងច្បាប់។

[១១:១២:០៩]

លោកប្រធាន យើងមិនយល់ស្របនឹងគាត់ទេ។ យើងបានបញ្ជាក់ថាដំណើរការនីតិវិធីបែបនេះមិនអាចបំបែកចេញឱ្យដាច់ច្បាប់ និងនយោបាយនោះទេ។ សាលាក្តីបែបនេះគឺអាចនឹងប្រើច្បាប់លាយជាមួយនឹងនយោបាយ។ យើងឱ្យពិនិត្យឃើញច្បាស់ថា គឺអាចនឹងឃើញច្បាស់គឺវាមិនមែនលាក់កំបាំងស្ថិតនៅក្នុងមេធាវីការពារក្តីជនដែលមានការភ័យខ្លាចនោះទេ។ នេះគឺជាទស្សនៈដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃដំណើរការព្រហ្មទណ្ឌអន្តរជាតិជាយូរមកហើយ។

ចៅក្រម ផាល នោះក៏បានបញ្ជាក់យ៉ាងច្បាស់ថា បញ្ជាក់នៅក្នុងការ ខ្វែងយល់នៅក្នុងសាលាក្តីតូក្យូថា “នៅពេលដែលមានអ្នកឈ្នះនៅក្នុងសង្គ្រាម គប្បីតែកាត់ទោសដូចជាអ្នកចាញ់ដែរ គឺត្រូវគោរពគោលការណ៍ដូចគ្នា”។ ទស្សនៈ នួន ជា គឺថាគាត់មិនបានអាចជំនុំជម្រះដោយយុត្តធម៌ ដោយតំណាងភាគីអ្នកដែលឈ្នះទាំងអស់ទេ។ ដូច្នេះហើយគំនិតនេះផ្ទុះបញ្ចាំងពីមតិខ្វែងយោបល់របស់ចៅក្រមនោះឯង។ នៅក្នុងការជំនុំជម្រះនេះ គឺនិយាយពីច្បាប់ ហើយនិងអង្គហេតុ មិននយោបាយទេ។

[១១:១៣:២៥]

ចំពោះសហព្រះរាជអាជ្ញា ហេតុអ្វីបានសហព្រះរាជអាជ្ញាបំភ្លេចចោលអង្គហេតុទាក់ទងទៅនឹងការចោទប្រកាន់នោះ? លោក លីសាក់ បានជម្រាបអង្គជំនុំជម្រះកាលម្សិលមិញថា សហព្រះរាជអាជ្ញាគឺបានដាក់បញ្ចូល៤០ទំព័រជាការវិភាគប្រវត្តិសាស្ត្រក្នុងសារណារបស់ខ្លួន។ ប៉ុន្តែសួរថាប្រវត្តិសាស្ត្រអ្វី?

ហេតុអ្វីបានជាអះអាងថា អំពើហិង្សារបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ មិនមានរៀបរាប់ពីការទម្លាក់គ្រាប់បែកអាមេរិកាំង? ឬក៏អំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយ លន់ នល់ ប្រឆាំងនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមិននិយាយ? ហេតុអីមិនមាននិយាយអំពីសង្គ្រាមបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងពួកអ្នកទាំងនោះ?

បើសិនជាមានការចម្ងល់អំពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងទៅនឹងអំពើឃោរឃៅរបស់ខ្មាំង របស់គេដែលក្នុងចម្បាំងនោះដែរឬទេ? មិនមានអ្នកណាជាអ្នកមានអំណាចទេដែលជាអ្នកទទួលខុសត្រូវ ដែលដូចដែលកូនក្តីរបស់ខ្ញុំទទួលចោទប្រកាន់ចំពោះបទឧក្រិដ្ឋដូចគ្នាទេ គឺគេប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នា។ តើសហព្រះរាជអាជ្ញាអាចហ៊ានចោទប្រកាន់អ្នកទាំងឡាយនៅក្នុងប្រទេសទាំងនេះទេដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់កូនក្តីខ្ញុំ?

[១១:១៤:៥២]

លោកប្រធាន លោក លោកស្រីចៅក្រម គឺថាចម្លើយគឺគេនឹងឆ្លើយថា “ទេ”។ ចម្លើយដែលសហព្រះរាជអាជ្ញាដែលថាការជំនុំជម្រះនេះ គឺមិនទាក់ទងនឹងយុត្តិធម៌ទេ ប៉ុន្តែមិនអាចលើកឈ្មោះលោក ហេង សំរិន ផង។ គេមិនអាចលើកឡើងដោយខ្លួនគេក្នុងជំទាស់នឹងមេធាវីការពារក្តីថា ការជំនុំជម្រះនេះ ហើយនិងការស៊ើបអង្កេតមិនយុត្តិធម៌។

ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់បទឧក្រិដ្ឋដែលលោក វេយ៍ន័រ ហើយនិង ខេល និយាយរួមគ្នាអំពីបទឧក្រិដ្ឋ ហើយនិងខ្ញុំនឹងនិយាយអំពីការជម្លៀសទីក្រុងភ្នំពេញ។

ទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ ខ្ញុំចង់បំភ្លឺឱ្យច្បាស់អំពីការយល់ច្រឡំរបស់សារណារបស់យើងដោយសហព្រះរាជអាជ្ញា ដែលយើងបានស្តាប់ឮកាលពីម្សិលមិញ ហើយដែលនាំធ្វើឱ្យមានការភ័ន្តច្រឡំដូចដែលកូនក្តីរបស់យើងខ្ញុំបានបញ្ជាក់ព្រឹកមិញនេះឯង។

ក្នុងសេចក្តីពន្យល់សង្ខេបរបស់យើង ហើយ នួន ជា បានបញ្ជាក់ព្រឹកមិញម្តងទៀតនៅព្រឹកនេះថាការជម្លៀសទីក្រុងភ្នំពេញ គឺធ្វើឡើយដោយមានការពិចារណាជាច្រើនដែលរាប់បញ្ចូលទាំងការខ្វះស្បៀងអាហារនៅក្នុងទីក្រុងភ្នំពេញ និងកម្ពុជាជាទូទៅ ហើយនិងផលប៉ះពាល់ការទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិក ហើយនិងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចរដ្ឋកម្ពុជា ទាំងស្រូវអង្ករដែលប្រមូលផលបានត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ផងដែរ។

[១១:១៦:២៣]

យើងបានជម្រាបទៅសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះថា អង្គហេតុទាំងអស់នេះជាផ្នែកទាំងមូលដែលនាំឲ្យមានសេចក្ដីសម្រេចក្នុងការជម្លៀសក្នុងរបៀបមួយដែលកំណត់ ត្រូវកំណត់វិធីនៃការអនុវត្តផងដែរ។

កាលពីម្សិលមិញនេះ សហព្រះរាជអាជ្ញាបានចាប់យកប្រយោគមួយពីមតិរបស់លោក សុន អរុណ ពីអាទិត្យមុន។ ហើយថាការជម្លៀសអាចនឹងត្រូវបាន -- មិនត្រូវធ្វើឡើងទេ បើគ្មានការខ្វះស្បៀងអាហារនៅភ្នំពេញ។ សហព្រះរាជអាជ្ញានិយាយថា ការកាត់ទោសគឺត្រូវពិនិត្យផ្ទៀងផ្ទាត់ទៅលើថាប្រយោគនេះវាផ្អែកទៅលើការផ្ដាច់ស្បៀងអាហារ និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ ដូច្នេះការអះអាងបែបនេះជាការមិនពិតទេ។ អង្គហេតុនេះគឺវាមានភាពពាក់ព័ន្ធនៅពេលនេះ។ ដូចដែលពីមុនដែរ ជាពិសេសគឺចំពោះការការពារក្ដីរបស់លោក នួន ជា។

[១១:១៧:២៩]

ទី១ ដូចដែលលោក សុន អរុណ បានបញ្ជាក់ ការទម្លាក់គ្រាប់បែកនោះគឺថាបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ហើយនិងលទ្ធភាពក្នុងការផលិតស្បៀង។ ការពិតនោះគឺជាទិដ្ឋភាពដែលថាបក្សកុម្មុយនីស្ដកម្ពុជាសន្និដ្ឋានថា ខ្លួនមិនអាចផលិតសេដ្ឋកិច្ចដើម្បីគាំទ្រប្រជាជនសង្គមទាំងមូលបានទេ ពីព្រោះវាមានការខូចខាតជាច្រើនដោយសារសង្គ្រាម។

ចំណុចទី២ ដូច សុន អរុណ បានបញ្ជាក់ដែរ គឺថាការជម្លៀសនោះគឺថាអាចនឹងមានរូបភាពផ្សេង បើសិនជាមហន្តរាយនៃទុរភិក្សមិនបានកើតមាននោះទេ។

ពីម្សិលមិញនេះគឺ ដូចដែលពួកគាត់បានបញ្ជាក់ក្នុងការជំនុំជម្រះនេះ សហព្រះរាជអាជ្ញាបញ្ជាក់ដដែលៗ វាយប្រហារការជំនុំជម្រះដោយមិនជំទាស់ទៅលើអង្គហេតុតាមវិធីដែលគេបានធ្វើនោះទេ។ ដោយសារភាពបន្ទាន់ ហើយនិងអង្គហេតុនោះបញ្ជាក់ថាវាមានការប៉ះពាល់ដល់អ្នករស់ទីក្រុងភ្នំពេញណាស់។ អ្នកដែលមើលឃើញជាលក្ខណៈច្បាស់ថា ការជម្លៀសហ្នឹងគឺៗដោយសារមានការគំរាមច្បាស់លាស់នៃការអត់ឃ្លាន ហើយនិងមានរបាយការណ៍ថាមានអាហារសល់សម្រាប់តែប្រាំមួយថ្ងៃទៀតទេ គិតពីថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ ហើយភស្តុតាងដែលយើងបានស្ដាប់ពីម្សិលមិញបញ្ជាក់ឲ្យឃើញច្បាស់ថា យើងមានអាហារ -- ខ្វះស្បៀងអាហារ ហើយនិងការទម្លាក់គ្រាប់បែកហ្នឹង គេចោទថាការអះអាងបែបហ្នឹង គឺខុស ជាការភ័ន្តច្រឡំ។

[១១:១៩:០៣]

មតិចុងក្រោយរបស់ខ្ញុំទាក់ទងនឹងការជម្លៀសទីក្រុងភ្នំពេញ គឺថាទាំងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញា ជាថ្មីម្តងទៀតអះអាង នួន ជា គឺមិនដាក់ខ្លួនគាត់ឲ្យតុលាការសួរដេញដោលទេ។ នួន ជា បាន១ផ្តល់ពេល១០ថ្ងៃដើម្បីសួរដេញដោល ហើយដូចដែលលោក លីសាក់ លើកឡើងពីម្សិលមិញនោះដែរ។ ហើយថាគាត់បានបន្តមិនធ្វើដូច្នោះដោយសារថាមានការបំពានសិទ្ធិរបស់គាត់នៅក្នុងការជម្លៀស នៅក្នុងការប្រើភស្តុតាងនៅពេលលោក ហេដឌ័រ។ ហេតុដូច្នេះអ្វីដែលខ្ញុំលើកឡើង ខ្ញុំសូមជំទាស់ដែលសហព្រះរាជអាជ្ញាថា កូនក្តីរបស់ខ្ញុំមិនព្រមធ្វើសក្ខីកម្មឲ្យសួរដេញដោលនេះ គឺមិនពិតដូច្នោះទេ។

ឥឡូវនេះ ខ្ញុំសូមបន្តនិយាយអំពីការជម្លៀសលើកទី២។ នៅពេលដែលសហព្រះរាជអាជ្ញាគាត់និយាយអំពីការផ្លាស់ទីលើកទី២ គាត់បានបកស្រាយខុសនូវការលើកឡើងរបស់យើង ដែលគាត់និយាយថា យើងបកស្រាយថា ការជម្លៀសលើកទី២ ត្រូវបានធ្វើឡើងដោយមេដឹកនាំភូមិភាគក្រហម។ ដែលគាត់ចង់បកស្រាយថា ការជម្លៀសលើកទី២ គឺធ្វើឡើងដោយមេដឹកនាំភូមិភាគតំបន់។ យើងសូមបញ្ជាក់ថា យើងមិនដែលនិយាយបែបនេះទេ។ គឺថានេះគឺជាការបកស្រាយរបស់ពួកគេ ហើយវាមិនមានន័យអ្វីទាល់តែទាំងអស់។

[១១:២០:៣៧]

លោកប្រធាន លោក លោកស្រីចៅក្រម ចំណុចរបស់យើងគឺថាការផ្លាស់ទី២ គឺជាការអនុវត្តរបស់ភូមិភាគ។ គឺថាទាំង រស់ ញឹម ហើយនិង សោ ភឹម ដែលជាមេដឹកនាំរបស់ភូមិភាគទាំងពីរនេះ គឺជាអ្នកផ្តើមគំនិតនៅក្នុងការជម្លៀសលើកទី២។ ហើយគាត់មិនមែនត្រឹមតែជាមេដឹកនាំរបស់ភូមិភាគប៉ុណ្ណោះទេ ប៉ុន្តែគាត់គឺជាសមាជិករបស់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ គឺគាត់មានអំណាចប្រហាក់ប្រហែលគ្នាស្មើនឹង នួន ជា ឬក៏ ប៉ុល ពត។ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបានគាំទ្រដល់ការសន្និដ្ឋានថា គឺភូមិភាគ មិនមែនជាគណៈកម្មការមជ្ឈិមនោះទេដែលគ្រប់គ្រង ហើយមានសិទ្ធិអំណាចទៅលើការជម្លៀសនេះ។

ជាបន្តទៀត ខ្ញុំនឹងនិយាយអំពីទួលពោធិ៍ជ្រៃ។ យើងមានបញ្ហាជាច្រើនដែលត្រូវនិយាយអំពីទួលពោធិ៍ជ្រៃ ក្រៅពីគោលនយោបាយនោះ។ ប៉ុន្តែដោយសារតែមានពេលវេលាកំណត់ដូច្នេះ ខ្ញុំនឹងលើកយកតែប្រាំមួយចំណុចសំខាន់១តែប៉ុណ្ណោះ។

ទី១) សហព្រះរាជអាជ្ញាកាលពីម្សិលមិញមិនបាននិយាយអ្វីទាំងអស់ ទាក់ទងទៅនឹងភស្តុតាង

ផ្ទាល់ ដែលថាមិនមានគោលនយោបាយក្នុងការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការលន់នល់។ សហព្រះរាជអាជ្ញាមិនបាននិយាយអ្វីទាំងអស់អំពី ភី ភួន។ គេមិនបាននិយាយអ្វីទាំងអស់អំពី ហេង សំរិន ហើយក៏គេមិនបាននិយាយអ្វីទាំងអស់អំពី អ៊ុក ប៊ុនឈឿន ផងដែរ។ គេមិនបានជំទាស់ទៅលើបញ្ហាទាំងអស់នេះ គេមិនបានប្រឆាំង ហើយក៏គេមិនបានប្រាប់អង្គជំនុំជម្រះថាវាមិនអាចទុកចិត្តបាននោះទេ។ សហព្រះរាជអាជ្ញាក៏មិនបានប្រាប់អង្គជំនុំជម្រះ ថាតើត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីដោះស្រាយការផ្ទុយគ្នារវាងគោលជំហរ និងភស្តុតាងអំពីអ្នកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែលបានផ្ដល់ភស្តុតាងនោះ។

[១១:២២:៣២]

ដូចដែលខ្ញុំបានសង្កេតឃើញរួចទៅហើយ គឺយើងបានអះអាងថា វាមានការរំលោភទៅលើសិទ្ធិរបស់លោក នួន ជា ទៅលើការទទួលបានសិទ្ធិជំនុំជម្រះដោយយុត្តិធម៌ ដែលវាតម្រូវឲ្យមានការច្រានចោលនូវបទចោទទាំងអស់ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ ប៉ុន្តែសហព្រះរាជអាជ្ញាមិនបាននិយាយអំពីបញ្ហាទាំងអស់នេះ។ ដូច្នេះយើងសូមលើកឡើងថា វាជាការគួរឲ្យចាប់អារម្មណ៍។

ទី២) គឺថាខាងសហព្រះរាជអាជ្ញាបានផ្ដល់នូវភស្តុតាងចំនួនពីរមកដល់អង្គជំនុំជម្រះ ទាក់ទងទៅនឹងគោលនយោបាយនៅក្នុងការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់។ ភស្តុតាងទី១ គឺជារូបថតរបស់មនុស្សមួយក្រុមនៅក្រសួងព័ត៌មាន ដែលគេថាប្រហែលជានៅថ្ងៃ១៧ មេសា ៧៥។

លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតនៅលើអេក្រង់ ហើយសូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំបង្ហាញនៅពេលឥឡូវនេះ។ ហើយសូមប្រាប់ដល់ខាងសោត-ទស្សន៍ថា យើងចង់ឲ្យមានការពង្រីកឲ្យធំបន្តិចដោយសាររូបថតហ្នឹងវារាងតូច។

[១១:២៣:៤២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:២៣:៥៨]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអភ័យទោសលោកប្រធាន គឺថាខាងសហព្រះរាជអាជ្ញាបានហៅរូបថតនេះថា មានអ្នកខ្លះដែលគាត់ឈរស្ងៀមស្ងាត់ ដោយឱបដៃ។ ហើយខាងសហព្រះរាជអាជ្ញាហៅភស្តុតាងថា ជាភស្តុតាងដែលមានទម្ងន់យ៉ាងខ្លាំង ដែលថាទាហានទាំងអស់ និងមន្ត្រីទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេសម្លាប់នៅក្នុងទូទាំងប្រទេសកម្ពុជា ទាំងនៅថ្ងៃ១៧ មេសា និងនៅក្នុងអំឡុងពេលក្រោយៗមកទៀត។

គឺថាការសម្លាប់ហ្នឹងត្រូវធ្វើឡើងអនុលោមទៅតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ រូបថតមួយនេះ គឺជាភស្តុតាងមួយក្នុងចំណោមភស្តុតាងពីរដែលសហព្រះរាជអាជ្ញាបានអះអាងថា បានបង្ហាញអំពីវត្តមាននៃគោលនយោបាយ។ ប្រហែលជាសហព្រះរាជអាជ្ញាគាត់ឃើញនូវលេខកូដសម្ងាត់ណាមួយនៅក្នុងរូបថត ដែលយើងខាងមេធាវីការពារក្តីមើលអត់ឃើញមើលទៅ។

ផ្ទុយទៅនឹងអ្វីដែលព្រះរាជអាជ្ញាបានអះអាង យើងសូមឆ្លើយតបទៅនឹងភស្តុតាងនេះ។ ដូចដែលយើងបានឆ្លើយកាលពីសប្តាហ៍មុន។ យើងឯកភាពថា រូបថតហ្នឹងបង្ហាញពីមនុស្សដែលមានវត្តមាននៅក្រសួងព័ត៌មាន ប៉ុន្តែរូបថតនោះបង្ហាញត្រឹមតែប៉ុណ្ណឹងទេ អត់មានអ្វីលើសពីហ្នឹងទេ។ យើងបានពន្យល់ថា ហេតុអ្វីបានជាអង្គហេតុនោះវាមិនពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយសម្លាប់មនុស្ស។ ប៉ុន្តែព្រះរាជអាជ្ញាគាត់មិនឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់យើងនោះទេ។ ផ្ទុយទៅវិញ គឺថាព្រះរាជអាជ្ញាគ្រាន់តែបញ្ជាក់ឡើងវិញនូវអង្គហេតុដែលថារូបថតហ្នឹង គឺថតពីមនុស្សដែលមានវត្តមាននៅក្រសួង។ ដូច្នេះខ្ញុំគិតថាភស្តុតាងដែលគេលើកឡើងថា ជាភស្តុតាងដែលមានទម្ងន់ធ្ងន់ហ្នឹងគឺវាមិនពាក់ព័ន្ធទាល់តែសោះ។

ភស្តុតាងទី២ ដែលគេលើកឡើងថាជាភស្តុតាងដ៏ខ្លាំងក្លានោះ គឺជាការដកស្រង់មួយចំនួនពីសក្ខីកម្មរបស់ ឌុច។ ដូចដែលយើងលើកឡើងពីមុនរួចមកហើយ ឌុច បានទទួលស្គាល់ថាគាត់មិនមានមូលដ្ឋានណាមួយក្នុងការធ្វើការសន្និដ្ឋាន ពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ សក្ខីកម្មរបស់គាត់គឺមិនពាក់ព័ន្ធនោះឡើយ។ ប៉ុន្តែខ្ញុំសូមបន្ថែមថា ទោះបីថាការដកស្រង់ដែលមិនពាក់ព័ន្ធដែលលើកឡើងដោយព្រះរាជអាជ្ញាកាលពីម្សិលមិញក៏ដោយ ក៏មិនអាចបង្ហាញថាមានគោលនយោបាយសម្លាប់មនុស្សកើតឡើងនោះឡើយ។

[១១:២៦:១៩]

កាលពីម្សិលមិញ ព្រះរាជអាជ្ញាបានដកស្រង់សម្តីរបស់ ឌុច ដែលខ្ញុំសូមលើកយកមកដកស្រង់៖ “ក្នុងដំណាក់កាលដំបូងនោះ ប្រជាជនត្រូវបានគេជម្លៀស ហើយបន្ទាប់មកទៀត ទាហានជាន់ខ្ពស់មួយចំនួនត្រូវបានគេចាប់ខ្លួន ហើយនិងសម្លាប់ជាសម្ងាត់”។ សូមបញ្ចប់ការដកស្រង់។

យើងមិនដឹងថាតើ ឌុច គាត់សន្និដ្ឋានបែបនេះដោយរបៀបណានោះទេ ប៉ុន្តែទោះបីថាភស្តុតាងហ្នឹង -- ទោះបីយ៉ាងណាក៏ដោយភស្តុតាងហ្នឹងបានបង្ហាញថា មានតែទាហានជាន់ខ្ពស់ប៉ុណ្ណោះត្រូវបានគេសម្លាប់។ ហើយសូម្បីតែ ដូច្នេះក៏ដោយក៏មានតែមន្ត្រីទាហានជាន់ខ្ពស់មួយចំនួនប៉ុណ្ណោះត្រូវបានគេ

សម្លាប់។ ហើយភស្តុតាងមួយផ្សេងទៀតរបស់សហព្រះរាជអាជ្ញាដែលដកស្រង់ចេញពី ឌុច ផងដែរគឺវាមិនស្របជាមួយនឹងគោលនយោបាយដែលគេលើកឡើងនោះទេ។

ដូចដែលព្រះរាជអាជ្ញាបានកត់សម្គាល់ដែលថា ចៅក្រម ឡាវែន៍ គាត់បានសួរ ឌុច នៅក្នុងសំណុំរឿង០០១ នោះថា តើមនុស្សដែលពាក់ព័ន្ធជាមួយទាហានរបប លន់ នល់ ត្រូវបានគេសម្លាប់ឬក៏អត់? ហើយ ឌុច ក៏បានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់សម្តីរបស់ ឌុច៖ “មនុស្សនៅក្នុងរបប លន់ នល់ត្រូវបានគេចាត់ទុកជាបីប្រភេទ។ ប្រភេទទី១ គឺគេចាត់ទុកថាជាមនុស្សដែលត្រូវគេកម្ទេចជាសម្ងាត់” សូមបញ្ចប់ការដកស្រង់។

ហើយនេះគឺជាចំណុចដែលព្រះរាជអាជ្ញាគាត់បញ្ឈប់ការអាននូវសម្រង់របស់គាត់ ប៉ុន្តែដូចដែលអង្គជំនុំជម្រះដឹងច្បាស់រួចទៅហើយការឆ្លើយគឺអានបន្តទៅទៀត៖ “ប្រភេទទី២ គេសំដៅទៅលើមនុស្សដែលត្រូវបានគេឃុំខ្លួននៅជំរំអប់រំ ហើយនិងប្រភេទទី៣ គឺគេសំដៅទៅលើប្រជាជនដែលត្រូវបានគេចាត់ទុកជាប្រជាជនថ្មី”។ សូមបញ្ចប់ការដកស្រង់។

[១១:២៨:០៣]

ដូច្នេះហើយនេះ គឺជាភស្តុតាងសំខាន់ចុងក្រោយរបស់ព្រះរាជអាជ្ញាទាក់ទងទៅនឹងគោលនយោបាយនៃការតាមចាប់ និងសម្លាប់ជាប្រព័ន្ធទៅទាហាន និងអ្នករដ្ឋការលន់នល់។ ទោះបីយ៉ាងណាក៏ដោយវាមិនបានបង្ហាញថាមានគោលនយោបាយបែបនេះកើតឡើងនោះឡើយ។

លោកប្រធាន លោក លោកស្រីចៅក្រម! ចំណុចទី៣ របស់ខ្ញុំទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ គឺទាក់ទងទៅនឹងទម្រង់ គំរូនៃភស្តុតាង។ កាលពីម្សិលមិញ សហព្រះរាជអាជ្ញាមិន -- សូម្បីតែជំទាស់ទៅលើការបង្ហាញជាប្រព័ន្ធរបស់យើងថា មិនមានទម្រង់គំរូបែបនេះកើតឡើងនោះឡើយ។ លោក រេយ៍ន័របាននិយាយហាក់ដូចជាតួសម្តែងអឺចឹងទាក់ទងទៅនឹងលក្ខណៈជាប្រព័ន្ធរបស់ទម្រង់គំរូនេះ។ គាត់បានសួរអង្គជំនុំជម្រះប្រហែលជាប្រាំទៅប្រាំមួយដង ថាតើវាជាការចៃដន្យដែរឬទេ ដែលថាការសម្លាប់ហ្នឹងកើតឡើងដូចគ្នានៅគ្រប់ទីកន្លែងក្នុងទូទាំងប្រទេស?

[១១:២៩:០០]

ឥឡូវនេះ ខ្ញុំសួរបន្តទៅនេះវិញ តើវាជាការចៃដន្យដែរឬទេ ដែលសហព្រះរាជអាជ្ញាគាត់មិនអាចបង្ហាញ សូម្បីតែសាក្សីមួយរូបដែលបង្ហាញអំពីវត្តមាននៃទម្រង់គំរូនេះដែលគេបាននិយាយថាបានកើតឡើងនៅគ្រប់ទីកន្លែងនោះ? តើវាការចៃដន្យដែរឬទេ ដែលគេមិនអាចសូម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍

តែមួយដែលយើងបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលនោះ?

លោក លីសាក់ ក៏បានលើកឡើងទាក់ទងទៅនឹងទម្រង់គំរូនៃភស្តុតាងនេះផងដែរ គាត់បានប្រាប់អង្គជំនុំជម្រះថា មេធាវីការពារក្តីមាននូវសារណាមួយពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាន លន់ នល់ នៅក្នុងខែមេសា ឆ្នាំ៧៥។ គាត់បាននិយាយថា សារណារបស់ពួកយើងគឺថាការសម្លាប់ហ្នឹងកើតឡើងនៅក្នុងភូមិពាយ័ព្យ និងភូមិភាគនិរតី។ ប៉ុន្តែតាមការពិតទៅ គឺយើងអត់មានសារណាសូម្បីតែបន្តិច ទាក់ទងទៅនឹងការសម្លាប់ទាហានលន់ នល់ នោះឡើយ។ សារណារបស់យើងគឺថា សហព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់អំពីអត្ថិភាពនៃគោលនយោបាយដែលដឹកនាំដោយមជ្ឈិមនោះឡើយ។

[១១:៣០:១៥]

ហេតុផលសម្រាប់ការសន្និដ្ឋាននេះ គឺថាជាដំបូងវាមិនស្របជាមួយនឹងភស្តុតាងផ្ទាល់ ហើយនិងទី២ គឺថាភស្តុតាង ទម្រង់គំរូនៃភស្តុតាង គឺមិនអាចទុកចិត្តជាប្រព័ន្ធ ហើយទី៣ គឺថាភស្តុតាងមិនអាចទុកចិត្តជាប្រព័ន្ធហ្នឹង គឺផ្តោតតែនៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី។ ហេតុដូច្នេះហើយ គឺវាមិនពាក់ព័ន្ធទៅនឹងគោលនយោបាយទូទាំងប្រទេសនោះឡើយ។

សហព្រះរាជអាជ្ញាមិនបានជំទាស់សូម្បីតែមួយទៅលើអង្គហេតុនេះ។ តាមពិតទៅដើម្បីបង្កើតអំពីអត្ថិភាពនៃគោលនយោបាយ ដោយផ្អែកទៅលើភស្តុតាងដែលមិនអាចទុកចិត្តបាន ហើយដែលមិនអាចយកមកជំទាស់នៅក្នុងតុលាការជាសាធារណៈបាន ហើយដែលកើតឡើងតែនៅក្នុងផ្នែកមួយតូចនៃប្រទេស គឺបានន័យថា ពេលនោះព្រះរាជអាជ្ញាត្រូវត្រៀមខ្លួនយ៉ាងខ្លាំង ដើម្បីធ្វើការឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះ។

[១១:៣១:០៥]

លោក លីសាក់ បានលើកឡើងនូវការពន្យល់មួយដែរ។ គាត់បានលើកឡើងថា ប្រហែលជាមានទាហាន លន់ លន់ ច្រើនជាងនៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ច្រើនជាងកន្លែងផ្សេងទៀតនៅក្នុងប្រទេស។ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ គាត់មិនបានផ្តល់សូម្បីតែភស្តុតាងតែមួយ ដើម្បីគាំទ្រការលើកឡើងនេះឡើយ។ ភស្តុតាងបានបង្ហាញ ដែលយើងបានបង្ហាញទៅអង្គជំនុំជម្រះកាលពីសប្តាហ៍មុនបានបង្ហាញយ៉ាងច្បាស់ថា ទាហាន លន់ នល់ មិនត្រូវបានគេសម្លាប់នៅក្នុងតំបន់រំដោះមុនឆ្នាំ៧៥នោះ

ឡើយ។

ដូច្នេះហើយមិនមានហេតុផលអ្វីដែលយើងមិនជឿថា ទាហានលន់នល់ នៅបន្តរស់នៅរស់នៅក្នុងតំបន់រំដោះរហូតដល់ថ្ងៃ១៧ មេសា ៧៥ និងក្រោយៗមកទៀតនោះទេ។ ហើយក៏មិនមានភស្តុតាងណាមួយបង្ហាញថា ទាហានលន់នល់ និងមន្ត្រីលន់នល់ ត្រូវបានគេសម្លាប់តិចជាងនៅក្នុងតំបន់ពិសេស តំបន់មជ្ឈិម ឬក៏តំបន់ឧត្តរ ឬក៏តំបន់ផ្សេងៗទៀតនោះ នៅក្នុងខែមេសា ៧៥នោះឡើយ។ វាបង្ហាញថាពួកគេមិនត្រូវបានសម្លាប់នៅក្នុងតំបន់នោះទាល់តែសោះ។ យើងបានបង្ហាញភស្តុតាងសំខាន់ៗជាច្រើនដែលបង្ហាញថា ទាហាន លន់ នល់ ក៏ដូចជាមន្ត្រីរដ្ឋការ លន់ នល់ មានវត្តមាននៅក្នុងភូមិភាគបូព៌ា ឬក៏នៅក្នុងការគ្រប់គ្រងរបស់ទាហានភូមិភាគបូព៌ាដែលមិនត្រូវបានគេសម្លាប់។

ដូចគ្នានឹងលោក វេយ័ន័រ ដែរ, លោក លីសាក់ មិនបានបង្ហាញអ្វីទាល់តែសោះអំពីភស្តុតាងនេះ។ គាត់មិនអាចបង្ហាញសូម្បីតែហេតុផលមួយ ថាហេតុអ្វីការវិភាគរបស់យើងដែលបានផ្តល់ទៅអង្គជំនុំជម្រះកាលពីសប្តាហ៍មុនមានកំហុស។ គាត់មិនអាចនិយាយយោងសូម្បីតែចម្លើយតែមួយរបស់សាក្សីមួយរូបណាឡើយ។

[១១:៣២:៥០]

លោកប្រធាន លោក លោកស្រីចៅក្រម បន្ទាប់មកទៀតលោក លីសាក់ បានលើកឡើងថា ការប្រមូលផ្តុំយ៉ាងច្រើនរបស់ភស្តុតាងនៅក្នុងភូមិភាគនិរតី គឺប្រហែលជាស្របជាមួយនឹងគោលនយោបាយរបស់មជ្ឈិមបក្ស ពីព្រោះ ប៉ុល ពត មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងភូមិភាគនិរតី។ គាត់ប្រហែលជាចង់ឲ្យអង្គជំនុំជម្រះនេះធ្វើការសន្និដ្ឋានចំនួនពីរ។ គាត់ចង់ឲ្យអង្គជំនុំជម្រះនេះសន្និដ្ឋានថា ទី១ តាម៉ុក គាត់ជិតស្និទ្ធជាមួយ ប៉ុល ពត។ ហើយទី២ ដោយសារតែ តាម៉ុក គាត់ជិតស្និទ្ធជាមួយ ប៉ុល ពត អ្វីៗទាំងអស់ដែលបានកើតឡើងនៅក្នុងភូមិភាគនិរតី គឺបានឆ្លុះបញ្ចាំងពីចេតនារបស់មជ្ឈិមបក្ស។ ប៉ុន្តែមិនមានភស្តុតាងសូម្បីតែមួយដើម្បីគាំទ្រដល់ការអះអាងនេះឡើយ។ ហើយក៏មិនដែលមានប្រធានបទនៃការនិយាយដែលគាត់លើកឡើងម្សិលមិញ ដែលមានរយៈពេលប្រាំនាទីមាននៅក្នុងសក្ខីកម្មរបស់សាក្សី។ ហើយក៏មិនមានការអះអាងណាមួយទាក់ទងទៅនឹងប្រធានបទនេះ នៅក្នុងឯកសារជាភស្តុតាងនោះឡើយ។ ហើយកាលពីមុនកន្លងមក ក៏មិនដែលមានការនិយាយអំពីបញ្ហានេះ នៅចំពោះមុខអង្គជំនុំជម្រះដែរ។ ទើបតែខែមុន ដែលថាគោលជំហររបស់ព្រះរាជអាជ្ញា គឺថាការសម្លាប់ហ្នឹងកើតឡើងនៅគ្រប់ទីកន្លែង។

[១១:៣៤:០២]

លោកប្រធាន ទើបតែសប្តាហ៍មុនប៉ុណ្ណោះ ដែលគោលជំហររបស់ព្រះរាជអាជ្ញាបានបញ្ជាក់ច្បាស់ថា ការសម្លាប់ហ្នឹងកើតឡើងនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ ហើយប្រាំនាទីមុនពេលលោក លីសាក់ ឡើងមកនិយាយនោះ គឺថាគោលជំហររបស់សហព្រះរាជអាជ្ញាបានបញ្ជាក់ច្បាស់ថា ការសម្លាប់កើតឡើងនៅគ្រប់ទីកន្លែង។ ប៉ុន្តែពួកគេមិនដែលព្យាយាមភ្ជាប់ទំនាក់ទំនងនៃការ -- ភ្ជាប់ទំនាក់ទំនងហេតុការណ៍ណាមួយទៅក្នុងមជ្ឈិមបក្សនោះឡើយ។ ពួកគេមិនចាំបាច់ត្រូវបង្ហាញនោះទេ ព្រោះគោលជំហររបស់ពួកគេ គឺថាអ្វីៗទាំងអស់កើតឡើងដូចគ្នានៅគ្រប់ទីកន្លែង។

វាជាការចាំបាច់ដែលយើងត្រូវដឹងថា ទ្រឹស្តីរបស់លោក លីសាក់ គឺពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់លោក នួន ជា តែក្នុងករណីដែលលោក នួន ជា រៀបចំផែនការរួមជាមួយ តាម៉ុក ហើយនិង រស់ ញឹម តែប៉ុណ្ណោះ។ ប៉ុន្តែមិនមែនជាមួយ សោ ភឹម ឬក៏ ណៃ សារ៉ាន់ ក្នុងការសម្លាប់ទាហាន លន់ នល់ នោះទេ។ តើទ្រឹស្តីហ្នឹងអាចត្រឹមត្រូវដែរឬទេ? អាចត្រឹមត្រូវដែរឬទេ ព្រះរាជអាជ្ញា? វាអាចត្រូវ។ គឺថាអ្វីៗអាចត្រូវ ប៉ុន្តែអង្គជំនុំជម្រះមិនដែលពិចារណាបែបនេះទេ។ សហព្រះរាជអាជ្ញាក្នុងពេលកន្លងមកគឺថាមិនដែលជំទាស់ពីបញ្ហានេះទេ មិនមានភស្តុតាងអ្វីទាំងអស់ដើម្បីគាំទ្រចំណុចនេះ។ ហើយអង្គជំនុំជម្រះក៏មិនមានមូលដ្ឋានណាមួយដើម្បីធ្វើការសន្និដ្ឋានបែបនេះដែរ។

[១១:៣៥:២៨]

លោកប្រធាន លោក លោកស្រីចៅក្រម! ចំណុច៤ ដែលខ្ញុំចង់លើកឡើងទាក់ទងទៅនឹងទួលពោធិ៍ជ្រៃហ្នឹង គឺការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាយើងមិនអាចឆ្លើយតបសូម្បីតែការអះអាងសំខាន់របស់ពួកគេទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ ព្រះរាជអាជ្ញាបានពណ៌នាថា ការអះអាងសំខាន់របស់ពួកគេ គឺថា នួន ជា ចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមក្នុងការសម្លាប់ខ្មាំងវណ្ណៈ ហើយនិងអ្នកទាំងអស់គ្នាដែលជំទាស់ទៅនឹងបក្សកុម្មុយនីស្តកម្ពុជា។

តាមពិតទៅយើងបានបង្ហាញអង្គជំនុំជម្រះថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកទាហាន និងមន្ត្រីរដ្ឋការជាមួយក្រុមដទៃទៀត ដូចជាព្រះសង្ឃ និងបញ្ញាជន ដែលក្រុមទាំងអស់នោះមិនមែនជាប្រធានបទនៃគោលនយោបាយកាប់សម្លាប់នោះឡើយ។

គោលជំហររបស់សហព្រះរាជអាជ្ញា គឺថាបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកទាហាន និងអ្នករដ្ឋការគឺសង្ស័យ។ ហើយការសន្និដ្ឋាននេះ គឺមិនគ្រប់គ្រាន់ទាក់ទងទៅនឹងផ្នែកច្បាប់ដែលអាចបង្ហាញអំពីការ

ទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួនជា។ សេចក្តីដីកាដំណោះស្រាយបានចោទប្រកាន់ថានៅទួលពោធិ៍ជ្រៃ ទាហាន និងរដ្ឋការត្រូវបានគេសម្លាប់ដោយមិនមានការរើសអើងជារួមតែម្តង។ បន្ទាប់មកទៀត វាបាននិយាយថា គោលនយោបាយដែលតម្រូវឲ្យមានការសម្លាប់ទាហាន និងអ្នករដ្ឋការជារួមហ្នឹង គឺពាក់ព័ន្ធទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះ។ ទ្រឹស្តីវណ្ណៈដែលមិនត្រឹមត្រូវ ដែលមិនមានទំនាក់ទំនងច្បាស់លាស់ទៅនឹងគោលនយោបាយនៃការសម្លាប់ជាប្រព័ន្ធហ្នឹង គឺមិនគ្រប់គ្រាន់ទាល់តែសោះ។

[១១:៣៦:៥៩]

លោកប្រធាន លោក លោកស្រីចៅក្រម វាជាការចាំបាច់ដែលយើងត្រូវទទួលស្គាល់ថា វាមានភាពខុសគ្នារវាងការសង្ស័យជាទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះមន្ត្រីសាធារណរដ្ឋ ហើយនិងសេចក្តីសម្រេចក្នុងការសម្លាប់មន្ត្រីទាំងអស់នោះភ្លាមៗ។ ភាពខុសគ្នានេះ គឺជាប្រធានបទនៃចម្លើយរបស់សម្តេច ហេង សំរិន ចំពោះលោក ប៉ែន យៀរនិន។ ហេង សំរិន មិនបាននិយាយថា នួន ជា មិនដែលគិតអំពីមន្ត្រីរបបមុននោះឡើយ។ គាត់មិនបាននិយាយថា មន្ត្រីទាំងអស់នោះមិនមែនជាប្រធានបទនៃការពិភាក្សានោះឡើយ។ អ្វីដែលគាត់និយាយ គឺថានៅពេលដែលមជ្ឈិមបក្សសម្រេច ថាតើត្រូវដោះស្រាយយ៉ាងដូចម្តេចជាមួយមន្ត្រីសាធារណរដ្ឋនោះ ពួកគេ -- ខ្ញុំសូមដកស្រង់៖ “មិនបាននិយាយថាសម្លាប់នោះទេ”។ ផ្ទុយទៅវិញពួកគេនិយាយថា ខ្ញុំសូមដកស្រង់៖ “កុំអនុញ្ញាតឲ្យពួកគេស្ថិតនៅក្នុងក្របខ័ណ្ឌរបស់យើង” សូមបញ្ចប់ការដកស្រង់។

ភាពខុសគ្នាបែបនេះ គឺបានបង្ហាញច្បាស់អំពីភាពស្រពេចស្រពិលនៅក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅលើការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មាំង។ ដូច្នេះហើយគឺថាមិនមានភស្តុតាងណាមួយដែលថា មនុស្សបែបនេះ ឬថាក្រុមមនុស្សបែបនេះត្រូវបាន គេសម្លាប់ជាប្រព័ន្ធនោះឡើយ។

[១១:៣៨:២៣]

ឥឡូវនេះខ្ញុំសូមឈានដល់ចំណុចទី៥ ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។ អ្វីដែលព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញបានបង្ហាញថា ពួកគេយល់ស្របជាមួយយើងទៅវិញទេ។

ទោះបីថាពួកគេលើកឡើងថាការលើកឡើងជាសំខាន់របស់គេគឺថា ទាហានគឺជាខ្មាំងរបស់បក្ស។ ជាចុងក្រោយគេបានបញ្ចប់ដោយនិយាយក្នុងលក្ខណៈសាមញ្ញ និងចង្អៀតជាង។ ចុងក្រោយពួកគេបាននិយាយថា គឺមានគោលនយោបាយសម្លាប់ ហើយខ្ញុំសូមដកស្រង់៖ “មន្ត្រីដែលមានឋានៈមួយចំនួន

ហើយនិងខ្ពស់ជាងនេះ”។ ការពិតទៅយើងសូមជំទាស់ទៅលើចំណុចនេះ ប៉ុន្តែចំណុចសំខាន់គឺថា ព្រះរាជអាជ្ញាដឹងច្បាស់ថា ទ្រឹស្តីវណ្ណៈដែល ឌុច បានអះអាងថាអាននៅក្នុងទស្សនាវដ្តីទង់បដិវត្តហ្នឹង គឺមិនមែនមានន័យថា ជាការសម្លាប់នោះទេ។ ទោះបីថាពួកគេដឹងថា ពួកគេមិនអាចអះអាងដោយគួរឲ្យជឿជាក់ថា នួន ជា មានចេតនាសម្លាប់ទាហានលន់នល់ ដោយមិនគិតអំពីឋានៈក៏ដោយ។

ដូចដែលយើងបានសង្កេតកាលពីម្សិលមិញ សហព្រះរាជអាជ្ញាមិនអាចសូម្បីតែអះអាងអំពីជនរងគ្រោះនៅទួលពោធិ៍ជ្រៃ ដែលមិនអាចអះអាងថាពួកគេគ្រាន់តែជាទាហាន និងប្រជាជនស៊ីវិលធម្មតានោះឡើយ។ ម្សិលមិញពួកគេយល់ស្របថា នួន ជា មិនដែលមានចេតនាសម្លាប់ទាហានធម្មតា ឬក៏ប្រជាជនស៊ីវិលឡើយ។ នៅពេលដែលយើងនិយាយរួមគ្នាគឺថា ការសន្និដ្ឋានដែលថា នួន ជា មិនដែលមានចេតនាសម្លាប់ជនរងគ្រោះនៅទួលពោធិ៍ជ្រៃនោះឡើយ។ ដូច្នេះហើយ ហេតុផលតែមួយគត់នេះក៏គ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះលើកលែងបទចោទទាំងអស់ ដែលអង្គជំនុំជម្រះបានចោទទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ។

[១១:៤០:00]

ចំណុចចុងក្រោយទី៦របស់ខ្ញុំ គឺថាសហព្រះរាជអាជ្ញាមិនបាននិយាយអ្វីទាល់តែសោះអំពីលទ្ធភាពមួយ គឺថាប្រសិនបើទោះជាមានការសម្លាប់កើតឡើងនៅទួលពោធិ៍ជ្រៃក៏ដោយ គឺថាការសម្លាប់ហ្នឹងគឺជាការសម្លាប់សងសឹកដែលធ្វើឡើងដោយអ្នកមូលដ្ឋាន។

លោកប្រធាន លោក លោកស្រីចៅក្រម មិនត្រូវភ្លេចការរំដោះទីរួមខេត្តពោធិ៍សាត់ គឺជាការបញ្ចប់នូវការប្រយុទ្ធសង្គ្រាមស៊ីវិល បង្ហូរឈាមរយៈពេលមួយឆ្នាំ។ ដូច្នេះជនរងគ្រោះគឺប្រហែលជាត្រូវបានគេចាត់ទុកជាអតីតខ្មាំងរបស់បក្សកុម្មុយនីស្ត។ ដូច្នេះហើយការសម្លាប់ដោយសងសឹកប្រហែលជាអាចកើតមាន។

ការសន្និដ្ឋានចុងក្រោយរបស់ខ្ញុំ គឺទាក់ទងទៅនឹងការវិភាគរបស់ព្រះរាជអាជ្ញាទាក់ទងទៅនឹង រស់ ញឹម នៅក្នុងតួនាទីបក្សកុម្មុយនីស្ត និងនៅក្នុងតួនាទីនៃអ្នកដឹកនាំមជ្ឈិមនៃអ្នកដឹកនាំទាំងមូល។ ចំណុចសំខាន់ គឺថាខ្ញុំមិនអាចនិយាយឲ្យច្បាស់លើសពីនេះទេថា រស់ ញឹម មិនមែនគ្រាន់តែមេដឹកនាំភូមិភាគនោះទេ។ រស់ ញឹម ខ្លួនគាត់ខ្លួនគាត់ផ្ទាល់ គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ គាត់ខ្លួនគាត់ផ្ទាល់អាស្រ័យ បើផ្អែកទៅតាមការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺបានចូលរួមដូចគ្នានៅក្នុងការអនុវត្តរបស់គណៈមជ្ឈិមទាក់ទងទៅនឹងការអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ។

[១១:៤១:២៨]

សហព្រះរាជអាជ្ញាបាននិយាយថា នួន ជា ជួប រស់ ញឹម ជារៀងរាល់បីខែម្តង នៅក្នុងភូមិភាគពាយព្យ។ ដូច្នេះសំណួរខ្ញុំគឺថា តើម៉េចដែរ ប្រសិនបើការពិតថា រស់ ញឹម ជួប នួន ជា? តើពួកគាត់អាចនិយាយអ្វីអំពីទំនាក់ទំនងនោះបាន គ្រាន់តែជួបគ្នាប៉ុណ្ណឹង? ព្រះរាជអាជ្ញាបានប្រាប់យើងថា ការជួបហ្នឹងគឺថា រស់ ញឹម បានប្រាប់ នួន ជា អំពីអ៊ំរបស់ នួន ជា គឺឈ្មោះ ស៊ីវ ហេង។

លោកប្រធាន លោក លោកស្រីចៅក្រម យើងមានបញ្ហាយ៉ាងខ្លាំងដែលថា យើងមិនយល់អំពីអ្វីដែលគេចង់និយាយ។ រស់ ញឹម មិនបានស្នើសុំកូនក្តីខ្ញុំ ដើម្បីសម្លាប់ ស៊ីវ ហេង នោះទេ។ ហើយគាត់ក៏ដូចដែលព្រះរាជអាជ្ញាបានសង្កេតឃើញ គឺថាមិនខ្លាចប្រាប់គាត់ថា គាត់បានសម្លាប់ ស៊ីវ ហេង នោះដែរ។ ដូច្នេះហេតុអ្វីបានជា រស់ ញឹម ប្រាប់ នួន ជា អំពី ស៊ីវ ហេង? ហេតុអីក៏មិនប្រាប់ នួន ជា អំពីទួលពោធិ៍ជ្រៃទៅ? សំណួរគឺច្បាស់លាស់ណាស់ ព្រោះថាទួលពោធិ៍ជ្រៃ មិនមែនជាការចាប់អារម្មណ៍ នួន ជា នោះឡើយ។ គឺថាការស្លាប់របស់អ៊ំរបស់លោក នួន ជា ទើបជាការគួរឲ្យអារម្មណ៍ជាងសម្រាប់គាត់។

[១១:៤២:៣៤]

ភស្តុតាងទាក់ទងទៅនឹងសមាជិកជាច្រើនរបស់គណៈអចិន្ត្រៃយ៍ រួមបញ្ចូលទាំងមេដឹកនាំភូមិ-ភាគគឺមិនមានពាក់ព័ន្ធនោះឡើយ។ ដូចដែលយើងបានឃើញកាលពីសប្តាហ៍មុន គឺថាបុគ្គលតែមួយដែលអាចនិយាយអំពីសិទ្ធិអំណាចនេះគឺ អៀង សារី។ គាត់និយាយថា នៅក្នុងអង្គការ ខ្ញុំសូមដកស្រង់សម្តីរបស់គាត់ “ភូមិភាគនីមួយៗ គឺឯករាជ្យ។ សម្លាប់តាមដែលចង់ ធ្វើអ្វីតាមដែលខ្លួនចង់”។

អត្តចរិតរបស់ រស់ ញឹម ចំពោះការសម្លាប់ ស៊ីវ ហេង គឺបង្ហាញច្បាស់អំពីការពិពណ៌នានេះ។ អ្វីដែលព្រះរាជអាជ្ញាអាចឆ្លើយតបបាន គឺតែឡេក្រាម ឬក៏សារទូរលេខមួយចំនួនតូចដែលហាក់ដូចជាបង្ហាញថា រស់ ញឹម បានស្នើសុំយោបល់ ឬក៏ណែនាំពីមជ្ឈិមបក្ស។ ពួកគេមិនបានបង្ហាញអំពីសក្ខីកម្មដែលស៊ីសង្វាក់គ្នា ដែលថាមានការទំនាក់ទំនងពីមជ្ឈិមបក្សទៅមជ្ឈិម ដែលថាការទំនាក់ទំនងហ្នឹងមានការកម្រិតកំណត់ ហើយមិនមានអ្វីជាច្រើននោះឡើយ។ ហើយ នួន ជា គាត់សឹងតែមិនដែលធ្លាប់ផ្ញើសារទូរលេខទៅអ្នកណាម្នាក់នោះឡើយ។ សូម្បីតែការជ្រើសរើសដែលមានចំនួនតិចក៏ដោយ ក៏ការជ្រើសរើសសារទូរលេខហ្នឹង គឺវាមានតែនៅក្នុងឆ្នាំ៧៧ និង៧៨ គឺច្រើនឆ្នាំ ក្រោយហេតុការណ៍នៅទួលពោធិ៍ជ្រៃមកម្ល៉េះ។

[១១:៤៣:៥៨]

លោកប្រធាន លោក លោកស្រីចៅក្រម ទាំងអស់នេះគឺជារយៈពេលដូចដែល ប៉ែន យៀរនិន ប្រាប់យើង គឺថាការគ្រប់គ្រងរបស់មជ្ឈិមទៅលើភូមិកងទ័ពរបស់ខាងពាយ័ព្យហ្នឹង គឺកើនឡើងបន្តិចម្តងៗ។ ឯកសារទាំងអស់នេះគ្រាន់តែអាចបង្ហាញថា ព័ត៌មាននេះត្រូវបានបញ្ជូនទៅមជ្ឈិមបក្សដែលមិនមានស្នើសុំយោបល់ ឬក៏ការណែនាំ ហើយក៏មិនមានការផ្តល់យោបល់ ឬក៏ការណែនាំទៅខាងភូមិភាគនោះដែរ។ សំណួរដែលយើងចង់សួរ គឺថាហេតុអ្វីបានជាឯកសារដែលសហព្រះរាជអាជ្ញាបង្ហាញក្នុងរយៈពេលកន្លងមក ចាប់តាំងពីខែមេសា ៧៥ ហ្នឹង ហេតុអ្វីក៏ឆ្ងាយម្ល៉េះ? ដូច្នេះ យើងចង់សួរថា តើអ្វីវាជារឿងគួរឱ្យចៃដន្យមែនឬ?

លោកប្រធាន លោក លោកស្រីចៅក្រម មានការពិតតែមួយគត់ទាក់ទងទៅនឹង រស់ ញឹម។ ការពិតនោះ គឺថាចុងក្រោយគាត់ត្រូវគេសម្លាប់ ត្រូវគេបោសសម្អាតផងដែរ។ សហព្រះរាជអាជ្ញាបានប្រាប់អង្គជំនុំជម្រះថា រស់ ញឹម ត្រូវបានបោសសម្អាត ប៉ុន្តែចំពោះព្រះរាជអាជ្ញាគឺគេបញ្ចប់សាច់រឿងនៅត្រឹមនេះ។ ប៉ុន្តែចំពោះយើងវិញ គឺថាវាគ្រាន់តែជាការផ្តើមនៃសាច់រឿងថ្មី។

[១១:៤៥:១១]

សហព្រះរាជអាជ្ញាមិនបានប្រាប់បន្តទៅទៀតថា ហេតុអ្វីបាន រស់ ញឹម ត្រូវបានគេបោសសម្អាតនោះទេ។ ចម្លើយគឺថា គាត់ត្រូវបានគេចាត់ទុកថាជាជនក្បត់។ គាត់ត្រូវបានគេចាត់ទុកថាជាជនក្បត់ ព្រោះគាត់ប្រព្រឹត្តផ្ទុយទៅនឹងគោលនយោបាយរបស់បក្ស។ គាត់បានដាក់នូវស្ថានភាពរស់នៅដោយដ៏ធ្ងន់ធ្ងរទៅលើប្រជាជននៅតំបន់ភូមិភាគពាយ័ព្យ ហើយដើម្បីធ្វើឱ្យដួលរលំទៅដល់មជ្ឈិមបក្ស។

លោកប្រធាន លោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញាមិនអាចឆ្លើយតបសូម្បីតែសំណួរតែមួយយ៉ាងសាមញ្ញ។ នេះគឺជាអ្វីដែលខ្ញុំចង់និយាយចុងក្រោយ។ ប្រសិនបើ នួន ជា អាចគ្រប់គ្រង រស់ ញឹម ដោយងាយស្រួលនោះ ហេតុអ្វីពួកគេគិតថាវាចាំបាច់ត្រូវប្រើប្រាស់កម្លាំងទាំហានប្រឆាំងជាមួយ រស់ ញឹម នោះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោម ហើយ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៦នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលតបចុងក្រោយ។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញ យើងនឹងមិននិយាយវែងឆ្ងាយទេ ពីព្រោះថាយើង ៗមិនបានឮអ្វីដែលធ្វើយុត្តកម្មមកលើចម្លើយរបស់យើងទេ។ ជូនដោយហេតុថា អំណះអំណាងដែលខាង ម្ខាងទៀតបានលើកឡើងនោះមិនមានភាពពាក់ព័ន្ធ។ ជូនគឺថាដោយសារយើងបានឆ្លើយតបទៅនឹងបញ្ហានេះអស់ហើយ នៅក្នុងសារណាបញ្ចប់របស់យើង ហើយនិងតាមការនិយាយនៅក្នុងសវនាការនេះផ្ទាល់តែម្តង។

អំណះអំណាងដែលយើងយល់ឃើញថា ពុំមានភាពពាក់ព័ន្ធនោះ ខ្ញុំសូមផ្តល់ឧទាហរណ៍មួយគេបានលើកពីទូរលេខមួយទាក់ទងទៅនឹងលោក អ៊ិន តាំ ដែលជាអតីតយោធានៃសាធារណរដ្ឋខ្មែរ ដែលក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅតែបន្តច្បាំងប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យទៀត តាមព្រំប្រទល់ថៃ។ ហើយគេបាននិយាយផងដែរថា ខ្លឹមសារនៃទូរលេខ-- គឺថាបាននិយាយអំពីសកម្មភាពរបស់លោក អ៊ិន តាំ ដែលចង់ -- ដែលថាគេចង់គាបសង្កត់ទៅលោក អ៊ិន តាំ ហើយនិងអតីតយោធារបបសាធារណ

រដ្ឋខ្មែរ។ នេះមិនមានន័យអ្វីទេ ពីព្រោះថាពួកគេនៅតែបន្តសកម្មភាពប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យទៀត។ ដូច្នេះមិនមានអ្វីពាក់ព័ន្ធជាមួយនឹងកម្មវត្ថុនៃការជម្រះសេចក្ដីយើងហ្នឹងទេ។ ហើយយើងគិតថា អំណះអំណាងប្រភេទនេះពុំមានប្រយោជន៍ទេ។ យើងមិនបាច់ឆ្លើយតបទៅអំណះអំណាងបែបនេះទេ កុំឱ្យតុលាការខាតពេលវេលា។

[១៣:៣២:១៦]

ហើយទាក់ទងទៅនឹងអំណះអំណាង ដែលយើងបានឆ្លើយតបហើយនៅក្នុងសារណារបស់យើង ឬក៏តាមរយៈការនិយាយនៅទីនេះតែម្ដង។ ខ្ញុំសូមលើកឧទាហរណ៍មួយ ដែលមានសំណើ ស្នើដោយព្រះរាជអាជ្ញាឱ្យតុលាការប្រើកថាខណ្ឌ១៣៥០ ទៅដល់១៣៧២នៃដីកាដំណោះស្រាយ ដើម្បីពន្លាតវិសាលភាពទៅដល់គោលនយោបាយទាំងប្រាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ មានកថាខណ្ឌហ្នឹង -- កថាខណ្ឌហ្នឹងមិនអាចបំបែកបានទេ នៅពេលយើងបំបែកនីតិវិធី។ ហើយយើងបានឆ្លើយតបទៅនឹងបញ្ហានេះ ហើយនៅកថាខណ្ឌ១០៥ នៃសារណាបញ្ចប់សេចក្ដីសន្និដ្ឋានរបស់យើង ហើយនៅក្នុងសាលសវនាការនេះ ក៏យើងបានព្យាយាមក្នុងការអានកថាខណ្ឌហ្នឹងទាំងស្រុងផងដែរ។ គឺថាអានឧបសម្ព័ន្ធកាលពីឆ្នាំ២០១២នេះ។ ដូច្នេះ អំណះអំណាងរបស់យើងវាមិនមានប្រយោជន៍អីទេ មិនបាច់និយាយវែងឆ្ងាយទៀតទេ យើងបានឆ្លើយតបហើយ ផ្ដល់អំណះអំណាងហើយអស់ហើយ។

យើងចង់បំភ្លឺបន្តិចបន្តួច យើងគិតថាជាការចាំបាច់ ហើយធ្វើដោយខ្លីទេ។ ម្សិលមិញសហព្រះរាជអាជ្ញា ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា មូលហេតុដែលយើងបានពិពណ៌នាអំពីស្ថានភាពសុខភាពយោធា សេដ្ឋកិច្ចដែលនៅភ្នំពេញ ហើយនិងនៅក្នុងប្រទេសកម្ពុជា នៅខែមេសាឆ្នាំ១៩៧៥ ជួយឱ្យយើងធ្វើយុត្តកម្មលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ខ្ញុំគិតថា មិនត្រឹមត្រូវដូច្នេះទេ។ យើងថ្ងៃនេះ យើងចង់និយាយថា បើសិនជាយើងខំព្យាយាមក្នុងការពិពណ៌នាស្ថានភាពនេះ គឺមានមូលហេតុពីរ។

[១៣:៣៤:២៣]

ទី១) គឺថាចង់បំភ្លឺថា ការដែលសហចៅក្រមស៊ើបអង្កេតបានជ្រើសរើសសិក្សាលើបរិបទប្រវត្តិ-សាស្ត្រមិនបានបដិសេធបញ្ហាមួយចំនួនចោល មិនយកមកនិយាយ។ ឧទាហរណ៍ទាក់ទងទៅនឹងស្ថានភាពសេដ្ឋកិច្ច យោធា សុខាភិបាលជាដើមនោះ នៅសម័យខ្មែរក្រហមនោះ -- នៅមុនការបង្កើតរបបខ្មែរក្រហម។ ហើយនៅពេលដែលយើងធ្វើការពិពណ៌នានៃស្ថានភាពនេះ ពីព្រោះថាយើងចង់និយាយ

អំពីបញ្ហាចេតនារបស់ ខៀវ សំផន។ បញ្ហាគឺថាមិនថា មិនមែនត្រូវដឹងថា តើហេតុអ្វី ខៀវ សំផន សម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ។ ពីព្រោះថាគាត់មិនបានសម្រេចទេ គាត់មិនបានចូលរួមក្នុងការសម្រេចជម្លៀសមនុស្សទេ ជម្លៀសមនុស្សចេញពីទីក្រុងភ្នំពេញនេះ។ ដូច្នេះ អ្វីដែលយើងត្រូវដឹងគឺថា តើការពន្យល់មូលហេតុដែលគេបានផ្ដល់ឲ្យគាត់ក្រោយមកហើយទៀតនោះ អាចជឿជាក់បានដែរឬទេ? ហើយនេះគឺថាគាត់អាចជឿជាក់បានពេលក្រោយមកហើយ។ ទោះបីជាគេសួរគាត់មុនក៏ដោយ ក៏គាត់ប្រហែលជាមិនបានធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ។

[១៣:៣៦:០៤]

វាមិន -- ការពន្យល់មូលហេតុពេលក្រោយមកនោះ គឺថាឈរលើមូលដ្ឋានជាក់លាក់ ស្ថានភាពជាក់លាក់ ស្ថានភាពសុខាភិបាលយោធា ហើយសេដ្ឋកិច្ច។ ហើយចៅក្រមបានទទួលហើយធាតុផ្សំទាំងអស់នេះ ពីការពន្យល់។ ទាំងអស់នេះមិនមែនថាមិនមានខ្លឹមសារទេ ហើយសេចក្ដីពន្យល់ទាំងអស់នេះគឺថាអាចបញ្ចុះបញ្ចូលគេបានច្រើន។

សប្ដាហ៍មុនកាលថ្ងៃសុក្រ យើងបានបញ្ចាំងកិច្ចសម្ភាសន៍របស់សម្ដេច សីហនុ មួយ ខែតុលា ឆ្នាំ១៩៧៥ នៅញូវយ៉ក។ សម្ដេច សីហនុ ឆ្លើយថា ប្រកាសថាគាត់យល់ស្របលើមាគ៌ាការងារខ្មែរក្រហម ដែលត្រូវបានសម្រេចរហូតដល់ថ្ងៃនុំង។ ហើយអង្គាល់នុំងគាត់បានចូលមកទីក្រុងភ្នំពេញហើយ ៗ គាត់ដឹងហើយ គឺថាទីក្រុងភ្នំពេញពុំមានមនុស្សនៅទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះគាត់បានឆ្លើយយ៉ាងដូច្នេះ ហើយអស់លោក លោកស្រីចៅក្រមបានឮហើយកាលពីថ្ងៃសុក្រនេះ។

[១៣:៣៧:១១]

សេចក្ដីប្រកាសទាំងអស់នេះត្រូវបានធ្វើ -- ទាក់ទងទៅនឹងការជម្លៀសដំណាក់កាលទី២ យើងមានភស្ដុតាងមិនអាចជំទាស់បានទេ។ ខាងព្រះរាជអាជ្ញាក៏មិនបានជំទាស់ដែរគឺថា ខៀវសំផន កាលនោះគាត់នៅបរទេសទេទាក់ទងការជម្លៀសលើកទី២នេះ។ នៅពេលដែលគេធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជនដំណាក់កាលទី២នេះ គាត់នៅបរទេសទេ។ ហើយនៅទីនេះមិនមានអ្នកណាបង្ហាញភស្ដុតាងណាមួយថា បង្ហាញថាគាត់បានចូលរួមក្នុងការអនុវត្តនៃការជម្លៀសប្រជាជនលើកទី២នេះទេចាប់ពីខែសីហា ៧៥ រហូតដល់ចុង ៧៦។

ខ្ញុំចង់ធ្វើការកត់សម្គាល់មួយមុននឹងអស់លោក លោកស្រីចៅក្រមធ្វើសេចក្ដីសម្រេច គឺថាទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាកាលពីម្សិលមិញ សូមឲ្យតុលាការចាត់ទុកថាភស្ដុតាងដែល

ប្រមូលបានពីធាតុផ្សំនៅក្រៅភស្តុតាងនោះត្រូវតែពង្រឹងដល់ភស្តុតាងដែលពាក់ព័ន្ធ។

[១៣:៣៨:២៦]

បាទ ជាការពិតណាស់ គោលការណ៍ជាលក្ខណៈទូទៅនេះអាចទទួលយកបាន។ ក៏ប៉ុន្តែការអនុវត្តដូចដែលសហព្រះរាជអាជ្ញាសូមឲ្យតុលាការអនុវត្តនេះ អាចធ្វើឲ្យមានកំហុសតុលាការ ពីព្រោះថាសហព្រះរាជអាជ្ញាសូមឲ្យចាត់ទុកថា ខៀវ សំផន មានពិរុទ្ធភាពអំពីអង្គហេតុដែលមិនទាន់បានសម្រេចនៅទីនេះ ដែលសន្មតថានឹងត្រូវបានសម្រេចនៅពេលក្រោយ។ ហើយទោះបីជាយ៉ាងនេះក៏ដោយបើតាមព្រះរាជអាជ្ញា គឺថាត្រូវ -- គួរតែត្រូវប្រើដោយអង្គជំនុំជម្រះដើម្បីកំណត់ប្រភេទបទចោទបទល្មើស ហើយនិងទម្រង់ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន។ នេះគឺជាការយល់ឃើញមិនត្រឹមត្រូវទេ ហើយដែលរំលោភទៅលើគោលការណ៍ជាមូលដ្ឋាននៃច្បាប់។

បាទ ខ្ញុំសូមបញ្ចប់ដោយនិយាយតែពីរបីម៉ាត់ទេអំពីទម្រង់ទំនួលខុសត្រូវ គឺសហឧក្រិដ្ឋកម្មរួមនេះ ខ្ញុំសូមនិយាយពីរចំណុច។ សហព្រះរាជអាជ្ញាសូមឲ្យតុលាការអនុវត្តលក្ខណៈវិនិច្ឆ័យនៃទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម។ ហើយអំមិញនេះ យើងទើបតែបានពិនិត្យមើលមូលហេតុមួយដែលថាមិនអាចអនុវត្តបានទេ។

[១៣:៤០:១៥]

ក្រៅពីហេតុផលទាំងអស់នេះ ដែលទាក់ទងទៅនឹងវិសាលភាពនៃសំណុំរឿងយើងនេះ ខ្ញុំសូមរំឭកថា បើសិនជាយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតប្រភេទនៃទម្រង់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមនេះដែលក្នុងទម្រង់នេះ គឺកម្រិតនៃភស្តុតាងចាំបាច់ ដើម្បីបង្ហាញអំពីចេតនាទាបជាងហ្នឹងនោះ គឺថាមានមូលហេតុច្បាស់លាស់ គឺថាមានបរិបទជាក់លាក់ មិនមែនបង្កើតហ្នឹងមកដើម្បីធ្វើជាកាដូ ផ្តល់កាដូឲ្យពិភពលោកទេ ហើយនិងឲ្យខាងសហព្រះរាជអាជ្ញានេះ។ អ៊ីចឹងមូលហេតុហ្នឹង គឺថា ពិរុទ្ធជននៃសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ជាប្រព័ន្ធបង្កើតឲ្យចូលរួមក្នុងការបង្កើតជំរំប្រហារជីវិត។ គឺជាកន្លែងមួយដែលគេប្រមូលមនុស្ស ប្រមូលផ្តុំមនុស្ស ហើយក្នុងខណៈដែលបុគ្គលរូបនោះមិនអាចបង្ហាញអំពីលក្ខណៈដែលថាគេយកមនុស្សមកប្រមូលផ្តុំនោះ ហើយគាត់ដឹងផង គាត់មិនដឹងថាមានរឿងអីកើតឡើងនៅក្នុងជំរំនោះផង។

ដូច្នេះយុត្តិសាស្ត្រនេះ យល់ឃើញថាកម្រិតនៃភស្តុតាងដែលបង្ហាញចេតនានេះ ត្រូវតែអាចទាបជាងហ្នឹង។ អ្វីដែលសហព្រះរាជអាជ្ញាសូមឲ្យអស់លោក លោកស្រីចៅក្រមធ្វើនៅពេលថ្ងៃនេះ គឺថាឲ្យ

អស់លោក លោកស្រីចៅក្រមយល់ឃើញថា ប្រទេសកម្ពុជាជាជំរំប្រមូលផ្តុំមនុស្ស។ ហើយសូមឲ្យអនុវត្តទម្រង់សហឧក្រិដ្ឋកម្មរួមនេះ។ នេះមិនត្រឹមត្រូវទេ មិនត្រឹមត្រូវទាល់តែសោះ។ ព្រោះថានៅក្នុងបរិបទដែលខ្ញុំបានលើកឡើងនេះហើយ ដែលថាយុត្តិសាស្ត្រនៃសហឧក្រិដ្ឋកម្មរួមនេះត្រូវបានបង្កើតឡើង។ អ៊ីចឹងវាមិនត្រឹមត្រូវនឹងស្មារតីច្បាប់ទេ ការយល់ឃើញយ៉ាងដូច្នេះនោះ។

[១៣:៤៣:០១]

ហើយលើសពីហ្នឹងទៅទៀត អំណះអំណាងផ្សេងទៀត ដែលទាក់ទងទៅនឹងវិសាលភាពនៃជំនុំជម្រះក្តីយើងនេះ គឺថាអស់លោក លោកស្រីចៅក្រម មិនអាចចាត់ទុកថាប្រទេសកម្ពុជាជាជំរំប្រមូលផ្តុំនោះទេនៅសម័យនោះ។ ពីព្រោះថា មានអង្គហេតុថាអាចឲ្យលោក លោកស្រីចៅក្រម បង្ហាញថាអ៊ីចេះបាន ក៏ប៉ុន្តែសម្រាប់រឿងក្តីពេលៗក្រោយទេ ដំណាក់កាលក្រោយៗទេ។

ការកំណត់សម្គាល់ទី២ ដែលខ្ញុំចង់លើកឡើងដែរ គឺខ្ញុំសូមកត់សម្គាល់ថា ព្រះរាជអាជ្ញានេះនិយាយហួសហេតុ គឺថាមានទ្រង់ទ្រាយជាច្រើន ចំណុចជាច្រើននៃអំណះអំណាងរបស់គាត់។ តាមពិតទៅគាត់សុំឲ្យអស់លោក លោកស្រីចៅក្រមអនុវត្តទម្រង់ពន្លាតទៃនៃសហឧក្រិដ្ឋកម្មរួមនេះ។ គឺជាទម្រង់មួយដែល គឺថាតាំងពីមុនការកាត់សេចក្តីនេះម្ល៉េះ គឺថាដែលជាទម្រង់មួយដែលត្រូវបានបដិសេធចេញហើយ តុលាការយើងនេះបដិសេធហើយទម្រង់នេះនោះ។

អ៊ីចឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដែលថាទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទត្រូវតែរក្សា តម្កល់ដោយសារថាពួកគាត់នោះ ដឹងថានឹងអាចមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ការយល់ឃើញដូច្នេះ មិនអាចអនុវត្តបានទេនៅចំពោះមុខតុលាការយើងនេះ។ ព្រោះថាតុលាការនេះបានសម្រេចរួចហើយ មុននឹងការបើកជំនុំជម្រះនេះ។ ហើយសហព្រះរាជអាជ្ញាហ្នឹងក៏បានទទួលដំណឹងដែរ ដឹងដែររឿងនេះនោះ។

[១៣:៤៤:៥០]

បាទ អស់លោក លោកស្រីចៅក្រម នេះគឺជាការកត់សម្គាល់ដ៏ខ្លីរបស់ខ្ញុំដើម្បីបញ្ចប់ការពិភាក្សាដេញដោលក្នុងក្របខ័ណ្ឌនៃជំនុំជម្រះសេចក្តីយើងនេះ។ បាទ សូមអរគុណលោកប្រធាន សូមបញ្ចប់ត្រឹមនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោក ខៀវ សំផន! តើលោកត្រូវឡើងធ្វើសេចក្ដីថ្លែង បើសិនលោកថ្លែងសូមលោក -- អនុរក្ស មន្ទីរឃុំឃាំងនាំគាត់ទៅឲ្យគាត់ -- នាំគាត់ទៅឈរ -- អង្គុយនៅមុខឈើរាងវង់ក្រចកសេះនៅក្នុងអំឡុង ពេលដែលគាត់ធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាតបចុងក្រោយរបស់គាត់។

*(ជនជាប់ចោទទៅកាន់ឈើរាងវង់ក្រចកសេះ)*

[១៣:៤៦:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ខៀវ សំផន!

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកអាចនិយាយអង្គុយ អង្គុយនិយាយបាន ឃើញស្ថានភាពសុខភាព របស់លោក។

**លោក ខៀវ សំផន៖**

សូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គដែលគង់នៅតាមវត្តអារាមនានាទូទាំងប្រទេស!

សូមគោរពបងប្អូនរួមជាតិទាំងអស់ជាទីស្នេហា!

សូមគោរពដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់!

សូមគោរពលោកប្រធាន! សូមគោរពអស់លោក លោកស្រីចៅក្រមទាំងអស់!

សូមគោរពលោកមេធាវី អស់លោក លោកស្រីមេធាវីទាំងអស់!

សូមគោរពសហព្រះរាជអាជ្ញា!

[១៣:៤៨:២៦]

ក្នុងរយៈប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានស្ដាប់ច្បាស់អំពីអន្តរាគមន៍របស់ភាគីនានា។ ហើយជាពិសេសអន្តរាគមន៍របស់អ្នកដែលបន្ទោសខ្ញុំ ថាខ្ញុំបាននិយាយតិចតួចពេកក្នុងរឿងក្ដីរបស់ខ្ញុំនេះ។ ក៏ប៉ុន្តែព្រមជាមួយគ្នាដដែលនេះ អ្នកដដែលនេះបានប្រើប្រាស់អ្វីដែលខ្ញុំបាននិយាយបន្តិចបន្តួចនោះមកចោទលើរូបខ្ញុំទៅវិញ។ ហេតុនេះបើទោះជាខ្ញុំនិយាយពន្យល់ ដោយបដិសេធមិនព្រមទទួលការចោទប្រកាន់របស់អស់លោក ក៏អស់លោកនៅតែបន្ទោសខ្ញុំ។ តែបើខ្ញុំនៅស្ងៀមក៏អស់លោកនៅតែចោទប្រកាន់ខ្ញុំដដែល។

ខ្ញុំមិនដែលប្រាថ្នា ឬក៏បានសម្រេចជម្លៀសប្រជាជនអ្វីទាល់តែសោះ។ ហើយខ្ញុំក៏មិនដែលប្រាថ្នា ឬសម្រេចឲ្យមានការកាប់សម្លាប់អ្វីទាល់តែសោះ។ ជំនឿខាងនយោបាយរបស់ខ្ញុំ អ្វីដែលខ្ញុំបានខិតខំធ្វើសកម្មភាពជាហូរហែកន្លែងមកនេះ គឺដើម្បីការពារអ្នកទន់ខ្សោយ គឺដើម្បីឲ្យគេគោរពនូវសិទ្ធិជាមូលដ្ឋាន

របស់ពួកគេ ហើយដើម្បីប្រទេសជាតិយើង កម្ពុជាយើងមានភាពរឹងមាំ និងឯករាជ្យបរិបូរ។

[១៣:៥១:៥៦]

បាទ ពិតណាស់ ភាពអយុត្តិធម៌ក្នុងសង្គមធ្វើឲ្យខ្ញុំមិនពេញចិត្តទាល់តែសោះ។ តែវាមិនដល់ថ្នាក់ថាខ្ញុំចង់ឲ្យអ្នកដទៃទទួលភាពអយុត្តិធម៌វិញនោះឡើយ។ ឧត្តមគតិរបស់ខ្ញុំគឺ ជាតិ ឯករាជ្យភាព និងប្រជាជនរស់នៅបានធូរធារ និងសម្បូរសប្បាយ និងទទួលបាននូវកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួនដូចគេឯងឡើងវិញ។ ក៏ប៉ុន្តែពេលដែលខ្ញុំបានឮអ្វីដែលចោទប្រកាន់ដល់រូបខ្ញុំ និងរបៀបនៃការចោទប្រកាន់នៅទីនេះ ហើយពេលដែលខ្ញុំមើលឃើញថា អ្នកដែលនឹងត្រូវចូលរួមសម្រេចលើរឿងក្តីរបស់ខ្ញុំនេះបានបដិសេធ មិនព្រមពិចារណាដល់សភាពការណ៍ជាក់ស្តែងនូវសម័យកាលនោះ ដោយមើលមកខ្ញុំថាខ្ញុំជាព្រាយបិសាចនោះ ខ្ញុំលែងចង់និយាយស្តីអីទៀតហើយ។

បាទ កាលពីសម័យរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ខ្ញុំប្រាថ្នាចង់បានឲ្យខ្មែរក្រហម និងសម្តេច សីហនុ ទទួលបានជ័យជម្នះក្នុងសង្គ្រាម ហើយខ្ញុំបានចូលរួមជាមួយពួកគេ។

បាទ ក្រោយពីការលាលែងរបស់សម្តេច សីហនុ ពីប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ខ្ញុំបានជឿថា មានការកសាងប្រទេសឲ្យបានរីកចម្រើន។

[១៣:៥៥:១៦]

អស់លោកអ្នកទាំងអស់គ្នាដែលនៅទីនេះ អស់លោកហាក់ដូចជាជឿជាក់ថា ខ្ញុំខុស ព្រោះអស់លោកទាំងអស់គ្នា ជឿថា ខ្ញុំគួរតែប៉ាន់ប្រមាណមើលឃើញអំពីអ្វីដែលនឹងកើតឡើងនៅក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហើយខ្ញុំគួរតែឈប់ចូលរួម ឬក៏រត់គេចខ្លួនចេញពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែខ្ញុំនៅបន្តតទៅទៀត លោកក៏ចោទថា ខ្ញុំជាពិរុទ្ធជន។ បើទោះជាខ្ញុំអាចនិយាយបកស្រាយ និងព្យាយាមពន្យល់យ៉ាងណាក៏ដោយ។ តាមអស់លោក ខ្ញុំគួរតែទុកឲ្យ លន់ នល់ បន្តសកម្មភាពរបស់គេ។ ខ្ញុំមិនគប្បីតបតនឹងសកម្មភាពរបស់ លន់ នល់ ឡើយ ឬក៏នៅពេលទទួលបានជ័យជម្នះលើសង្គ្រាម លន់ នល់ និងពួកអាមេរិកហើយ ខ្ញុំត្រូវតែដឹងជាមុនថា នយោបាយ និងឧត្តមគតិរបស់ខ្ញុំនឹងមិនត្រូវបានអនុវត្តនោះទេ។ តែវានឹងត្រូវបង្វែរទៅតាមទិសផ្ទុយពីនេះទៅវិញ ដោយខ្មែរក្រហមដែលគេមានអំណាចគេបានអនុវត្តវិធានការតឹងរ៉ឹងនោះ។

ខ្ញុំមិនបានឃើញរឿងរ៉ាវដែលអាចកើតឡើងនៅថ្ងៃក្រោយនោះទេ ហើយខ្ញុំក៏មិនមានអំណាចអ្វីទៅដាក់កំហិតឲ្យគេកែប្រែនោះដែរ។ អ្នកខ្លះថាខ្ញុំជាជនកំសាក ឯខ្ញុំ ខ្ញុំមិនមែនជាអ្នកមានអំណាចអ្វី

ហើយខ្ញុំក៏មិនខ្វល់អ្វីពីរឿងអត់អំណាចនេះដែរ។ នេះប្រហែលជាទោសកំហុសរបស់ខ្ញុំ ព្រោះថាក្នុងពេលតៗមក ខ្ញុំក៏ស្ថិតនៅក្បែរៗអ្នកមានអំណាចផងដែរ តែខ្ញុំគ្មានអំណាចដូចគេទេ។ តែអស់លោកជឿជាក់ថាខ្ញុំមានអំណាច។ ដូច្នេះហើយបានជាថ្ងៃនេះ ខ្ញុំត្រូវបានគេចាប់ខ្លួនយកមកកន្លែងនេះ។

[១៣:៥៩:៤៥]

នៅថ្ងៃនេះ វាងាយស្រួលណាស់ដែលនិយាយថា ខ្ញុំគួរតែដឹងរឿងរ៉ាវទាំងអស់ យល់រឿងរ៉ាវទាំងអស់ ហើយដូច្នេះខ្ញុំអាចកែប្រែសភាពការណ៍បានទាំងអស់។ តើទាំងអស់គ្នាយល់ថា ខ្ញុំមិនបានព្យាយាមរកយល់ឬ តើទាំងអស់គ្នាពិតជាយល់ឃើញថា នេះជាអ្វីដែលខ្ញុំចង់បានសម្រាប់ប្រជាជនរបស់ខ្ញុំឬ? កាលពីនៅយុវវ័យ ខ្ញុំបានខិតខំទៅតាមលទ្ធភាព និងមធ្យោបាយរបស់ខ្ញុំក្នុងគោលបំណងចង់កែប្រែរបបអយុត្តិធម៌។ ក្រោយមក ខ្ញុំក៏ត្រូវបង្ខំចិត្តរត់គេចខ្លួន។ ខ្ញុំបានរួចជីវិតដោយសារតែខ្ញុំរត់ចូលព្រៃ។

បន្ទាប់មកទៀត នៅពេលដែលខ្ញុំគិតថាមានមនុស្សដែលគេអាចបំពេញកិច្ចការបានល្អប្រសើរជាងខ្ញុំ ដើម្បីផលប្រយោជន៍ប្រជាជន និងជាតិរបស់ខ្ញុំ។ ខ្ញុំក៏ប្រាថ្នាចង់ឲ្យអ្នកទាំងនោះទទួលបានជ័យជម្នះ ហើយខ្ញុំក៏បានផ្តល់ដល់ពួកគេនូវការឧបត្ថម្ភតិចស្តួចស្តើងតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន។ ពីព្រោះខ្ញុំជឿជាក់ទៅលើគម្រោងបដិវត្តន៍របស់គេនោះថា នឹងនាំឲ្យសង្គមបានប្រសើរជាងមុន ជាតិខ្ញុំបានរស់គង់វង្ស ទោះបើប្រទេសខ្ញុំត្រូវទទួលរងគ្រោះដោយសង្គ្រាមមហាវិនាសកម្ម ហើយត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទី រហូតដល់នាំឲ្យមានគ្រោះអាសន្ន ទុរ្ភិក្សថែមទៀតផងក៏ដោយ។

[១៤:០៣:២៨]

ផ្ទុយស្រឡះពីការដែលបានលើកឡើងនៅក្នុងសវនាការនេះ ខ្ញុំមិនដែលបានចូលរួមធ្វើផែនការដែលនាំបង្កឲ្យមានទុក្ខវេទនាទាល់តែសោះ។ គឺមិនដែលទាល់តែសោះ! មិនដែលទាល់តែសោះ! ដូចដែលខ្ញុំបានព្យាយាមនិយាយជម្រាបទៅដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងមកនិយាយនៅក្នុងសវនាការនេះដូច្នោះដែរ គឺថាខ្ញុំមិនដែលគិតថា ចង់ឲ្យរឿងទាំងនោះកើតឡើងទាល់តែសោះ។

នេះជារឿងតែមួយគត់ដែលខ្ញុំអាចនិយាយនៅថ្ងៃនេះ ពីព្រោះវាជាការពិត ប៉ុន្តែគ្មានអ្នកណាចង់ស្តាប់ខ្ញុំឡើយ។ នៅចំពោះមុខការមិនរវល់អើពើដល់ការខិតខំពន្យល់របស់ខ្ញុំ ចំពោះមុខលក្ខខណ្ឌដំណើរការនៃតុលាការនេះ ខ្ញុំមានអារម្មណ៍ថា ទោះបីខ្ញុំខំនិយាយពន្យល់យ៉ាងណាក៏ដោយ ក៏គេនៅតែមិនយកចិត្តទុកដាក់ស្តាប់ខ្ញុំឡើយ។ ផ្ទុយទៅវិញ ខ្ញុំមានអារម្មណ៍ថា ពេលណាខ្ញុំនិយាយគេរឹតតែចងកំហឹងនឹងខ្ញុំកាន់តែខ្លាំងទៅទៀត។

ដូច្នេះ ខ្ញុំគិតថា ខ្ញុំមិនបាច់ឆោតល្ងង់ទៅនិយាយពន្យល់អ្នកដែលមិនចង់ស្តាប់ខ្ញុំនោះទេ។ ខ្លួនខ្ញុំក៏ខ្ញុំសោកស្តាយណាស់ដែរ ដោយខំជឿយ៉ាងខ្លាំងពីដំបូង ថាតុលាការនេះអាចជាឱកាសសម្រាប់ខ្ញុំរូបខ្ញុំក្នុងការពន្យល់។ ក៏ប៉ុន្តែគ្រប់គ្នាចង់បានតែម្យ៉ាងគត់ពីខ្ញុំ គឺការសារភាពសុទ្ធសាធទៅតាមអ្វីដែលគេចោទមកលើខ្ញុំ។ ឯការចោទប្រកាន់នោះទៀតក៏ជាការចោទប្រកាន់លើអំពើដែលខ្ញុំមិនបានប្រព្រឹត្តទាល់តែសោះ។ ដោយហេតុថា ខ្ញុំមិនបានដឹងព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់ណាមួយ ខ្ញុំគ្មានហេតុផលអ្វីទៅលុនតួចំពោះការបង្ខំដាច់ណាត់មកលើខ្ញុំនោះដែរ។ ខ្ញុំយល់ថាការនៅស្ងៀមមិននិយាយស្តីរបស់ខ្ញុំ វាស្របនឹងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្ញុំជាង។ ហើយខ្ញុំទុកលទ្ធភាពជូនអស់លោក លោកស្រីចៅក្រមវិនិច្ឆ័យរូបខ្ញុំទៅចុះ។

មេធាវីទាំងអស់របស់ខ្ញុំ និងក្រុមការងាររបស់ខ្ញុំបានការពារខ្ញុំយ៉ាងរឹងមាំ យ៉ាងខ្លាំងក្លា និងប្រកបដោយការជឿជាក់។ ហើយខ្ញុំសូមអរគុណដល់អ្នកទាំងអស់គ្នា ទោះបីលទ្ធផលវាទៅជាយ៉ាងក៏ដោយ។ ខ្ញុំសង្ឃឹមជឿជាក់ថា ទោះជាយ៉ាងណាក្តីអស់លោក លោកស្រីនឹងស្វែងរកយុត្តិធម៌។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។ អនុរក្សមន្ទីរឃុំឃាំងនាំគាត់ត្រឡប់ទៅកាន់ទីកន្លែងនៅពីក្រោយមេធាវីរបស់គាត់វិញចុះ។

*(ជនជាប់ចោទចាកចេញពីឈើរាងវង់ក្រចកសេះ)*

[១៤:០៩:៥១]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដំណើរការនីតិវិធីសវនាការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីលើសំណុំរឿង០០២/០១ នៃសំណុំរឿង០០២ បានចប់សព្វគ្រប់ហើយ។ ក្រោយពីបានបញ្ចប់ការពិភាក្សាដេញដោលលើភស្តុតាង និងក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលដោយផ្ទាល់មាត់របស់ភាគីលើសំណុំរឿង០០២/០១ រួចមក ក្នុងនាមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខ្ញុំសូមជម្រាបជូនដល់ភាគីនានា និងសាធារណជនបានជ្រាបដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការសវនាការ

ជំនុំជម្រះលើអង្គសេចក្តីពិនិត្យភស្តុតាងលើសំណុំរឿង០០២/០១ ដែលជាផ្នែកដំបូងនៃសំណុំរឿង០០២ ដែលមានជនជាប់ចោទចំនួនពីររូប ១) ឈ្មោះ នួន ជា, ២) ឈ្មោះ ខៀវ សំផន ដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ដំណើរការសវនាការពិភាក្សាដេញដោល ពិនិត្យភស្តុតាងបានចាប់ផ្តើមពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ចំណាយពេលអស់២១២ថ្ងៃ និងសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីចាប់ផ្តើមពីថ្ងៃទី១៦ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ដែលចំណាយពេលវេលាអស់១០ថ្ងៃ។ គិតមកដល់នឹងពេលនេះកិច្ច ដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីលើសំណុំរឿង០០២/០១ បានប្រព្រឹត្តទៅអស់រយៈពេលសរុប២២២ថ្ងៃ។

គិតចាប់តាំងពីពេលចាប់ផ្តើមសវនាការដេញដោលលើភស្តុតាង រហូតមកទល់នឹងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១នេះ មានបុគ្គលចំនួន៩២រូប ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដែលក្នុងនោះរួមមាន អ្នកជំនាញចំនួនបីរូប សាក្សីចំនួន៥៧រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣២រូប។ បន្ថែមលើនេះមានវេជ្ជបណ្ឌិតព្យាបាលចំនួនពីររូប និងអ្នកជំនាញវេជ្ជសាស្ត្រចំនួនពីររូប បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទផងដែរ។

[១៤:១២:៤៧]

នៅក្នុងអំឡុងពេលធ្វើសវនាការលើសំណុំរឿង០០២/០១ ភាគីនានាបានប្តឹងសុំជាលាយលក្ខណ៍អក្សរចំនួនជាង២៩០បណ្តឹង ហើយជាលទ្ធផលគឺមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងសេចក្តីសម្រេចផ្ទាល់មាត់ជាង២៥០សេចក្តីសម្រេច ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូង។

ឯកសារសម្ភារៈជាច្រើនក្នុងសំណុំរឿងដូចជា អត្ថបទសារព័ត៌មាន ទស្សនាវដ្តី កំណត់ហេតុប្រជុំ សារទូរលេខជាតិ អន្តរជាតិ សៀវភៅនិពន្ធរបស់អ្នកជំនាញ ផែនទីបង្ហាញទីតាំងនៃឧក្រិដ្ឋកម្មរូបថតដែលបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារប្រតិចារឹកក្នុងសំណុំរឿង០០១ កំណត់ហេតុសួរចម្លើយជនជាប់ចោទ បទសម្ភាសន៍ សេចក្តីថ្លែងការណ៍ផ្សេងៗរបស់សាក្សី និងបុគ្គលមួយចំនួនដែលបានធ្វើឡើងដោយស្ថាប័នផ្សេងក្រៅពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ត្រូវបានភាគីស្នើសុំឱ្យទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ ហើយជាលទ្ធផលឯកសារចំនួនជាង៤.០០០ ត្រូវបានអង្គជំនុំជម្រះសាលា

ដំបូងសម្រេចទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ ដែលសរុបទាំងអស់មានចំនួន ប្រមាណ ១៦៦.៥០០ទំព័រ ដែលមានបីភាសា។

[១៤:១៤:២៩]

នាពេលនេះដំណើរការសវនាការលើអង្គសេចក្តីចំពោះសំណុំរឿង០០២/០១ ឃើញថាបានចប់សព្វគ្រប់ហើយ។ មុននឹងប្រកាសបិទសវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាដែលរួមមានភាគីនៃរឿងក្តីនៅចំពោះមុខអង្គជំនុំជម្រះនាពេលបច្ចុប្បន្ននេះ ព្រមទាំងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកន្លងមក។

ទន្ទឹមនឹងនេះអង្គជំនុំជម្រះសូមថ្លែងអំណរគុណផងដែរចំពោះការិយាល័យរដ្ឋបាល អង្គភាពផ្នែកចំណុះឲ្យការិយាល័យរដ្ឋបាល ដែលមានភារកិច្ចជួយជ្រោមជ្រែង គាំទ្រកិច្ចដំណើរការសវនាការ។ ជាពិសេសអង្គភាពបកប្រែភាសា និងដោយឡែកចំពោះអ្នកបកប្រែភាសាផ្ទាល់មាត់នៅក្នុងសវនាការនេះ មន្ត្រីអង្គជំនុំជម្រះសាលាដំបូង ផ្នែកសោតទស្សន៍និងរូបភាព អង្គភាពជនរងគ្រោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គភាពគាំពារការពារក្តី អនុរក្សមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្នែកកិច្ចការសាធារណៈ ផ្នែកសន្តិសុខនិងសុវត្ថិភាព ផ្នែកសេវាកម្មទូទៅ និងផ្នែកផ្សេងៗទៀត ដែលចំណុះឲ្យការិយល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំងភាគីជាតិ និងភាគីអន្តរជាតិ។

[១៤:១៦:១៣]

ដូចនេះដែរ អង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់មន្ត្រី បុគ្គលិកមកពីស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្នែកសន្តិសុខទូទៅ ផ្នែកពន្លត់អគ្គិភ័យ ផ្នែកពេទ្យ និងផ្នែកដទៃទៀតដែលពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិក មន្ត្រីមកពីអង្គការ មកពីមជ្ឈមណ្ឌលមួយចំនួនដែលមានជាអាទិ៍ដូចជា អង្គការចិត្តសាស្ត្រសង្គមអន្តរវប្បធម៌ (ធី.ភី.អូ) និងមជ្ឈមណ្ឌលឯកសារកម្ពុជា (ស៊ី.ឌី.ខេម) ដែលអ្នកទាំងអស់ដូចបានរៀបរាប់ខាងលើនេះបានចូលរួម និងជួយជ្រោមជ្រែងគាំទ្រដល់កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០១ អស់ពីកម្លាំងកាយចិត្ត បញ្ញាស្មារតីតាំងពីថ្ងៃចាប់ផ្តើមដំបូងរហូតដល់ទីបញ្ចប់ប្រព្រឹត្តទៅដោយរលូន និងទទួលបាន

លទ្ធផលល្អប្រសើរ។

អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសបិទកិច្ចពិភាក្សាដេញដោល ពិនិត្យភស្តុតាងលើសំណុំរឿងក្តី០០២/០១ ត្រឹមនេះ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបថា បន្ទាប់ពីនេះទៅអង្គជំនុំជម្រះនឹងចាប់ផ្តើមនូវកិច្ចការថ្មីមួយទៀតរបស់ខ្លួន គឺការពិភាក្សាពិចារណាសម្រេចសេចក្តីនិងរៀបចំនូវសាលក្រមវិនិច្ឆ័យលើសំណុំរឿងលេខ០០២/០១នេះ។

[១៤:១៧:៥៥]

ទាក់ទងទៅនឹងកាលបរិច្ឆេទសវនាការប្រកាសសាលក្រម អង្គជំនុំជម្រះសាលាដំបូងមិនទាន់អាចកំណត់ជាក់លាក់បាននៅឡើយទេ ដោយហេតុថា សំណុំរឿងក្តីនេះមានទ្រង់ទ្រាយធំធេង និងមានលក្ខណៈស្មុគស្មាញ ហើយនិងត្រូវធ្វើការ ធ្វើជាបីភាសា ភាសាប្រើប្រាស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការប្រកាសសាលក្រមដល់ភាគី និងសាធារណជនបានជ្រាបជាមុន មុនពេលវេលា ក្នុងកាលវេលាសមស្របមុនពេលប្រកាសសាលក្រម។

ទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២ ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនា-ការនៃសំណុំរឿង០០២ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីនៃរឿងក្តី០០២ បច្ចុប្បន្នទាំងអស់ឲ្យបានជ្រាបថា អង្គជំនុំជម្រះគ្រោងនឹងបើកកិច្ចប្រជុំរៀបចំសវនាការនៃសំណុំរឿង០០២/០២ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីពិនិត្យលើការរៀបចំការជំនុំជម្រះជាបន្តទៀតលើសំណុំរឿងលេខ០០២/០២។ អង្គជំនុំជម្រះនឹងជម្រាបជូនអំពីរបៀបវារៈសម្រាប់កិច្ចប្រជុំនេះនាពេលសមស្របឆាប់ៗខាងមុខនេះ។ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការថ្ងៃនេះត្រឹមនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ឯកាលបរិច្ឆេទកំណត់ឲ្យនាំខ្លួនជនជាប់ចោទមកចូលរួមសវនាការនៅក្នុងឱកាសតុលាការប្រកាសសាលក្រមនោះ អង្គជំនុំជម្រះនឹងចេញដីកាកោះ និងដីកាបង្គាប់នាពេលក្រោយក្នុងកាលវេលាសមស្របឲ្យបានមុនថ្ងៃសវនាការ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការបញ្ចប់នៅម៉ោង១៤:២០នាទី)*